**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សាន សាវាត់**

លោក **ស៊ុន ម៉ាច**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញឹក ឧទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សាន សាវ៉ាត់** និងខ្ញុំបាទឈ្មោះ **ស៊ុន ម៉ាច** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៤ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២៣-២០២៤។ យើងខ្ញុំទាំងពីរនាក់សូមគោរពសម្តែងនូវកត្តញ្ញូតាធម៌ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក **សាន យ៉ន់** និង អ្នកម្តាយ **អ៊ុច វណ្ណា**

លោកឪពុក **ស៊ុន ឡុម** និង អ្នកម្តាយ **រ៉ុន មី**

យើងខ្ញុំទាំងពីររូបជាកូនរបស់លោកអ្នកមានគុណ ពិតជាមានក្តីសោមនស្សរីករាយយ៉ាងកក់ក្តៅ ដែលលោកបានផ្តល់កំណើតដល់កូន ចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូនតាំងពីកុមារភាពបានយ៉ាងល្អប្រសើរបំផុត ដោយបានផ្តល់នូវដំបូន្មានប្រកបទៅដោយព្រហ្មវិហារធម៌ទាំង៤ (បួន) គឺ មេត្តា ករុណា មុទិតា និង ឧបេក្ខា។ លើសពីនេះ លោកអ្នកមានគុណក៏បានពុះពារគ្រប់ឧបសគ្គទាំងឡាយ ក្នុងការផ្តល់ឱ្យកូនបានសិក្សារៀនសូត្រមានចំណេះដឹងរហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ ដើម្បីអនាគតដ៏ត្រចេះត្រចង់របស់កូន។ ចំពោះគ្រប់ដំបូន្មានល្អៗរបស់អ្នកមានគុណនាពេលកន្លងមក កូនបានចង់ចាំទុកក្នុងចិត្តជានិច្ច និងមិនដែលហ៊ានបំភ្លេចម្តងណាឡើយ ទោះបីជាកូននៅទីណាក៏ដោយ ក៏កូននូវតែចងចាំជានិច្ចនូវរាល់ដំបូន្មានរបស់លោកដែលពិតជាមានតម្លៃខ្លាំងបំផុត មិនអាចកាត់ថ្លៃបានឡើយ ចំពោះកូនៗ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សា និងក្លាយជានិស្សិតផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យដ៏ឧដុង្គឧត្តមមួយនេះ និងបានផ្តល់ភាពងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។ លើសពីនេះ យើងខ្ញុំក៏សូមធ្វើការថ្លែងអំណរគុណផងដែរជូនចំពោះ **ឯកឧត្តមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ** ដែលជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ ដែលបានខិតខំអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងការផ្ទេរនូវចំណេះដឹងដល់និស្សិតគ្រប់រូប ជាពិសេសគឺរូបយើងខ្ញុំទាំងពីរនាក់រហូតដល់បញ្ចប់មហាវិទ្យាល័យនីតិសាស្ត្រនេះ។

**សាស្ត្រាចារ្យជំនួយ លោក ញឹក ឧុធី** ដែលជាសាស្ត្រាចារ្យណែនាំដ៏ល្អបំផុតមួយរូប ដែលបានខិតខំប្រឹងប្រែង និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ពន្យល់បន្ថែម ផ្តល់នូវយោបល់ ប្រភពឯកសារនានា និងផ្តល់នូវដំបូន្មានល្អៗអំពីរបៀប ព្រមទាំងគន្លឹះក្នុងការស្វែងរកឯកសារ និងវិធីសាស្ត្រក្នុងការចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង។

ជាទីបញ្ចប់ យើងខ្ញុំសូមបួងសួងដល់ទេវតាឆ្នាំថ្មី សូមជួយប្រសិទ្ធពរជ័យ សិរីមង្គល មហាប្រសើរជូនលោកអ្នកមានគុណទាំងអស់ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់គ្រប់រូប ឱ្យជួបតែពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជោគជ័យគ្រប់ភារកិច្ចការកុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីយើងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររយៈពេល ៤ឆ្នាំកន្លងមកនេះ នៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើឱ្យយើងខ្ញុំទទួលបាននូវពុទ្ធិ ចំណេះដឹង និងគុណវុឌ្ឍី យ៉ាងច្រើនអនេកពីសំណាក់លោកគ្រូ អ្នកគ្រូ ជាសាស្ត្រាចារ្យ ដែលបានខិតខំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់បំផុត។ ជាសក្ខីភាព យើងទាំងពីរនាក់បានជាប់ឈ្មោះជានិស្សិតសរសេរសារណា និងបានធ្វើការត្រិះរិះពិចារណាយ៉ាងត្រឹមត្រូវក្នុងការជ្រើសរើសយកប្រធានបទលើមុខវិជ្ជាដែលខ្លួនពេញចិត្ត។ ដោយការមើលឃើញអំពីសារៈសំខាន់ ភាពចាំបាច់ និងការអនុវត្តជាក់ស្តែងក្នុងប្រព័ន្ធយុត្តាធិការតុលាការ ព្រមទាំងការរីកចម្រើនផ្នែកនីតិរដ្ឋក្នុងសង្គមជាតិបច្ចុប្បន្ន បានធ្វើឱ្យយើងទាំងពីរនាក់មានទំនោរលើប្រធានបទដែលគួរឱ្យចាប់អារម្មណ៍ និងមានសារៈសំខាន់ ដែលទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ដែលប្រធានបទនេះនិយាយអំពី "**ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**" ដែលយើងខ្ញុំយកមកធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរនាក់។

មូលហេតុដែលយើងខ្ញុំបានសម្រេចចិត្តលើកយកប្រធានបទនេះ យកមកសរសេរជាសារណាបញ្ចប់ គឺក្នុងគោលបំណងសិក្សាស្វែងយល់ទៅលើ អត្ថន័យ កម្មវត្ថុ មូលហេតុ ល័ក្ខខ័ណ្ឌ និងស្ថាប័នមានសមត្ថកិច្ចជាពិសេសគឺ វិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ដែលទាំងអស់នេះ ជាសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ នៅក្នុងនីតិវិធីរដ្ឋប្បវេណី។ លើសពីនេះ យើងក៏បានសរសេររៀបរាប់អំពីនីតិវិធីមុនពេលអនុវត្ត នីតិវិធីអនុវត្ត និងនីតិវិធីក្រោយពេលអនុវត្តការប្រគល់អចលនវត្ថុ ដែលនីតិវិធីទាំងអស់នេះ ក្នុងនាមជាអ្នកសិក្សានីតិសាស្ត្រ អ្នកវិជ្ជាជីវៈ អ្នកអនុវត្តច្បាប់ និងប្រជាពលរដ្ឋទូទៅ គម្បីសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ និងច្បាស់លាស់ ជៀសវាងការអនុវត្តខុសអំពីនីតិវិធី។ យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា សៀវភៅសារណានេះ នឹងក្លាយជាឯកសារជំនួយដល់អ្នកសិក្សាលើការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និងជាមូលដ្ឋាននៃការបកស្រាយ ព្រមទាំងជាឯកសារយោង ដែលបានស្រាវជ្រាវ ដកស្រង់ និងចងក្រងឡើងជាសៀវភៅ តាមរយៈការសិក្សាស្រាវជ្រាវ និងដកស្រង់ចេញពី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី លិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធផ្សេងៗ ឯកសារខ្លះៗក្នុងបណ្ណាល័យ និងតាមរយៈអ៊ីនធឺណេត។

ជាចុងក្រោយ យើងខ្ញុំរង់ចាំទទួលការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងមិត្តនិស្សិតជំនាន់ក្រោយ រាល់កំហុសឆ្គងដែលបានកើតឡើងដោយអចេតនា នូវពាក្យពេចន៍ វគ្គឃ្លោងឃ្លា វេយ្យាករណ៍ ឬ អក្ខរក្រម ដោយសារអាចមានការភ្លាត់ភ្លាំងបន្តិចបន្តួច។ ហេតុដូច្នេះ ដើម្បីជួយកែលំអរឱ្យសៀវភៅនេះកាន់តែល្អ និងមានភាពសុក្រឹត្យ យើងខ្ញុំទាំងពីរនាក់សូមការអធ្យាស្រ័យពីមិត្តអ្នកអានរិះគន់ក្នុងន័យស្ថាបនា ដើម្បីអភិវឌ្ឍខ្លួន និងទុកជាបទពិសោធន៍បន្ថែមទៀត។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ទទួលបាននូវពរទាំងឡាយបួន សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេក្តីសុខសំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា សុខភាពល្អ និងជោគជ័យនូវគោលបំណងដែលបានប៉ងប្រាថ្នាគ្រប់ៗគ្នាកុំបីអាក់ខានឡើយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៤

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៤

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៤

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥

**ជំពូកទី១**

**សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**

**ផ្នែកទី១. អត្ថន័យ កម្មវត្ថុ និងមូលហេតុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ** ........ ៧

**កថាភាគទី១. អត្ថន័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ** ........ ៧

**កថាភាគទី២. កម្មវត្ថុនៃការអនុវត្តឱ្យប្រគល់អចលនវត្ថុ** ........ ៧

**កថាភាគទី៣. មូលហេតុដែលនាំឱ្យមានការអនុវត្តឱ្យប្រគល់អចលនវត្ថុ** ........ ៨

៣.១. ដើម្បីរំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តរបស់កូនបំណុលនៃការអនុវត្ត ........ ៨

៣.២. ដើម្បីផ្តល់ការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដល់ម្ចាស់បំណុលនៃការអនុវត្ត ........ ៩

៣.៣. ដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ........ ៩

**ផ្នែកទី២. លក្ខខណ្ឌ និងស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត** ........ ១០

**កថាភាគទី១. លក្ខខណ្ឌគ្រឹះនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ** ........ ១០

១.១. សិទ្ធិទាមទារនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ........ ១០

១.២. អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់ ........ ១០

**កថាភាគទី២. លក្ខខណ្ឌទម្រង់នៃការអនុវត្ត** ........ ១១

២.១. របៀបដាក់ពាក្យសុំ ........ ១១

២.២. ការពិនិត្យពាក្យសុំ ........ ១២

២.៣. លិខិតអនុវត្ត ........ ១២
២.៣.១ លិខិតអនុវត្តទូទៅ ........ ១៣
២.៣.២. លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ........ ១៣
២.៤. រូបមន្តអនុវត្ត ........ ១៤
២.៤.១. រូបមន្តអនុវត្តសាមញ្ញ ឬ ធម្មតា ........ ១៥
២.៤.២. រូបមន្តអនុវត្តពិសេស ........ ១៥
**កថាភាគទី៣. ស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត** ........ ១៦
៣.១. អាជ្ញាសាលា ........ ១៦
៣.២. សិទ្ធិ និងករណីយកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ........ ១៧
៣.២.១. ការបំបាត់នូវការប្រឆាំង ........ ១៧
៣.២.២. អ្នកសង្កេតការណ៍ ........ ១៧
៣.២.៣. ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់ ........ ១៧
៣.២.៤. ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍ ........ ១៨
៣.២.៥. សិទ្ធិចូលក្នុងកន្លែងបិទជិត ........ 18
៣.២.៦. ការធ្វើកំណត់ហេតុ ........ ១៨
**ផ្នែកទី៣. វិធីដោះស្រាយនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ** ........ ១៩
**កថាភាគទី១. អត្ថន័យ** ........ ១៩
**កថាភាគទី២. ការតវ៉ាចំពោះការអនុវត្ត** ........ ១៩
២.១. អត្ថន័យ និង វិសាលភាពនៃការអនុវត្ត ........ ១៩
២.២. មូលហេតុនៃការតវ៉ាចំពោះការអនុវត្ត ........ ២០
២.៣. បុគ្គលដែលមានសិទ្ធិធ្វើការតវ៉ាចំពោះការអនុវត្ត ........ ២០
២.៤. នីតិវិធីនៃការតវ៉ាចំពោះការអនុវត្ត ........ ២១

## ជំពូកទី២

## នីតិវិធីមុនពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

**ផ្នែកទី១. ការរៀបចំដាក់ពាក្យសុំអនុវត្ត** ........ ២៣

**កថាភាគទី១. ការចរចា និងការស្រាវជ្រាវ** .................... ២៣
**កថាភាគទី២. ការសរសេរពាក្យសុំ និងការដាក់ពាក្យសុំ** .................... ២៣
**កថាភាគទី៣. ឯកសារភ្ជាប់ជាមួយពាក្យសុំ** .................... ២៤
**ផ្នែកទី២. ការពិនិត្យពាក្យសុំដោយអាជ្ញាសាលា** .................... ២៤
**កថាភាគទី១. សមត្ថកិច្ចដែនដី** .................... ២៤
**កថាភាគទី២. ភាពត្រឹមត្រូវនៃពាក្យសុំ** .................... ២៥
**កថាភាគទី៣. ភាពគ្រប់គ្រាន់នៃឯកសារ** .................... ២៥
**កថាភាគទី៤. ពន្ធដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ** .................... ២៦
**កថាភាគទី៥. ការបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុន** .................... ២៦
**កថាភាគទី៦. ការបង់សោហ៊ុយនៃការអនុវត្តជាមុន** .................... ២៧
**ផ្នែកទី៣. នីតិវិធីត្រៀមមុនពេលចុះអនុវត្ត** .................... ២៨
**កថាភាគទី១. ការកំណត់សមាសភាពដែលត្រូវចូលរួមអនុវត្ត** .................... ២៨
១.១. អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ .................... ២៩
១.២. អាជ្ញាធរមូលដ្ឋាន(ឃុំ សង្កាត់) .................... ២៩
**កថាភាគទី ២. លិខិតរដ្ឋបាលដែលត្រូវប្រើប្រាស់មុនពេលចុះអនុវត្ត** .................... ២៩
**កថាភាគទី៣. ការកោះហៅកូនបំណុលមកចរចាក្រៅផ្លូវការ** .................... ៣០
**កថាភាគទី៤. ការកោះហៅម្ចាស់បំណុលមកពិភាក្សាអំពីការចំណាយក្នុងការអនុវត្ត** .................... ៣០
**កថាភាគទី៥. ការចុះទៅពិនិត្យស្ថានភាពនៃទីតាំងដែលត្រូវអនុវត្តជាមុន** .................... ៣១
**កថាភាគទី៦. កំណត់កាលបរិច្ឆេទ និងជូនដំណឹងអំពីការអនុវត្ត** .................... ៣២

## ជំពូកទី៣

## នីតិវិធីអនុវត្ត និង ក្រោយពេលអនុវត្តការប្រគល់អចលនវត្ថុ

**ផ្នែកទី១. នីតិវិធីនៃការចុះអនុវត្តការប្រគល់អចលនវត្ថុ** .................... ៣៤
**កថាភាគទី១. កំណត់ទីតាំងដើម្បីជួបជុំគណៈកម្មការ** .................... ៣៤
**កថាភាគទី២. ការសម្របសម្រួលឱ្យកូនបំណុលយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត** .................... ៣៥
**កថាភាគទី៣. ការចុះទៅដល់ទីតាំងដែលត្រូវអនុវត្ត** .................... ៣៥

**កថាភាគទី៤. ករណីមានឧបសគ្គកើតឡើងក្នុងពេលអនុវត្ត** ..... ៣៥

៤.១. ករណីមានការប្រឆាំងកើតឡើង ..... ៣៥

៤.២. ករណីមានអន្តរាគមន៍កើតឡើង ..... ៣៦

៤.៣. ការសម្រេចផ្អាកការអនុវត្ត ..... ៣៧

៤.៤. ការសម្រេចលុបចោលការអនុវត្តដោយបង្ខំ ..... ៣៧

**ផ្នែកទី២. វិធីអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ** ..... ៣៧

**កថាភាគទី១. ករណីអចលនវត្ថុកាន់កាប់ដោយកូនបំណុល** ..... ៣៧

**កថាភាគទី២. ករណីមានសំណាក់របស់កូនបំណុលនៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត** ..... ៣៨

**កថាភាគទី៣. ករណីអចលនវត្ថុត្រូវបានកាន់កាប់ដោយតតិយជន** ..... ៣៩

**កថាភាគទី៤. ករណីមានចលនវត្ថុនៅជាប់ជាមួយអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត** ..... ៣៩

**ផ្នែកទី៣. បញ្ចប់នីតិវិធីនៃការអនុវត្តការប្រគល់អចលនវត្ថុ** ..... ៤០

**កថាភាគទី១. ការធ្វើកំណត់ហេតុនៃការអនុវត្ត** ..... ៤០

**កថាភាគទី២. បញ្ចប់នីតិវិធីនៃការអនុវត្តការប្រគល់អចលវត្ថុ** ..... ៤១

**សេចក្តីសន្និដ្ឋាន** ..... ៤៣

**អនុសាសន៍** ..... ៤៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ សំដៅទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះ ហើយកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់វិញ ហើយដែលសិទ្ធិទាមទារនេះមានកំណត់នៅក្នុងលិខិតអនុវត្ត។ ការអនុវត្តដោយបង្ខំប្រភេទនេះ ត្រូវធ្វើឡើងតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តនោះស្ថិតនៅ ហើយធ្វើការរំលាយសិទ្ធិកាន់កាប់របស់កូនបំណុលនៃការអនុវត្តលើអចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តនោះ និងធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់នោះវិញ។ នីតិវិធីនេះ គឺជានីតិវិធីចុងក្រោយ និងដាច់ដោយឡែកមួយពីនីតិវិធីបណ្តឹងអង្គសេចក្តី ដែលចាប់ផ្តើមឡើងដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តទៅស្ថាប័នអនុវត្ត ដើម្បីសម្រេចសិទ្ធិទាមទារដែលមានចែងនៅក្នុងលិខិតអនុវត្ត។ ជាមួយគ្នានេះដែរ ដើម្បីអាចឱ្យស្ថាប័នអនុវត្តអាចធ្វើការអនុវត្តបានគេត្រូវគោរពលក្ខខ័ណ្ឌមួយចំនួនគឺ ត្រូវមានពាក្យសុំអនុវត្តដោយបង្ខំ លិខិតអនុវត្ត និងរូបមន្តអនុវត្ត និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ។ លើសពីនេះមូលហេតុដែលនាំឱ្យមានការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺត្រូវបានគេធ្វើឡើង ក្នុងគោលបំណងរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ហើយប្រគល់សិទ្ធិនេះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច។ នៅក្នុងករណីនេះ អាជ្ញាសាលា ត្រូវគោរពនូវសិទ្ធិ និងករណីយកិច្ចមួយចំនួនដូចជា ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ អាចស្នើសុំកម្លាំងក្នុងករណីមានការប្រឆាំង និងការអនុវត្តត្រូវស្វែងរកអ្នកសង្កេតការណ៍ អាចអនុវត្តនៅថ្ងៃសម្រាកឬពេលយប់ និងត្រូវធ្វើកំណត់ហេតុក្នុងការអនុវត្ត។

គេអាចធ្វើការបែងចែក នីតិវិធីនៃការអនុវត្តដោយបង្ខំជាបីដំណាក់កាលគឺៈ

- នីតិវិធីមុនពេលចុះអនុវត្តៈ ជាទូទៅ នៅមុនពេលចុះអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គេត្រូវកំណត់អំពីការរៀបចំដាក់ពាក្យសុំ ដែលក្នុងដំណាក់កាលនេះគឺជាដំណាក់កាលដំបូងបង្អស់នៃការត្រៀមសម្រាប់ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ ដោយនីតិវិធីនេះ ផ្តើមឡើងដោយអនុញ្ញាតឱ្យមានការចរចារវាងកូនបំណុល និងម្ចាស់បំណុលនៃការអនុវត្តដោយមានការសម្របសម្រួលពីស្ថាប័នអនុវត្ត ព្រមទាំងការស្រាវជ្រាវអំពីអត្តសញ្ញាណរបស់អចលនវត្ថុ និងឯកសារសំខាន់ៗ ដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។ បន្ទាប់មកម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរពាក្យសុំអនុវត្តឱ្យបានត្រឹមត្រូវ

និងដាក់ពាក្យសុំអនុវត្តនោះ មកស្ថាប័នអាជ្ញាសាលាដែលមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវឯកសារឱ្យបានគ្រប់គ្រាន់។ អាជ្ញាសាលាត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃពាក្យសុំនោះ ដោយពិនិត្យទៅលើ សមត្ថកិច្ច លិខិតអនុវត្ត រូបមន្តអនុវត្ត ឯកសារបង់ពន្ធដាក់ពាក្យសុំ ការបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្ត និងការបង់សោហ៊ុយជាមុន។ បន្ទាប់ពីនោះមកអាជ្ញាសាលាត្រូវកំណត់ អំពីនីតិវិធីត្រៀមមុនពេលចុះអនុវត្តដោយធ្វើការកំណត់អំពីសមាសភាពដែលត្រូវចូលរួមក្នុងការអនុវត្ត លិខិតរដ្ឋបាលដែលត្រូវប្រើប្រាស់មុនពេលចុះអនុវត្ត និងការស្នើសុំកម្លាំងចូលរួមក្នុងការអនុវត្ត ព្រមទាំងការចុះទៅពិនិត្យស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និងទីតាំងដែលត្រូវអនុវត្ត ហើយធ្វើការកំណត់កាលបរិច្ឆេទនៃការអនុវត្ត និងជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ។

- នីតិវិធីនៃការចុះអនុវត្តការប្រគល់អចលអចលនវត្ថុៈ ក្រោយពីនីតិវិធីត្រៀមមុនពេលចុះអនុវត្តត្រូវបានបញ្ចប់ គឺឈានចូលដល់នីតិវិធីនៃការចុះអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាញឹកញយក៏មានឧបសគ្គមួយចំនួនកើតឡើងផងដែរដូចជាករណីមានការប្រឆាំងតវ៉ា ការអន្តរាគមន៍បណ្ដឹងតវ៉ា ឬបណ្ដឹងឧបាស្រ័យផ្សេងៗ ដែលឧបសគ្គទាំងអស់នេះ អាចជាមូលហេតុនៃការផ្អាកការអនុវត្ត ឬ អាចឈានទៅដល់ការលុបចោលការអនុវត្តដោយបង្ខំផងដែរ។ ជាមួយគ្នានេះ ចំពោះវិធីនៃការអនុវត្តប្រភេទនេះ គឺវាអាស្រ័យទៅលើការកាន់កាប់ជាក់ស្ដែងរបស់កូនបំណុលនៃការអនុវត្ត ឬតតិយជន ហើយការរុះរើសំណង់របស់កូនបំណុលនៃការអនុវត្ត ដែលសាងសង់នៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត។ ទន្ទឹមនឹងនេះ អាជ្ញាសាលាក៏ត្រូវធ្វើការចាត់ចែង និងគ្រប់គ្រងឱ្យបានច្បាស់លាស់ចំពោះចលនវត្ថុ ដែលនៅជាមួយនឹងវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តនោះផងដែរ ព្រោះថាចលនវត្ថុទាំងនោះ មិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់ឡើយ។
- បញ្ចប់នីតិវិធីនៃការអនុវត្តការប្រគល់អចលនវត្ថុៈ ចំពោះការបញ្ចប់នីតិវិធីនៃការអនុវត្តប្រភេទនេះវិញនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់ឱ្យបានច្បាស់លាស់អំពីពេលវេលានៃការបញ្ចប់របស់វាឡើយ។ ជាការអនុវត្តជាក់ស្ដែងរបស់អាជ្ញាសាលា នឹងត្រូវបានបញ្ចប់នៅពេលដែលលំហូរនីតិវិធីទាំងអស់ ត្រូវបានបំពេញចប់សព្វគ្រប់ទាំងនៅក្នុងទិដ្ឋភាពច្បាប់ និងការអនុវត្តជាក់ស្ដែង មានន័យថា សិទ្ធិកាន់កាប់របស់កូនបំណុលលើអចលនវត្ថុត្រូវបានរំលាយ ហើយការប្រគល់ការកាន់កាប់អចលនវត្ថុទាំងស្រុងត្រូវបានប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។ ហេតុដូច្នេះហើយ បានជានៅក្នុងនីតិវិធីនេះ ទាមទារឱ្យមានការចូលរួមពីម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងដោយអាណត្តិ បន្ទាប់ពីស្ថាប័នអនុវត្តបានរំលាយការកាន់កាប់របស់កូនបំណុលនេះហើយ។ លើសពីនេះ

ទៅទៀត គេអាចកំណត់ការបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះបានដោយវិធីម្យ៉ាងទៀត គឺការបញ្ចប់ដោយការធ្វើកំណត់ហេតុ និងការអានកំណត់ហេតុជូនដល់អ្នកដែលបានចូលរួមស្តាប់ចាត់ទុកជាការផ្សព្វផ្សាយ និងការប្រកាសរំសាយកម្លាំង ដែលចូលរួមក្នុងការអនុវត្ត។

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជានីតិវិធីចុងក្រោយមួយដែលលំបាកក្នុងការអនុវត្ត និងស្មុគស្មាញ ហើយជួបប្រទះនូវបញ្ហាប្រឈមច្រើន។ ហេតុនេះហើយ អាជ្ញាសាលាត្រូវតែមានភាពឈ្លាសវៃម៉ត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ក្នុងពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុម្តងៗ។ ជាមួយគ្នានេះដែរ ការអនុវត្តនីតិវិធីនេះ គឺទាមទារឱ្យមានការចូលរួមសហការឱ្យបានស្អិតរមួតពីសំណាក់អាជ្ញាធរសាធារណៈ និងស្ថាប័នរដ្ឋដទៃៗទៀត ដែលពាក់ព័ន្ធ។ ការអនុវត្តនីតិវិធីមួយនេះ គឺជាការអនុវត្តច្បាប់មួយដែលមានលក្ខណៈឯករាជ្យរបស់ស្ថាប័នតុលាការ។ ហេតុដូច្នេះហើយ គេមិនគួរឱ្យមានការធ្វើអន្តរាគមន៍របស់ស្ថាប័នអំណាចដទៃទៀត មកលើស្ថាប័នតុលាការឡើយ ពីព្រោះទិដ្ឋភាពនេះ នឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ឯករាជ្យភាពនៃអំណាចតុលាការ។ តាមរយៈការចង្អុលបង្ហាញ និងការជួយជ្រោមជ្រែងពីសំណាក់លោកសាស្ត្រាចារ្យណែនាំ ព្រមទាំងដោយហេតុថា ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជានីតិវិធីចុងក្រោយមួយដែលលំបាកក្នុងការអនុវត្ត និងមានការស្មុគស្មាញ ហើយជួបប្រទះនូវបញ្ហាប្រឈមច្រើន ទើបយើងខ្ញុំក្នុងនាមជានិស្សិតផ្នែកនីតិសាស្ត្រ សូមលើកយកប្រធានបទស្តីពី "**ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**" នេះមកធ្វើការបកស្រាយ ដើម្បីឱ្យនិស្សិតដែលកំពុងសិក្សា និងនិស្សិតជំនាន់ក្រោយៗទៀត ក៏ដូចជាប្រជាពលរដ្ឋទូទៅបានយល់ពីនីតិវិធីនេះឱ្យបានកាន់តែច្បាស់ និងយល់ដឹងថា អ្វីខ្លះជាសិទ្ធិរបស់ម្ចាស់បំណុលក្នុងការរំលាយសិទ្ធិកាន់កាប់របស់កូនបំណុលនៃការអនុវត្តលើអចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តនោះ ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់នោះវិញ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយផ្អែកទៅតាមការសរសេររៀបរាប់ខ្លះៗខាងលើ យើងបានដឹងហើយថា អ្វីទៅជាការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ស្ថាប័នមានសមត្ថកិច្ច និងនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ប៉ុន្តែវាមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារនៅមានអ្វីដែលយើងត្រូវដឹងបន្ថែមទៀតនោះគឺ តើអ្វីជាមូលហេតុដែលនាំឱ្យមានការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ? ហើយតើត្រូវមានល័ក្ខខ័ណ្ឌអ្វីខ្លះ ក្នុងការអនុវត្តឱ្យស្របទៅតាមនីតិវិធីច្បាប់ជាធរមាន? ម្យ៉ាងវិញទៀត ប្រសិនបើកូនបំណុលចង់ធ្វើឧបាស្រ័យទៅលើការអនុវត្តដោយបង្ខំឱប្រគល់អចលនវត្ថុ តើកូនបំណុលអាចធ្វើឧបាស្រ័យទៅតុលាការណា? អ្វីជាកម្មវត្ថុនៃការធ្វើឧបាស្រ័យ? ជាពិសេស តើនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុមានប៉ុន្មានដំណាក់កាល? ហើយក្នុងដំណាក់កាលនីមួយៗត្រូវធ្វើអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ "**ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**" ខាងលើនេះត្រូវបានធ្វើឡើងក្នុងគោលបំណងសិក្សាស្វែងយល់នូវខ្លឹមសារ និងមូលហេតុទាំងឡាយដែលនាំឱ្យមានការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ព្រមទាំងសិក្សាស្វែងយល់អំពីល័ក្ខខ័ណ្ឌ ស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត និងវិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុផងដែរ។ ជាមួយគ្នានេះដែរ ការលើកយកប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវ ក៏ធ្វើឡើងក្នុងគោលបំណងសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីនីតិវិធីមុនពេលអនុវត្ត នីតិវិធីអនុវត្ត និងក្រោយពេលអនុវត្តការប្រគល់អចលនវត្ថុផងដែរ ហើយក៏ជាការសិក្សាស្វែងយល់អត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងលំហូរនីតិវិធីនៃការអនុវត្ត ព្រមទាំងទម្រង់លិខិតរដ្ឋបាល ដែលត្រូវប្រើប្រាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ជាពិសេស គោលបំណងនៃការស្រាវជ្រាវប្រធានបទខាងលើនេះ គឺដើម្បីជាប្រយោជន៍សម្រាប់សិស្សនិស្សិតក្នុងការសិក្សាស្វែងយល់បន្ថែមផង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទដែលយើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវនេះ គឺយើងខ្ញុំធ្វើការស្រាវជ្រាវ និងចងក្រងផ្តោតសំខាន់ទៅលើខ្លឹមសារនៃទ្រឹស្តីនៃនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុតែប៉ុណ្ណោះ ដែលខ្លឹមសារទាំងអស់នេះមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ និង នៅក្នុងសៀវភៅសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគទី២ ហើយដែលកិច្ចការនេះជាសមត្ថកិច្ចផ្តាច់មុខរបស់អាជ្ញាសាលា។

ម្យ៉ាងវិញទៀត ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**" នេះ គឺយើងធ្វើការសិក្សាស្រាវជ្រាវផ្តោតតែទៅលើអចលនវត្ថុដែលបានចុះបញ្ជី ឬដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្លង់រឹង) តែប៉ុណ្ណោះ។

ហើយចំណុចសំខាន់ៗមួយចំនួនដែលយើងខ្ញុំយកមកសរសេរចងក្រងឡើងនេះមានដូចជា ៖

- ស្វែងយល់អំពីសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ស្វែងយល់អំពីមូលហេតុដែលនាំឱ្យមានការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ស្វែងយល់អំពីល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ស្វែងយល់អំពីវិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ស្វែងយល់អំពីនីតិវិធីមុនពេលអនុវត្ត នីតិវិធីអនុវត្ត និងក្រោយពេលអនុវត្តការប្រគល់អចលនវត្ថុ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទអ្វីមួយ ពិតជាមានការលំបាកណាស់ ព្រោះយើងត្រូវចំណាយពេលវេលា

ដ៏មានតម្លៃយ៉ាងច្រើន រួមទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជាពិសេសគឺត្រូវមានការអំណត់អត់ធ្មត់ព្យាយាមទៀតផង ទើបការសិក្សាស្រាវជ្រាវទទួលបានជោគជ័យ។ ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែខិតខំតស៊ូព្យាយាមយ៉ាងយកចិត្តទុកដាក់ និងជម្នះរាល់ឧបសគ្គឱ្យទាល់តែបាន ដើម្បីចងក្រងប្រធានបទនេះឡើង ពីព្រោះប្រធានបទនេះ គឺជាប្រធានបទមួយដែលថ្មី និងជាប្រធានបទមួយដែលយើងខ្ញុំមានការពេញចិត្ត និងមានចំណាប់អារម្មណ៍។ ម្យ៉ាងវិញទៀត ការសិក្សាប្រធានបទនេះ វាអាចជួយឱ្យយើងខ្ញុំមានការរីកចម្រើននូវចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។

លើសពីនេះ ប្រធានបទមួយនេះ នឹងជួយបង្កើនចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុដល់អ្នកសិក្សាស្រាវជ្រាវ ព្រមទាំងអាចយល់ច្បាស់អំពីនីតិវិធី និងដំណើរការនៃការអនុវត្តតាំងពីដើមរហូតដល់ចប់ ហើយយល់អំពីដំណើរការ និងការរៀបចំឯកសាររដ្ឋបាល និងសំណុំរឿង និងភាពបត់បែនក្នុងដំណើរការនៃការអនុវត្តជាក់ស្តែងនៃរឿងក្តីអនុវត្តនីមួយៗ ព្រមទាំងដំណោះស្រាយបញ្ហានៅពេលជួបប្រទះឧបសគ្គមួយចំនួន ដែលអាចកើតមានចំពោះមុខក្នុងពេលចុះអនុវត្ត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាននៃប្រធានបទខាងលើនេះ យើងខ្ញុំបានធ្វើការស្រាវជ្រាវ និងប្រមែប្រមូលយកខ្លឹមសារមួយចំនួនពីប្រភពឯកសារសំខាន់ៗដែលពាក់ព័ន្ធដូចខាងក្រោម ៖

- ខ្លឹមសារដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី
- សៀវភៅសេចក្តីកំណត់មាត្រានីមួយៗរបស់ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី
- ខ្លឹមសារដែលបានសរសេរនៅក្នុងសៀវភៅពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និងទី២ ដែលរៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា
- ឯកសារអេឡិចត្រូនិចដែលទាញចេញពី គេហទំព័រក្រសួងយុត្តិធម៌ និងគេហទំព័រសមាគមអ្នកច្បាប់... ។ល។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនៃសារណានេះ គឺឈរលើការបកស្រាយដោយផ្អែកលើឯកសារ ក្នុងនោះយើងខ្ញុំបានធ្វើការចែកចេញជា ៣ ជំពូកធំៗ និងផ្នែកធំៗដូចខាងក្រោម ៖

### ជំពូកទី១. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

- ផ្នែកទី១. អត្ថន័យ កម្មវត្ថុ និងមូលហេតុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ផ្នែកទី២. ល័ក្ខខ័ណ្ឌ និងស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត
- ផ្នែកទី៣. វិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

**ជំពូកទី២. នីតិវិធីមុនពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**

- ផ្នែកទី១. ការរៀបចំដាក់ពាក្យសុំអនុវត្ត
- ផ្នែកទី២. ការពិនិត្យពាក្យសុំដោយអាជ្ញាសាលា
- ផ្នែកទី៣. នីតិវិធីត្រៀមមុនពេលចុះអនុវត្ត

**ជំពូកទី៣. នីតិវិធីអនុវត្ត និង ក្រោយពេលអនុវត្តការប្រគល់អចលនវត្ថុ**

- ផ្នែកទី១. នីតិវិធីនៃការចុះអនុវត្តការប្រគល់អចលនវត្ថុ
- ផ្នែកទី២. វិធីអនុវត្តដោយបង្ខំឱ្យការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ
- ផ្នែកទី៣. បញ្ចប់នីតិវិធីនៃការអនុវត្តការប្រគល់អចលនវត្ថុ

# ជំពូកទី១
# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

# ជំពូកទី១
# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

នៅក្នុងជំពូកនេះ នឹងសិក្សាទៅលើសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ចំពោះខ្លឹមសារទាក់ទងនឹងសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំនេះ នឹងធ្វើការសិក្សាទៅលើ ៣ ផ្នែកធំៗគឺ ផ្នែកទី១ ធ្វើការបកស្រាយទាក់ទងទៅនឹងអត្ថន័យ កម្មវត្ថុ និងមូលហេតុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ផ្នែកទី ២ ធ្វើការបកស្រាយទៅលើល័ក្ខខ័ណ្ឌ និងស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត ផ្នែកទី៣ វិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។

## ផ្នែកទី១. អត្ថន័យ កម្មវត្ថុ និងមូលហេតុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

### កថាភាគទី១. អត្ថន័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬ នាវា ឬ វត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបាននូវការកាន់កាប់នោះ[1]។

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍ សំដៅទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬ ទីទំនេរណាមួយទៅឱ្យម្ចាស់បំណុល ឬ តតិយជន។ វិធីអនុវត្តនេះ អាចធ្វើទៅបាន ដោយមិនបាច់គិតអំពីអត្ថិភាព ឬ នត្ថិភាពនៃការចុះបញ្ជី ឬ សិទ្ធិផ្សេងៗ ដូចជាកម្មសិទ្ធិជាអាទិ៍ នៃអចលនវត្ថុដែលជាកម្មវត្ថុទេ ហើយថែមទាំងអាចធ្វើទៅបានចំពោះផ្នែកណាមួយនៃអចលនវត្ថុ ដូចជាចំពោះបន្ទប់មួយនៃផ្ទះជាអាទិ៍ទៀតផង។ ការប្រគល់ មានន័យថា ជាការផ្ទេរនូវការគ្រប់គ្រងដោយផ្ទាល់លើអចលនវត្ថុ។ ចំណែកឯការបណ្តេញចេញ មានន័យថា ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត និង ញាតិរបស់អ្នកនោះ រស់នៅក្នុងអចលនវត្ថុ ជាអាទិ៍ ឬ មានវត្ថុផ្សេងៗទៀតក្នុងនោះ ដូចជាគ្រឿងសង្ហារិម ជាអាទិ៍ អ្នកទាំងនោះត្រូវយកវត្ថុទាំងនោះ ហើយរើចេញពីអចលនវត្ថុនោះ[2]។

### កថាភាគទី២. កម្មវត្ថុនៃការអនុវត្តឱ្យប្រគល់អចលនវត្ថុ

នៅក្នុងនីតិវិធីនេះ វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុរួមមាន អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះ ហើយកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត។ អចលនវត្ថុ

---

[1] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២៤(១) "តទៅនេះហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦"។

[2] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩), ១៨០

សំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ ជាអាទិ៍[3]។ ចំណែក នាវា សំដៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹងលើសពី ២០ តោន ទោះបីមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និង ជលយានដែលមានចំណុះសរុបជាតោនក្រោម ២០ តោនដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[4]។

ការអនុវត្តនេះអាចធ្វើទៅបានដោយមិនចាំបាច់គិតអំពីអត្ថិភាព ឬ នត្ថិភាពនៃការចុះបញ្ជី ឬ សិទ្ធិផ្សេងៗ ដូចជាកម្មសិទ្ធិនៃអចលនវត្ថុជាកម្មវត្ថុទេ ហើយថែមទាំងអាចធ្វើទៅបានចំពោះផ្នែកណាមួយនៃអចលនវត្ថុដូចជាចំពោះបន្ទប់នៃផ្ទះជាដើមផងដែរ។ ករណីនេះមានន័យថា ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុស្ថាប័នអនុវត្តអាចធ្វើទៅបានដោយពុំចាំបាច់គិតអំពី ការបានចុះបញ្ជី ឬមិនបានចុះបញ្ជីនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុនេះ នៅអង្គភាពសុរិយោដីនោះឡើយ ហើយជាមួយគ្នានេះដែរ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះ គេក៏អាចធ្វើទៅបានចំពោះផ្នែកណាមួយនៃអាគារ ឬ ផ្ទះក៏បានដែរ ឧទាហរណ៍ដូចជា ការអនុវត្តឱ្យប្រគល់បន្ទប់ណាមួយ ឬ សាលណាមួយនៃអាគារក៏បានដែរ។

ចំពោះករណី នាវា ឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅ ក្នុងនោះរួមមានដូចជា រថយន្តសម្រាប់បោះជំរុំ ផ្ទះចល័ត ជាដើម គេត្រូវយកនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ មកអនុវត្តដូចគ្នាផងដែរ ដោយធ្វើការបណ្តេញជននោះចេញពីចលនវត្ថុនោះ ដោយអនុលោមទៅតាមវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យបណ្តេញចេញពីអាគារ។ ដូច្នេះ ក្នុងករណីនេះ ការប្រគល់របៀបនេះ មានន័យថាជាការផ្ទេរនូវការគ្រប់គ្រងដោយផ្ទាល់ចំពោះអចលនវត្ថុ។

## កថាភាគទី៣. មូលហេតុដែលនាំឱ្យមានការអនុវត្តឱ្យប្រគល់អចលនវត្ថុ

### ៣.១. ដើម្បីរំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តរបស់កូនបំណុលនៃការអនុវត្ត

ការរំលាយការកាន់កាប់នេះ ត្រូវធ្វើឡើងដោយ អាជ្ញាសាលា នៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត[5]។ មានន័យថា កម្មវត្ថុរបស់កូនបំណុលនៃការអនុវត្តត្រូវធ្វើឡើងដោយស្ថាប័នរដ្ឋដែលមាននីតិសម្បទាស្របច្បាប់។ ក្នុងករណីនេះ ម្ចាស់បំណុលនៃការអនុវត្តមិនអាចធ្វើការរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្តដោយខ្លួនឯងបានទេ ព្រោះការរំលាយសិទ្ធិខាងលើនេះវាទាមទារឱ្យមានការចូលរួមពីសំណាក់ស្ថាប័នតុលាការ និងអាជ្ញាធររដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

[3] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២០ "តទៅនេះហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧"។

[4] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៥៥៤។

[5] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៤ (១)។

ការរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត គឺធ្វើឡើងដើម្បីបញ្ឈប់នូវការអនុវត្តនូវសិទ្ធិទាំងឡាយ ដែលកូនបំណុលនៃការអនុវត្តមានពីមុនមក។ ជាមួយគ្នានេះដែរ ការរំលាយសិទ្ធិនេះ គឺជាការរំលាយសិទ្ធិតាមផ្លូវច្បាប់ ហើយជួនកាលក៏មានការប្រឆាំងតបតពីសំណាក់កូនបំណុលនៃការអនុវត្ត ដូចនេះ មានតែអាជ្ញាសាលាទេ ដែលអាចរំលាយការប្រឆាំងនេះបាន តាមរយៈការប្រើប្រាស់នូវកម្លាំងសាធារណៈដើម្បីបំបាត់នូវការប្រឆាំងទាំងនោះបាន[6]។

**៣.២. ដើម្បីផ្តល់ការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដល់ម្ចាស់បំណុលនៃការអនុវត្ត**

ការធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបាននូវការកាន់កាប់នេះ គឺជារឿងមួយដែលមានការលំបាកដូចគ្នាទៅនឹងការរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្តដែរ។ នៅក្នុងនីតិវិធីនៃអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះ អាចធ្វើទៅបានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តនោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត[7]។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ទោះបីជាការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ត្រូវបានរំលាយក៏ដោយក៏មិនអាចសម្រេចគោលបំណងនៃការអនុវត្តបានដែរ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តមិនបានទទួលការកាន់កាប់ទេនោះ។ មានន័យថា ម្ចាស់បំណុលត្រូវទទួលការកាន់កាប់អចលនវត្ថុ បន្ទាប់ពីអាជ្ញាសាលាបានអនុវត្តការប្រគល់ចប់សព្វគ្រប់ ព្រោះថាអាជ្ញាសាលាមិនមានសមត្ថកិច្ចក្នុងការថែរក្សា ឬការពារនូវអចលនវត្ថុខាងលើនេះដោយខ្លួនឯងបានឡើយ សូម្បីតែមួយរយៈពេលខ្លី។ ប្រសិនបើនិយាយឱ្យខ្លីមានន័យថា បើគ្មានវត្តមានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងដោយអាណត្តិទេ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុមិនអាចអនុវត្តបានឡើយ ព្រោះខ្វះការចូលរួមរបស់ម្ចាស់បំណុលដែលជាអ្នកទទួលការកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត។

**៣.៣. ដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត**

ការរំលាយនូវការកាន់កាប់ និងធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តនេះ គឺជាសិទ្ធិដែលម្ចាស់បំណុលនៃការអនុវត្តបានទាមទារទៅស្ថាប័នអនុវត្តដូចមានកំណត់នៅក្នុងពាក្យសុំអនុវត្តដោយបង្ខំ ដើម្បីឱ្យស្ថាប័នអនុវត្តនេះ ជួយសម្រេចសិទ្ធិនូវការទាមទាររបស់ខ្លួន ហើយសិទ្ធិទាមទារនេះ ត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តដោយត្រូវភ្ជាប់មកជាមួយផងដែរនូវរូបមន្តសម្រាប់អនុវត្តនូវការប្រគល់អចលនវត្ថុ ក៏ដូចជាសិទ្ធិដែលខ្លួនបានទាមទារនេះ។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៣៨ (១)។

[7] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៤ (២)។

## ផ្នែកទី២. លក្ខខណ្ឌ និងស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត

### កថាភាគទី១. លក្ខខណ្ឌគ្រឹះនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

#### ១.១. សិទ្ធិទាមទារនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

សិទ្ធិទាមទារ គឺជាការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយដែលមានចែងក្នុងច្បាប់សារធាតុ។ ដូច្នេះ ដើម្បីឱ្យដើមចោទអាចធ្វើការអះអាងសិទ្ធិរបស់ខ្លួន ចំពោះចុងចម្លើយបាន ដើមចោទត្រូវតែមានសិទ្ធិតាមច្បាប់សារធាតុ ជាសិទ្ធិដែលធ្វើការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់។ ដូចជា សិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ[8] គឺជាសិទ្ធិដែលកម្មសិទ្ធិករអាចទាមទារឱ្យប្រគល់មកវិញនូវវត្ថុទៅបុគ្គលដទៃដែលបានដណ្តើមយក ឬ ដកហូត ក្នុងករណីដែលវត្ថុនោះ ត្រូវបានដណ្តើមយក ឬ ដកហូតទៅដោយបុគ្គលដទៃដែលគ្មានសិទ្ធិកាន់កាប់ស្របច្បាប់។ កម្មសិទ្ធិករនៃវត្ថុអាចទាមទារឱ្យអ្នកកាន់កាប់វត្ថុរបស់ខ្លួនដោយជាក់ស្តែង ប្រគល់វត្ថុនោះមកខ្លួនវិញបាន ដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ។ ករណីនេះ កម្មសិទ្ធករមិនអាចធ្វើការសង្គ្រោះដោយប្រើកម្លាំងខ្លួនឯងក្នុងការការពារសិទ្ធិរបស់ខ្លួនបានទេ។ ដូច្នេះ មានវិធានចំនួនពីរដែលកម្មសិទ្ធិករអាចអនុវត្តដើម្បីធ្វើការទាមទារយកមកវិញនូវកម្មសិទ្ធិនោះគឺ ការសម្រេចសិទ្ធិតាមរយៈការអនុវត្តដោយស្ម័គ្រចិត្ត (ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ) ឬ ការសម្រេចសិទ្ធិតាមរយៈបណ្តឹង។ ឧទាហរណ៍ករណីអ្នកជួលបានជួលអចលនវត្ថុទៅអ្នកសុំជួលរយៈពេល ៣ឆ្នាំ ក្រោយបញ្ចប់ការជួល អ្នកសុំជួលមិនព្រមចេញពីអចលនវត្ថុនោះដោយអះអាងថា ខ្លួនជាម្ចាស់នៃអចលនវត្ថុនោះ។ ករណីនេះអ្នកជួលអាចធ្វើការទាមទារឱ្យអ្នកសុំជួលប្រគល់អចលនវត្ថុនោះមកវិញ តាមរយៈបណ្តឹងទាមទារឱ្យប្រគល់អចលនវត្ថុ។ បន្ទាប់ពីទទួលបានសាលក្រម អ្នកជួលអាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់អចលនវត្ថុ តាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់។ ហេតុដូច្នេះ សិទ្ធិទាមទារដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជាប្រភេទសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយប្រភេទ ដែលមានគោលបំណងឱ្យធ្វើសកម្មភាព ក្រៅពីបង់ប្រាក់។

#### ១.២. អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់

កម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺសំដៅលើអចលនវត្ថុដែលបានចុះបញ្ជី។ ពាក្យថា **"អចលនវត្ថុ"** ដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គឺសំដៅលើ ដីធ្លី វត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជាអគារសំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍[9]។ ចំពោះពាក្យថា **"ដែលបានចុះបញ្ជី"** គឺចង់សំដៅលើស្ថានភាពមួយដែលអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តត្រូវបានចុះបញ្ជី ឬ អចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់

[8] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១៥៥។

[9] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១២០ (២)។

អចលនវត្ថុ។ សរុបជារួមមក កម្មវត្ថុនៃការអនុវត្តដោយបង្ខំដែលត្រូវសិក្សាក្នុងពេលនេះ គឺជាអចលនវត្ថុដែលបានចុះបញ្ជី ឬដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលសម្គាល់ថា នរណាជាម្ចាស់កម្មសិទ្ធិករ ហើយអចលនវត្ថុនោះត្រូវបានកាន់កាប់ និងគ្រប់គ្រងដោយកូនបំណុលនៃការអនុវត្ត ហើយដែលក្លាយទៅជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។

ការចុះបញ្ជីអចលនវត្ថុ សំដៅទៅលើការចុះបញ្ជីដែលស្ថាប័នជាក់លាក់របស់រដ្ឋ (រដ្ឋបាលសុរិយោដី) ធ្វើការចុះបញ្ជីអំពីស្ថានភាពរូបសាស្ត្រ និង ទំនាក់ទំនងនៃសិទ្ធិលើអចលនវត្ថុនីមួយៗ ដាក់នៅក្នុងសៀវភៅសាធារណៈដែលបានកំណត់ (សៀវភៅគោលបញ្ជី)។

### កថាភាគទី២. ល័ក្ខខ័ណ្ឌទម្រង់នៃការអនុវត្ត

បន្ទាប់ពីគោរពបាននូវល័ក្ខខ័ណ្ឌសារធាតុខាងលើរួចហើយ ល័ក្ខខ័ណ្ឌបន្ទាប់ គឺត្រូវគោរពនូវល័ក្ខខ័ណ្ឌទម្រង់មួយទៀត ដែលជាល័ក្ខខ័ណ្ឌចាំបាច់មិនអាចខ្វះបាន ព្រោះការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ មិនអាចកើតឡើងដោយឯកឯងបានឡើយ ពោលគឺត្រូវចាប់ផ្ដើមឡើងតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដោយមានលក្ខខណ្ឌទម្រង់ពាក់ព័ន្ធនឹងរបៀបដាក់ពាក្យសុំ ដែលចំណុចទាំងអស់នេះ នឹងធ្វើការសិក្សាដូចខាងក្រោម។

#### ២.១. របៀបដាក់ពាក្យសុំ

ការដាក់ពាក្យសុំឱ្យប្រគល់អចលនវត្ថុ ត្រូវចាប់ផ្ដើមឡើងដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយពាក្យសុំនេះ ត្រូវធ្វើឡើងជាលាយក្ខណ៍អក្សរទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ចគឺអាជ្ញាសាលា[10]។ នៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរនេះ ត្រូវសរសេរចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត
- ឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត។
- សេចក្ដីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ
- វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់[11]។

ចំពោះករណីដែលសុំឱ្យអនុវត្តដោយបង្ខំដោយផ្ទាល់ត្រូវបញ្ជាក់ផងដែរ លើលិខិតនោះនូវអត្តសញ្ញាណនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងត្រូវបញ្ជាក់នូវខ្លឹមសារនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃ

[10] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៣៦។
[11] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៤៩។

ការអនុវត្តដោយបង្ខំ និង ត្រូវបញ្ជាក់នូវខ្លឹមសារនៃសេចក្ដីសម្រេច ដែលទាមទារឱ្យមានការអនុវត្តនោះ ព្រមទាំងភ្ជាប់មកជាមួយនូវលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តផងដែរ។

**២.២. ការពិនិត្យពាក្យសុំ**

បន្ទាប់ពីទទួលបានពាក្យសុំឱ្យអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុចហើយ អាជ្ញាសាលា ត្រូវធ្វើការពិនិត្យពាក្យសុំដូចខាងក្រោមៈ

- តើអាជ្ញាសាលាមានសមត្ថកិច្ចលើការអនុវត្តនេះដែរឬទេ?
- តើពាក្យសុំបានបំពេញនូវលក្ខខណ្ឌត្រឹមត្រូវតាមមាត្រា ៣៤៩ និងមាត្រា ៥២៤ ដែរឬទេ?
- តើភាគីនៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ និងភាគីនៅក្នុងលិខិតអនុវត្តនោះត្រឹមត្រូវ និងដូចគ្នាដែរឬទេ?
- តើមានឯកសារភ្ជាប់គ្រប់គ្រាន់ដែរឬទេ?
- តើបានបង់ពន្ធលើពាក្យសុំឱ្យអនុវត្តតាមបញ្ញត្តិ នៃមាត្រា ៣៧២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង ប្រការ ១៣ នៃប្រកាសស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាដែរឬទេ?
- តើបញ្ជូនទៅកូនបំណុលនៃការអនុវត្តនូវលិខិតអនុវត្ត រូបមន្តអនុវត្តពិសេស ឬ រូបមន្តអនុវត្តច្រើនច្បាប់ដែរឬទេ?
- តើម្ចាស់បំណុលបានបង់សោហ៊ុយជាមុនហើយឬនៅ?

**២.៣. លិខិតអនុវត្ត**

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត[12]។ លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកណាមួយជាក់លាក់ ដែលកំណត់នៅក្រោមនីតិឯកជន ហើយដោយផ្អែកទៅលើឯកសារនេះ ច្បាប់ផ្ដល់នូវអំណាចឱ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិនោះ តាមរយៈការអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុអាចធ្វើទៅបានចាំបាច់ត្រូវតែមានលិខិតអនុវត្ត ពីព្រោះលិខិតនេះ គឺជាឯកសារសំខាន់មួយ ដែលកំណត់អំពីសិទ្ធិទាមទារឱ្យផ្ដល់ ឬ ប្រគល់អចលនវត្ថុជាក់លាក់ណាមួយ ដែលច្បាប់ប្រគល់អំណាចឱ្យស្ថាប័នអនុវត្តដែលមានកំណត់នៅក្នុងច្បាប់។ ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ក៏ប៉ុន្តែការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ អាចធ្វើឡើងបានដោយមិនដាក់លិខិតអនុវត្តក៏បានដែរ[13]។

លិខិតអនុវត្ត រួមមានជាអាទិ៍ សេចក្ដីសម្រេចរបស់តុលាការ និងកំណត់ហេតុផ្សេងៗតាមផ្លូវតុលាការដែលមានអានុភាពដូចសេចក្ដីសម្រេចរបស់តុលាការ ឬ លិខិតយថាភូតដែលធ្វើឡើងដោយសារការី។ ដូច្នេះ

[12] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៥០ (១)។

[13] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥០០។

គេបែងចែកលិខិតអនុវត្តជាពីរប្រភេទ គឺ លិខិតអនុវត្តទូទៅ និង លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ។

**២.៣.១ លិខិតអនុវត្តទូទៅ**

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ដែលលិខិតអនុវត្តនេះ គឺជាលិខិតដែលមានបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុល។ ចំពោះលិខិតអនុវត្តទូទៅនេះ រួមមានចំនួន ០៩ (ប្រាំបួន) ដូចជា៖

ក-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។

ខ-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

គ-ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ។

ឃ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

ង-ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦។

ច-លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។

ឆ-សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្ត ដែលបានចូលជាស្ថាពរតាមបញ្ញត្តិនៃមាត្រា ៣៥២។

ជ-សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរតាមបញ្ញត្តិនៃមាត្រា ៣៥៣។

ឈ-កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាព ដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ[14]។

**២.៣.២. លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ**

លិខិតអនុវត្តនេះ គឺជាលិខិតដែលជាឯកសារបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគរបស់បុគ្គលដែលមានសិទ្ធិប្រាតិភោគដូចជា ហ៊ីប៉ូតែក ឬ សិទ្ធិឃាតទុក ជាអាទិ៍ ដែលបានកំណត់ក្នុងនៅក្រោមច្បាប់សារធាតុ ហើយដែលអាចប្តូរជាប្រាក់ដោយបង្ខំនូវទ្រព្យសម្បត្តិដែលត្រូវធានា តាមរយៈស្ថាប័នអនុវត្ត ហើយទទួលការសងប្រាក់មុនម្ចាស់បំណុលដទៃទៀត។ លិខិតអនុវត្តនេះមានដូចជា៖

[14] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៥០ (២)។

ក-សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ ។

ខ-លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ[15]។

**២.៤. រូបមន្តអនុវត្ត**

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។[16] រូបមន្តអនុវត្ត គឺជាប្រយោគដែលក្រឡាបញ្ជី ឬ សារការី សរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត និង ដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និង អត្ថន័យនៃអំណាចបង្ខំឱ្យអនុវត្ត នៃលិខិតអនុវត្តនោះ។ ជាគោលការណ៍ ស្ថាប័នអនុវត្ត ត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត[17]។ ក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានការបញ្ជាក់អំពីការចូលជាស្ថាពរ ឬ ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលមានភ្ជាប់មកជាមួយនូវរូបមន្តអនុវត្ត លើកលែងតែការអនុវត្តដោយបង្ខំដែលយកលិខិតអនុវត្តមួយចំនួន ដែលបានកំណត់នៅក្នុងមាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីធ្វើជាលិខិតអនុវត្ត ហើយការអនុវត្តដោយបង្ខំនោះដោយកំណត់យកភាគីដែលមានក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ ធ្វើជាកូនបំណុលនៃការអនុវត្តនោះពោលគឺ មិនចាំបាច់ត្រូវមានរូបមន្តអនុវត្តលើលិខិតអនុវត្តនោះទេ គឺគ្រាន់តែយកលិខិតចម្លងយថាភូតនៃលិខិតអនុវត្តធ្វើការអនុវត្តជាការស្រេច។ ចំពោះលិខិតអនុវត្តដែលមិនចាំបាច់មានរូបមន្តអនុវត្ត រួមមាន៖

ក-សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ។

ខ-សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ដែលភ្ជាប់មកជាមួយនូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

គ-ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

បើទោះបីជាមានការកំណត់ដូចខាងលើនេះ ជាអញ្ញត្រកម្មក៏ដោយក៏ម្ចាស់បំណុលនៃការអនុវត្តមិនអាចធ្វើការអនុវត្តដោយបង្ខំដោយគ្មានរូបមន្តអនុវត្តបាននោះទេ នៅក្នុងករណីដែលការអនុវត្តដោយបង្ខំនោះមិនបានកំណត់យកភាគីដែលមានក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ ធ្វើជាកូនបំណុលនៃការអនុវត្ត

[15] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៤៩៦។

[16] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៥៤ (១)។

[17] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩), ៥៣។

មានន័យថា ក្នុងករណីដែលលិខិតអនុវត្តដែលបានកំណត់ខាងលើនេះ កំណត់យកភាគីផ្សេងក្រៅពីភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត មកធ្វើជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ការអនុវត្តដោយបង្ខំបែបនេះ គឺត្រូវមាននូវរូបមន្តអនុវត្ត ហើយត្រូវជារូបមន្តអនុវត្តពិសេសទៀតផង។

ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី ឃើញថាពុំមានកំណត់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃរូបមន្តអនុវត្តនោះទេ។ ប៉ុន្តែបើផ្អែកតាមសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី គឺបានកំណត់យ៉ាងច្បាស់លាស់អំពីប្រភេទនៃរូបមន្តអនុវត្ត ដោយបានបែងចែករូបមន្តអនុវត្តជា ០២ (ពីរ) ធំៗ គឺ រូបមន្តអនុវត្តសាមញ្ញ ឬ ធម្មតា និង រូបមន្តអនុវត្តពិសេស ។

### ២.៤.១. រូបមន្តអនុវត្តសាមញ្ញ ឬ ធម្មតា

រូបមន្តអនុវត្តសាមញ្ញ ឬ រូបមន្តអនុវត្តធម្មតា ពុំមានចែងជាក់លាក់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែមានកំណត់ និងពន្យល់នៅក្នុងសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា៣៥៤ ទំព័រ ៣៣១ ដែលក្នុងនោះបានផ្តល់និយមន័យថា រូបមន្តអនុវត្តសាមញ្ញ ជារូបមន្តអនុវត្តដែលមានចុះសេចក្តីអនុញ្ញាតនៃការអនុវត្តដោយបង្ខំ ដូចដែលបានកំណត់ក្នុងលិខិតអនុវត្ត។ ក្នុងន័យនេះ រូបមន្តអនុវត្តសាមញ្ញ ជារូបមន្តអនុវត្ត ដែលកំណត់យកបុគ្គលដែលមានការបញ្ជាក់ច្បាស់លាស់ក្នុងលិខិតអនុវត្តមកធ្វើជាម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត ហើយដែលពុំមានភ្ជាប់លក្ខខណ្ឌបង្អង់ ឬ ពេលវេលាកំណត់មិនពិតប្រាកដឡើយ ។

### ២.៤.២. រូបមន្តអនុវត្តពិសេស

ក្រៅពី រូបមន្តអនុវត្តធម្មតា គេសង្កេតឃើញមានរូបមន្តអនុវត្តមួយផ្សេងទៀត គឺរូបមន្តអនុវត្តពិសេស។ រូបមន្តអនុវត្តពិសេស មានចែងយ៉ាងជាក់លាក់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីព្រមទាំងមានសរសេរពន្យល់នៅក្នុងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ។ រូបមន្តអនុវត្តពិសេស គឺជារូបមន្តអនុវត្តដែលមានចុះសេចក្តីបញ្ជាក់ថា លក្ខខណ្ឌបង្អង់ត្រូវបានបំពេញ ឬ ពេលកំណត់មិនពិតប្រាកដបានមកដល់ ឬដែលមានចុះសេចក្តីអនុញ្ញាតនៃការអនុវត្ត ដោយបង្ខំដោយយកជនឯទៀតក្រៅពីគូភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ជាម្ចាស់បំណុល នៃការអនុវត្ត ឬ ធ្វើជាកូនបំណុលនៃការអនុវត្ត[18]។ រូបមន្តអនុវត្តពិសេស មិនមែនចេះតែត្រូវបានគេផ្តល់ឱ្យនោះទេ គឺត្រូវបានផ្តល់ដោយត្រូវបំពេញទៅតាមលក្ខខណ្ឌដែលមានចែកកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដូចខាងក្រោម៖

- សិទ្ធិទាមទារដែលត្រូវបានកំណត់ក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ក្រឡាបញ្ជីអាចប្រគល់រូបមន្តអនុវត្តបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញលក្ខខណ្ឌនៃការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ។

[18] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៥៦។

- ការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវបានសរសេរក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត នោះម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការផ្តល់រូបមន្តអនុវត្ត ដែលមានសរសេរនូវហេតុការណ៍នោះ។
- នៅក្នុងករណីដែលមានភាពច្បាស់លាស់ថា អាចនឹងធ្វើការការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុល នៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ឬ ករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ ដោយលិខិតអំពីហេតុការណ៍នោះ ក្រឡាបញ្ជីអាចផ្តល់រូបមន្តអនុវត្ត។ ក្រឡាបញ្ជីត្រូវទទួលបានសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅ ពេលផ្តល់រូបមន្តអនុវត្តនេះ។

## កថាភាគទី៣. ស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត

### ៣.១. អាជ្ញាសាលា

យោងតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ **ជួន ណាត** បានឱ្យនិយមន័យ "**អាជ្ញាសាលា**" សំដៅអ្នកដែលរាជការតាំងឱ្យមានមុខការជាជំនួយតុលាការ... (ត្រូវបានផលប្រយោជន៍ពីគូក្តី តាមកំណត់ដែលច្បាប់អនុញ្ញាតឱ្យយក)។ អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ[19] និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។ ស្ថាប័នយុត្តាធិការនេះស្ថិតក្រោមក្រសួងយុត្តិធម៌ និង មានសមាសភាពជាមន្ត្រីរាជការដែលមានឈ្មោះថា អាជ្ញាសាលាដែលបំពេញការងារ នៅសាលាដំបូងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បង្គាប់ឱ្យធ្វើការ។ ការតាំងស៊ប់អាជ្ញាសាលាពេញសិទ្ធ តាមសំណើពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យក្នុងឋានន្តរសក្តិ ក៣-១៤ ក្រោយពីទទួលបានការវាយតម្លៃពីសាលាដំបូងដែលសាមីខ្លួនធ្វើកម្មសិក្សា។[20] ការតែងតាំង ការតម្លើងថ្នាក់ ឬឋានន្តរសក្តិ ការដាក់វិន័យ ត្រូវអនុវត្តតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលលើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះ[21]។

មុនឆ្នាំ២០០៧ ពុំទាន់មានអាជ្ញាសាលាទេ ប៉ុន្តែក្រសួងយុត្តិធម៌បានចេញសេចក្តីបង្គាប់លេខ១១៧ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពររដ្ឋប្បវេណី និងសេចក្តីសម្រេចផ្សេងៗដោយប្រគល់ភារកិច្ចទៅឱ្យព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង តាមសាលាដំបូងរាជធានី-ខេត្តនីមួយៗជាអ្នកទទួលបន្ទុកអនុវត្ត។ ក្រោយមានក្រមនីតិវិធីរដ្ឋប្បវេណី២០០៧ "**អាជ្ញាសាលា**" ត្រូវបានយកមកប្រើប្រាស់ជាថ្មីនៅក្នុងក្រមនេះ ពេលនោះវិជ្ជាជីវៈអាជ្ញាសាលា ត្រូវបានបង្កើតឱ្យមានឡើងវិញនៅកម្ពុជាជាលើកទី២ បន្ទាប់ពីវិជ្ជាជីវៈអាជ្ញាសាលានេះត្រូវ

[19] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ២៤៦ (៣)។

[20] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, ឆ្នាំ២០១២, មាត្រា ៩ ថ្មី (១)។

[21] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, ឆ្នាំ២០១២, មាត្រា ៩ ថ្មី (២)។

បានបង្កើតលើកដំបូងនៅកម្ពុជាក្នុងឆ្នាំ១៩៣៨។

ក្រោយមក ក្រសួងយុត្តិធម៌បានចេញប្រកាសលេខ៣០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ប្រគល់ភារកិច្ចឱ្យព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជួសអាជ្ញាសាលាជាបណ្តោះអាសន្នសិន។ បន្ទាប់មក **សាលាភូមិន្ទអាជ្ញាសាលា** ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១១៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨។

### ៣.២. សិទ្ធិ និងករណីយកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

#### ៣.២.១. ការបំបាត់នូវការប្រឆាំង

ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា អាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀត ដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន[22]។

#### ៣.២.២. អ្នកសង្កេតការណ៍

នៅពេលចូលទៅទីកន្លែងរស់នៅដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬ ញាតិនៅជាមួយ ឬអ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះ ដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវឱ្យមានវត្តមានមន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ។ ក្នុងករណីដែលអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំដោយប្រើកម្លាំង ឬ ដោយមានជំនួយពីនគរបាល ជាអាទិ៍ តាមបញ្ញត្តិនៃមាត្រា ៣៣៨ កថាខណ្ឌទី ១ នោះបើទោះបីជាមិនចូលទៅក្នុងទីកន្លែងរស់នៅក៏ដោយ ក៏ចាំបាច់ត្រូវមានអ្នកសង្កេតការណ៍ដែរ (មាត្រា ៣៣៩)។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីសង្កេតទៅលើភាពត្រឹមត្រូវនៅក្នុងការអនុវត្ត និងដើម្បីបង្កើតភស្តុតាងសម្រាប់ពេលអនាគតផង ។

#### ៣.២.៣. ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់

អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញការបង្គាប់ ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅ នៅថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ ឬ ពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់។ នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាម

[22] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៣៨។

ការបង្គាប់របស់តុលាការអនុវត្តត្រូវបង្ហាញលិខិតដែលបញ្ជាក់ថា ខ្លួនបានទទួលការអនុញ្ញាតផងដែរ[23]។ ការកំណត់បែបនេះ គឺដើម្បីជៀសវាងការបៀតបៀនដល់ភាពស្ងប់សុខក្នុងជីវភាពប្រចាំថ្ងៃរបស់កូនបំណុលដោយពុំមានភាពចាំបាច់។

**៣.២.៤. ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍**

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬ លក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍បើជននោះទាមទារ[24]។

**៣.២.៥. សិទ្ធិចូលក្នុងកន្លែងបិទជិត**

ក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬ នាវា ឬ វត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ ហើយក្នុងករណីនេះ យោងតាមមាត្រា៥២៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬ វត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយបើចាំបាច់អាចធ្វើការចាត់ចែងជាចាំបាច់ ដើម្បីបើកទ្វារដែលបិទនោះបាន។ ដូចនេះ ក្នុងស្ថានភាពដែលមានការលំបាកក្នុងការអនុវត្តដូចជា ឧបសគ្គនានា ដែលរារាំងក្នុងការចូលទៅកាន់ទីកន្លែងដែលកូនបំណុលនៃការអនុវត្តកាន់កាប់ ដូចជាករណីផ្ទះ ឬ អាគារនោះមានជាប់សោរមិនអាចចូលកើតជាដើម នោះអាជ្ញាសាលាអាចចាត់ចែងឱ្យអ្នកជំនាញធ្វើការកាត់សោរនោះចេញបាន។

**៣.២.៦. ការធ្វើកំណត់ហេតុ**

អាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុស្ដីពីការបំពេញមុខនាទីរបស់ខ្លួន[25]។ អាជ្ញាសាលា ត្រូវរក្សាទុកកំណត់ហេតុអំពីការអនុវត្តដោយបង្ខំ ព្រមទាំងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងរឿងក្ដីដែលមានការអនុវត្តដោយបង្ខំ ដើម្បីធ្វើជាសំណុំរឿងនៃការអនុវត្តដោយបង្ខំ។ ក្នុងករណីនេះ ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំ ដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់ អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដីនោះពីអាជ្ញាសាលាបានដោយបង់ពន្ធ[26]។

---

[23] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៥០។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៥១។

[25] សេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា, ឆ្នាំ២០១២, មាត្រា ២០។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៧៨ (២)។

## ផ្នែកទី៣. វិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

### កថាភាគទី១. អត្ថន័យ

នៅពេលអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្តត្រូវអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិនានា ហើយត្រូវធ្វើការអនុវត្តនោះឱ្យស្របទៅតាមច្បាប់។ ប៉ុន្តែយ៉ាងណាក៏ដោយ ភាពត្រឹមត្រូវតាមច្បាប់ មិនមែនសុទ្ធតែត្រូវបានធានារហូតនោះទេ។ នៅក្នុងករណីដែលមានការអនុវត្តដោយបង្ខំផ្ទុយនឹងច្បាប់ ដូចជាក្នុងករណីដែលសកម្មភាពណាមួយរបស់ស្ថាប័នអនុវត្តបានបំពានទៅលើក្រមនីតិវិធីជាដើម។ ក្រមនីតិវិធីរដ្ឋប្បវេណីបង្កើតឱ្យមានប្រព័ន្ធនៃវិធីឧបាស្រ័យចំពោះការអនុវត្ត ដែលរួមមានបណ្តឹងជំទាស់ និងការតវ៉ាចំពោះការអនុវត្ត។ **បណ្តឹងជំទាស់** គឺជាឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមានលក្ខណៈជាការសម្រេចសេចក្តី ហើយបណ្តឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់។ រីឯ **ការតវ៉ាចំពោះការអនុវត្ត** វិញ គឺជាឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមិនអាចប្តឹងជំទាស់បាន និង ចំពោះការចាត់ចែងការអនុវត្តដោយអាជ្ញាសាលា[27]។ តាមរយៈការសិក្សាពីខាងលើ ចំពោះស្ថាប័នដែលមានសមត្ថកិច្ចក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុគឺ អាជ្ញាសាលា។ ដូច្នេះ ចំពោះវិធីឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា៣៨៤ (ការតវ៉ាចំពោះការអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

### កថាភាគទី២. ការតវ៉ាចំពោះការអនុវត្ត

#### ២.១. អត្ថន័យ និង វិសាលភាពនៃការអនុវត្ត

ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យមួយទាមទារឱ្យតុលាការអនុវត្ត ឬ សាលាដំបូង ឬហៅម្យ៉ាងទៀតថា តុលាការដើម កែតម្រូវនូវការចាត់ចែងការអនុវត្តដែលមិនអាចប្តឹងជំទាស់បាន ដោយអះអាងថាខុសនឹងបញ្ញត្តិស្តីពីនីតិវិធីក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី[28]។

សមត្ថកិច្ចនៃតុលាការចំពោះការធ្វើឧបាស្រ័យនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ[29]។ មានន័យថា គូភាគីមិនអាចព្រមព្រៀងគ្នា ជ្រើសរើសយកសមត្ថកិច្ចនៃតុលាការផ្សេងទៀត ដើម្បីធ្វើការអនុវត្តបានឡើយ។

ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យដែលមានភាពងាយស្រួល និងឆាប់រហ័សជាងការដាក់

[27] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩), ១៩។

[28] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៧) មាត្រា ៣៨៤ (១)។

[29] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៨៦។

ពាក្យបណ្ដឹងជំទាស់។ ការតវ៉ាចំពោះការអនុវត្ត អាចធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្ដឹងជំទាស់បាន និង ការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និង ការយឺតយ៉ាវ ឬ ការធ្វេសប្រហែស ក្នុងការចាត់ចែងការអនុវត្តនោះ[30]។ ការតវ៉ាចំពោះការអនុវត្ត ក៏អាចធ្វើឡើងបានដែរ ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលពុំមានចរិតលក្ខណៈជាដីកាសម្រេច។ ក្រៅពីនេះ ដោយសារថាសកម្មភាពរបស់អាជ្ញាសាលា ពុំមែនជាការសម្រេចសេចក្ដីទេនោះ ទើបបានជាបណ្ដឹងជំទាស់ មិនអាចធ្វើឡើងបានឡើយ ចំពោះសកម្មភាពទាំងនោះ តែអាចធ្វើការតវ៉ាចំពោះការអនុវត្តបាន[31]។

### ២.២. មូលហេតុនៃការតវ៉ាចំពោះការអនុវត្ត

មូលហេតុនៃការតវ៉ាចំពោះការអនុវត្ត ត្រូវបានកម្រិតត្រឹមមូលហេតុដែលថា ស្ថាប័នអនុវត្តបានបំពានទៅលើបញ្ញត្តិនៃនីតិវិធី ដែលខ្លួនត្រូវពិនិត្យ និង គោរពតាម។ ជាឧទាហរណ៍ នត្ថិភាពនៃសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិតអនុវត្តមិនមែនជាបញ្ហាដែលអាជ្ញាសាលា ត្រូវធ្វើការពិនិត្យនោះទេ មូលហេតុនេះ មិនអាចអះអាងបានតាមរយៈការតវ៉ាចំពោះការអនុវត្តឡើយ (ក្នុងករណីនេះ ភាគីត្រូវធ្វើការអះអាងតាមរយៈបណ្ដឹងតវ៉ាចំពោះការទាមទារ ដែលបានកំណត់នៅក្នុងមាត្រា ៣៦៣)។ ប្រសិនបើអាជ្ញាសាលាត្រូវធ្វើការចាត់ចែងការអនុវត្តណាមួយ តែមានភាពយឺតយ៉ាវនៅក្នុងការចាត់ចែងនោះ ការណ៍នេះ គឺជាការបំពានទៅលើបញ្ញត្តិនៃនីតិវិធី ហើយ នៅក្នុងករណីបែបនេះ ម្ចាស់បំណុលអាចធ្វើការតវ៉ាចំពោះការអនុវត្ត ហើយទាមទារឱ្យធ្វើការចាត់ចែងការអនុវត្តនោះបាន (សាលាដំបូងនឹងចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាធ្វើការចាត់ចែងការអនុវត្តនោះ)[32]។

### ២.៣. បុគ្គលដែលមានសិទ្ធិធ្វើការតវ៉ាចំពោះការអនុវត្ត

បុគ្គលដែលមានសិទ្ធិធ្វើការតវ៉ាចំពោះការអនុវត្ត គឺអ្នកដែលទទួលរងការប៉ះពាល់ដោយសារតែការចាត់ចែងការអនុវត្តខុសច្បាប់ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្ត។ ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត តតិយជនក៏អាចធ្វើការតវ៉ាចំពោះការអនុវត្តបានដែរ។

ឧទាហរណ៍៖ ម្ចាស់បំណុល អាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ប្រសិនបើអាជ្ញាសាលាលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលធ្វើឡើងដោយត្រឹមត្រូវតាមច្បាប់ ឬ ធ្វេសប្រហែសមិនធ្វើការចាប់ផ្ដើមការអនុវត្តដោយបង្ខំ។ កូនបំណុល អាចធ្វើការតវ៉ាចំពោះការអនុវត្តដោយបង្ខំបាន ប្រសិនបើល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចាប់ផ្ដើមការអនុវត្តដោយបង្ខំ ដូចជា ការបញ្ជូនលិខិតអនុវត្ត ការមកដល់នូវពេលកំណត់ពិតប្រាកដ ជាអាទិ៍

[30] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៤៤ (១,២)។

[31] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩), ២២។

[32] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩), ២២។

មិនត្រូវបានបំពេញ ឬ ប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលានោះខុសច្បាប់ ករណីថាប្រសិនបើការអនុវត្តដោយបង្ខំនៅពេលយប់ដោយពុំមានការអនុញ្ញាត ការរឹបអូសចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស តតិយជនអាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ប្រសិនបើខ្លួនបានទទួលរងការប៉ះពាល់ដោយសារការអនុវត្តខុសច្បាប់ ដូចជាករណីនៃការរឹបអូសទ្រព្យដោយយល់ច្រឡំថា ទ្រព្យនោះ ជាកម្មសិទ្ធិរបស់កូនបំណុល បើទោះបីជាមានភាពច្បាស់លាស់ថា ទ្រព្យនោះ ជាកម្មសិទ្ធិរបស់តតិយជនក៏ដោយ។

**២.៤. នីតិវិធីនៃការតវ៉ាចំពោះការអនុវត្ត**

ជាទូទៅ ការតវ៉ាចំពោះការអនុវត្ត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (ការតវ៉ាដោយផ្ទាល់មាត់អាចធ្វើទៅបាននៅកាលបរិច្ឆេទតុលាការ) ទៅតុលាការអនុវត្តដែលពាក់ព័ន្ធ ប្រសិនបើការតវ៉ានោះធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ឬ ទៅសាលាដំបូងដែលអាជ្ញាសាលាពាក់ព័ន្ធស្ថិតនៅ ប្រសិនបើការតវ៉ានោះធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ឬ ចំពោះការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្តនោះ[33]។

ពុំមានការកម្រិតអំពីអំឡុងពេលដែលអាចធ្វើការតវ៉ាចំពោះការអនុវត្តទេ គឺថាការតវ៉ាអាចធ្វើទៅបានឱ្យតែមានផលប្រយោជន៍ក្នុងការតវ៉ានោះ (ផលប្រយោជន៍ជាក់ស្តែងនៅក្នុងការកែតម្រូវការអនុវត្ត)។ នៅក្នុងការអនុវត្តទូទៅ ផលប្រយោជន៍នៃការតវ៉ានឹងរលត់ ប្រសិនបើមិនបានធ្វើការតវ៉ា នៅក្រោយការចាប់ផ្តើមការចាត់ចែងការអនុវត្ត និង នៅមុនពេលបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលរួមបញ្ចូលនូវការចាត់ចែងនោះ។

តុលាការអនុវត្ត ឬ សាលាដំបូង ធ្វើការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តដោយចេញដីកាសម្រេច[34]។ តុលាការមានឆន្ទានុសិទ្ធិនៅក្នុងការកំណត់ថា តើត្រូវធ្វើ ឬ មិនត្រូវធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីចេញដីកាសម្រេច។ ប្រសិនបើមិនធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចសួរភាគី និង អ្នកដែលពាក់ព័ន្ធដទៃទៀតបាន។ ប្រសិនបើតុលាការអនុវត្ត ឬ សាលាដំបូងយល់ឃើញថា ការតវ៉ាចំពោះការអនុវត្តផ្ទុយនឹងច្បាប់ ឬ មិនមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ានោះ ប្រសិនបើយល់ឃើញថា ការតវ៉ាចំពោះការអនុវត្តដែលធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត មានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តនោះ ប្រសិនបើយល់ឃើញថា ការតវ៉ាចំពោះការអនុវត្តដែលធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា មានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលុបចោលការចាត់ចែងការអនុវត្ត ឬ ហាមឃាត់ការអនុវត្ត។

[33] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៨៥។

[34] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៣៧ (១,៣)។

ទោះបីជាមានការតវ៉ាចំពោះការអនុវត្តក៏ដោយ ក៏ដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ មិនផ្អាកដោយឯកឯងដែរ ក៏ប៉ុន្តែ ដូចក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងជំទាស់ដែរ តុលាការអនុវត្ត ឬ សាលាដំបូង អាចបង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ឬ ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំបាន[35]។ ជាគោលការណ៍ ការសម្រេចសេចក្តី (ដីកាសម្រេច) អំពីការតវ៉ាចំពោះការអនុវត្ត ត្រូវបានកម្រិតត្រឹមការសម្រេចសេចក្តីម្តងតែប៉ុណ្ណោះ។ មានន័យថា ឧបាស្រ័យផ្សេងទៀត (បណ្តឹងជំទាស់) ចំពោះការសម្រេចសេចក្តីនេះ មិនអាចធ្វើឡើងបានទេ។ ក៏ប៉ុន្តែ ដោយសារថា ដីកាសម្រេចដូចខាងក្រោមនេះ សុទ្ធតែជាដីកាសម្រេចសំខាន់ៗដែលបញ្ចប់ដោយផ្ទាល់ ឬ ដោយប្រយោល នូវនីតិវិធីនៃការអនុវត្តដោយបង្ខំនោះ ដើម្បីជាការប្រុងប្រយ័ត្ន ទើបបានជាមានការអនុញ្ញាតជាពិសេស ឱ្យអាចប្តឹងជំទាស់បាន ចំពោះដីកាសម្រេចទាំងនោះដូចមានចែងក្នុងមាត្រា ៣៤៥ កថាខណ្ឌទី ១ ចំណុច ក ដល់ចំណុច គ ដូចខាងក្រោម៖

(ក) ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ។

(ខ) ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ។

(គ) ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ[36]។

[35] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៤៤ (៣)

[36] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ* (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩), ២៣, ២៤។

# ជំពូកទី២

# នីតិវិធីមុនពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

# ជំពូកទី២
# នីតិវិធីមុនពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

## ផ្នែកទី១. ការរៀបចំដាក់ពាក្យសុំអនុវត្ត

### កថាភាគទី១. ការចរចា និងការស្រាវជ្រាវ

មុនពេលចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាធម្មតាម្ចាស់បំណុលនៃការអនុវត្តមិនចង់ឱ្យមានការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុភ្លាមៗ ដោយពុំបានចរចាជាមួយនឹងកូនបំណុលនៃការអនុវត្តនោះទេ ហើយស្ថាប័នអនុវត្តក៏មិនចង់ធ្វើការអនុវត្តភ្លាមៗដោយពុំបានសួរនាំ ឬ ធ្វើការចរចានោះដែរ។ ហើយវាក៏ជានីតិវិធីមួយដ៏ល្អដែលមានលក្ខណៈទន់ភ្លន់ផង។ ស្ថាប័នអនុវត្តតែងតែកោះហៅកូនបំណុលនៃការអនុវត្ត ឱ្យមកជួបចរចាជាមួយនឹងម្ចាស់បំណុលនៃការអនុវត្តដោយមានការសម្របសម្រួលពីអាជ្ញាសាលា។ ក្នុងករណីនេះ ស្ថាប័នអនុវត្តអាចធ្វើការជូនដំណឹងទៅកូនបំណុល ដោយការដាស់តឿនកូនបំណុលឱ្យយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត តាមរយៈការចេញលិខិតជូនដំណឹងបង្គាប់ឱ្យអនុវត្តដោយស្ម័គ្រចិត្ត ហើយបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ដើម្បីទុកជាការជូនដំណឹង។ ដោយហេតុថា នីតិវិធីនេះមានលក្ខណៈស្មុគស្មាញ និងត្រូវចំណាយពេលវេលា ព្រមទាំងប្រាក់កាសច្រើន ហេតុនេះហើយ បើកូនបំណុលនៃការអនុវត្តយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត ដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តនោះភាគីនឹងមានផលប្រយោជន៍ និងចំណេញជាច្រើននូវពេលវេលា ក៏ដូចជាប្រាក់កាស។ ប៉ុន្តែ ប្រសិនបើកូនបំណុលនៃការអនុវត្តមិនព្រមអនុវត្តដោយស្ម័គ្រចិត្តនោះទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ។

### កថាភាគទី២. ការសរសេរពាក្យសុំ និងការដាក់ពាក្យសុំ

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ពាក្យសុំនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច នៅកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ[37]។ ពាក្យសុំនេះ ត្រូវសរសេររៀបរាប់អំពីចំណុចនីមួយៗនៃមាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាពិសេសត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីអត្តសញ្ញាណនៃអចលនវត្ថុនៃការអនុវត្តដោយបង្ខំ។ ក្នុងករណីដែលពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់នេះមានភាពខ្វះចន្លោះ ឬ មិនត្រឹមត្រូវ អាជ្ញាសាលាត្រូវធ្វើការជូនដំណឹងទៅអ្នកដាក់ពាក្យសុំឱ្យមកកែតម្រូវពាក្យសុំតាមមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ បើអ្នកដាក់ពាក្យសុំមិនព្រមកែតម្រូវតាមការជូនដំណឹងនោះទេ អាជ្ញាសាលាអាចធ្វើការលើកពាក្យសុំចោលតាមមាត្រា៧៨ ដដែលនៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ហើយក្នុង

[37] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៥២៤ (១)។

ករណីនេះអ្នកដាក់ពាក្យសុំត្រូវមកដាក់ពាក្យសុំម្តងទៀតនៅស្ថាប័នអាជ្ញាសាលា ដើម្បីអាចធ្វើការអនុវត្តដោយបង្ខំបាន។

**កថាភាគទី៣. ឯកសារភ្ជាប់ជាមួយពាក្យសុំ**

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត[38] (សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក និងកំណត់ហេតុសះជា) រូបមន្តអនុវត្ត លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃលិខិតអនុវត្តវិក័យបត្របង់ពន្ធដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និងលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ និងលិខិតផ្សេងៗទៀត ដែលមានចែងនៅក្នុងមាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រភេទនៃលិខិតទាំងអស់ខាងលើនេះ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ធានានូវភាពស្របច្បាប់នៃការអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។

**ផ្នែកទី២. ការពិនិត្យពាក្យសុំដោយអាជ្ញាសាលា**

**កថាភាគទី១. សមត្ថកិច្ចដែនដី**

ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ស្ថាប័នអនុវត្តជាពីរប្រភេទ គឺ តុលាការអនុវត្ត និង អាជ្ញាសាលា[39]។ តុលាការអនុវត្ត និង អាជ្ញាសាលា មានចរិតលក្ខណៈផ្សេងពីគ្នា ហេតុដូច្នេះបានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាទៅឱ្យស្ថាប័ននីមួយៗដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្ត និង ទៅតាមប្រភេទបែបបទនៃការអនុវត្ត។ ចំណែកពាក្យសុំឱ្យអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវដាក់ឱ្យត្រូវនឹងសមត្ថកិច្ចរបស់អាជ្ញាសាលា ដោយត្រូវគិតពិចារណាទៅលើសមត្ថកិច្ចដែនដី ឬ សមត្ថកិច្ចតាមកម្មវត្ថុ។ ក្នុងករណីនេះ ប្រសិនបើពាក្យសុំអនុវត្តដោយបង្ខំនេះ ត្រូវបានដាក់ទៅខុសសមត្ថកិច្ចនោះស្ថាប័នអាជ្ញាសាលានឹងមិនអាចអនុវត្តបានឡើយ វាមានន័យថា អាជ្ញាសាលាមិនអាចធ្វើការអនុវត្តដោយបង្ខំ ដោយបំពានលើសមត្ថកិច្ចរបស់ស្ថាប័នដទៃបានឡើយ ជាពិសេសគឺសមត្ថកិច្ចរបស់តុលាការអនុវត្ត ឬ សមត្ថកិច្ចដែនដីរបស់អាជ្ញាសាលាដែនដីផ្សេងៗបានទេ។ ហេតុនេះហើយការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អាជ្ញាសាលា មិនមែនជាសមត្ថកិច្ចរបស់តុលាការអនុវត្តទេ។ ដូចដែលមានចែងក្នុងមាត្រា ៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់យ៉ាងច្បាស់អំពីសមត្ថកិច្ចរបស់អាជ្ញាសាលា ក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ដូច្នេះអ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យសុំទៅអាជ្ញាសាលានៃសាលាដំបូងនៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ។ ជាមួយគ្នានេះដែរអាជ្ញាសាលាក៏ត្រូវពិនិត្យទៅលើសមត្ថកិច្ចតាមកម្មវត្ថុផងដែរ ព្រោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត គឺជាឧបករណ៍

[38] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៥២ (១)។

[39] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៣៦ (២)។

សំខាន់មួយដែលអាចកំណត់អំពីដែនសមត្ថកិច្ចជាក់លាក់របស់ស្ថាប័នអនុវត្តផងដែរ។

**កថាភាគទី២. ភាពត្រឹមត្រូវនៃពាក្យសុំ**

ជាធម្មតាការអនុវត្តដោយបង្ខំ គឺជានីតិវិធីដោយឡែកមួយដាច់ពីគ្នាពីនីតិវិធីបណ្តឹង ដែលតម្រូវឱ្យមានការដាក់ពាក្យសុំអនុវត្តពីម្ចាស់បំណុលនៃការអនុវត្ត ដូចនេះ ពាក្យសុំអនុវត្តដោយបង្ខំត្រូវមានភាពត្រឹមត្រូវ និងគោរពទៅតាមល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងច្បាប់។ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវដាក់ពាក្យសុំត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រា ៣៤៩ របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ និងមាត្រា៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីនេះ អ្នកដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវសរសេរពាក្យសុំអនុវត្តដោយបង្ខំជាលាយលក្ខណ៍អក្សរ ដោយនៅក្នុងពាក្យសុំនោះ ត្រូវមានភ្ជាប់ជាមួយនូវលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត។ ជាមួយគ្នានេះដែរ នៅក្នុងពាក្យសុំនេះត្រូវមានបញ្ជាក់អំពីខ្លឹមសារមួយចំនួនដូចជា ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ សញ្ញាណនៃលិខិតអនុវត្ត និងសេចក្តីស្នើសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។ លើសពីនេះ គេត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីសញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ព្រមទាំងខ្លឹមសារនៃសេចក្តីសម្រេច ដែលម្ចាស់បំណុលសុំក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស វិធានបង្ខំដោយប្រយោល។ ជាមួយគ្នានេះ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។ ដូច្នេះ ការបញ្ជាក់ឱ្យច្បាស់អំពីសញ្ញាណនៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត អត្តសញ្ញាណរបស់គូភាគីនៃការអនុវត្ត សញ្ញាណនៃលិខិតអនុវត្ត ប្រភេទនៃការអនុវត្តនិងវិធីដែលត្រូវយកមកអនុវត្ត គឺជាឧបករណ៍គតិយុត្តមួយដ៏សំខាន់សម្រាប់បង្កលក្ខណៈងាយស្រួលដល់ស្ថាប័នអនុវត្តឱ្យដំណើរការអនុវត្តដោយបង្ខំឱ្យមានភាពរលូន និងទទួលបានជោគជ័យ។

**កថាភាគទី៣. ភាពគ្រប់គ្រាន់នៃឯកសារ**

ជាធម្មតា ដើម្បីអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុទៅបានវាទាមទារឱ្យមានឯកសារភ្ជាប់គ្រប់គ្រាន់។ ដូច្នេះ អ្នកដាក់ពាក្យសុំត្រូវចងក្រង ឬ ប្រមូលឯកសារឱ្យបានគ្រប់គ្រាន់សម្រាប់ធានាដល់កិច្ចដំណើរការនៃការអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំ។ តើឯកសារភ្ជាប់ទាំងនោះត្រូវមានអ្វីខ្លះ? នៅក្នុងសំណុំឯកសារនៃពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុគេត្រូវមានភ្ជាប់មកជាមួយនូវលិខិតអនុវត្ត ដូចដែលមានចែងនៅ

ក្នុងមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវ៖ លិខិតបញ្ជាក់ពីការចូលជាស្ថាពរនៃលិខិតអនុវត្ត រូបមន្តអនុវត្ត និងលិខិតបញ្ជាក់អំពីសិទ្ធិតំណាងដោយអាណត្តិ វិក័យប័ត្របង់ពន្ធ និង ឯកសារសំខាន់ផ្សេងៗទៀត ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់គូភាគី និងអត្តសញ្ញាណរបស់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដូចនេះ ប្រសិនបើមានការខ្វះខាតនូវឯកសារណាមួយ ដូចជាលិខិតអនុវត្ត ឬ រូបមន្តអនុវត្ត ឬ លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃលិខិតអនុវត្តជាដើមនោះ ស្ថាប័នអាជ្ញាសាលា នឹងមិនអាចធ្វើការអនុវត្តបានទេ ហេតុនេះហើយ អ្នកដាក់ពាក្យសុំអនុវត្តដោយបង្ខំត្រូវស្វែងរកឯកសារមកបង្គ្រប់នីតិវិធីដើម្បីឱ្យស្ថាប័នអាជ្ញាសាលាអាចអនុវត្តបាន។

**កថាភាគទី៤. ពន្ធដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ**

ដើម្បីអាចអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុបាន ម្ចាស់បំណុលត្រូវបង់ពន្ធដាក់ពាក្យសុំអនុវត្តដោយបង្ខំ[40]។ ប៉ុន្តែ ក្នុងករណីដែលការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនេះត្រូវធ្វើទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំ តាមបញ្ញត្តិដែលមានកំណត់ក្នុងមាត្រា ៣៧២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះ នៅក្នុងករណីនេះ គេត្រូវយកប្រការ១៣ នៃប្រកាសលេខ ៣០ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌មកអនុវត្តវិញ។ នៅក្នុងប្រកាសលេខ ៣០ នេះបានបញ្ញត្តិថា៖ ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ៥០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅ។

**កថាភាគទី៥. ការបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុន**

លិខិតអនុវត្ត ដែលជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត នៅមុនពេលចាប់ផ្តើមការអនុវត្ត ឬ យ៉ាងយូរបំផុតស្របពេលជាមួយនឹងការចាប់ផ្តើមការអនុវត្ត[41]។ ក្នុងករណីនេះមានន័យថា ដើម្បីអាចឱ្យការអនុវត្តដោយបង្ខំអាចប្រព្រឹត្តទៅបាន ស្ថាប័នអនុវត្តត្រូវធ្វើការបញ្ជូនលិខិតអនុវត្តនេះ ទៅកូនបំណុលនៃការអនុវត្តជាមុន ដើម្បីជូនដំណឹងទៅកូនបំណុលនៃការអនុវត្តថា នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនឹងចាប់ផ្តើមចំពោះអចលនវត្ថុរបស់គាត់ ហើយក៏ក្នុងគោលបំណងផ្តល់ឱកាសឱ្យកូនបំណុលធ្វើការការពារខ្លួនផងដែរ។ នៅក្នុងករណីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ចាំបាច់គេត្រូវធ្វើការបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុនតាមមាត្រា ៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះពេលវេលាជាក់លាក់នៃការបញ្ជូនវិញ គឺមិនមានការកំណត់ច្បាស់លាស់នោះទេ ដូច្នេះអាជ្ញាសាលាគ្រាន់តែអាចធ្វើការ

[40] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៧២ (២)។

[41] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៦០។

បញ្ជូននៅពេលជាមួយគ្នានឹងការចាប់ផ្តើមនៃការអនុវត្តនៅទីកន្លែងដែលត្រូវអនុវត្តនោះក៏បាន។

ចំណែកឯវិធីនៃការអនុវត្តការបញ្ជូនវិញ គេអាចធ្វើការបញ្ជូនដោយអនុវត្តតាមមាត្រា២៤៦ ស្តីពីគោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ។ ស្ថាប័នដែលធ្វើការបញ្ជូន គឺមានមន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន និង មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូនគឺ ក្រឡាបញ្ជី។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានដូចជា មន្ត្រីប៉ុស្តិ៍ប្រៃសនីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី ជាដើម[42]។ មុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺការបញ្ជូនដាក់លាក់ចំពោះជនដែលត្រូវទទួល ការធ្វើរបាយការណ៍អំពីការបញ្ជូន ហើយដាក់របាយការណ៍នោះទៅតុលាការជាដើម[43]។ ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់[44] ។

**កថាភាគទី៦. ការបង់សោហ៊ុយនៃការអនុវត្តជាមុន**

ដើម្បីអាចឱ្យស្ថាប័នអនុវត្តអាចធ្វើការអនុវត្តដោយបង្ខំបាន ទាមទារឱ្យម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់សោហ៊ុយសម្រាប់ការអនុវត្តជាមុន បើមិនដូច្នេះទេ ស្ថាប័នអនុវត្តមិនអាចធ្វើការអនុវត្តបានទេ។ បើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ អាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបានដោយដីកាសម្រេច ហើយដីកាសម្រេចនេះអាចប្តឹងជំទាស់បាន[45]។ មានន័យថា អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកក្នុងការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ ដើម្បីចាត់ចែងកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំនេះ។ ប៉ុន្តែ ចំពោះសោហ៊ុយចាំបាច់ ដើម្បីចាត់ចែងកិច្ចការ ដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់តុលាការត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ។ ចំពោះកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឬ អាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំ សាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឬ អាជ្ញាសាលានោះស្ថិតនៅក្រោម អាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននូវសោហ៊ុយចាំបាច់ ដើម្បីចាត់ចែងកិច្ចការនោះ តាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ហើយក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបង់ជាមុននូវចំនួនទឹកប្រាក់ ដែលបានកំណត់ដោយតុលាការទេ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឬ អាជ្ញាសាលា អាចលើកចោលពាក្យសុំនោះបាន។ សោហ៊ុយសម្រាប់ការអនុវត្តជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត[46]។ សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំជាពន្ធដែលម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំចាច់ក្នុងការបញ្ជូន

[42] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ២៤៦។

[43] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ២៥៤។

[44] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ២៤៧ (២)។

[45] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៧៥។

[46] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៧៦ (១)។

ឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀត ដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ។ តើអ្វីខ្លះជាសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ? តាមក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់ថាអ្វីខ្លះជាសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំនោះទេ ហើយក៏មិនបានកំណត់នូវចំនួនទឹកប្រាក់នៃការបង់នោះដែរ។ ប៉ុន្តែនៅក្នុងប្រការ១៤ នៃប្រកាសលេខ៣០ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ បានកំណត់យ៉ាងច្បាស់លាស់ពីខ្លឹមសារនៃការចំណាយ ដែលអាជ្ញាសាលាត្រូវយកមកអនុវត្ត។ ដូច្នេះសោហ៊ុយទាំងអស់នោះរួមមានដូចជា៖

ក-សោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅ សម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

ខ-សោហ៊ុយសម្រាប់ការផ្ញើឯកសារ ទូរស័ព្ទ និង ទូរសារ ជាអាទិ៍។

គ-សោហ៊ុយសម្រាប់ការជូនដំណឹងជាសាធារណៈ។

ឃ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់ អ្នកសង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ (អ្នកសង្កេតការណ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ង-កម្រៃសម្រាប់អ្នកបច្ចេកទេស ឬ កម្មករ។

ច-សោហ៊ុយសម្រាប់ការដឹកជញ្ជូន ថែរក្សា និង គ្រប់គ្រងវត្ថុ។

ឆ-សោហ៊ុយសម្រាប់ការប្រមូលផល។

ជ-សោហ៊ុយសម្រាប់ការទទួលលិខិតបញ្ជាក់ពីស្ថាប័នសាធារណៈ។

ឈ-សោហ៊ុយសម្រាប់ថត និង ផ្តិតរូបថក ដើម្បីថតស្ថានភាពបច្ចុប្បន្ននៃវត្ថុ។

ញ-សោហ៊ុយ សម្រាប់ការធ្វើលិខិតបញ្ជាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី៩ នៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សោហ៊ុយស្នាក់នៅ និង កម្រៃសម្រាប់អ្នកវាយតម្លៃ។

ឋ-សោហ៊ុយធ្វើលិខិតរាយការណ៍ដែលត្រូវដាក់ជូនទៅតុលាការអនុវត្ត។

ឌ-សោហ៊ុយចាំបាច់សម្រាប់ការលក់តាមវិធីផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់។

## ផ្នែកទី៣. នីតិវិធីត្រៀមមុនពេលចុះអនុវត្ត

### កថាភាគទី១. ការកំណត់សមាសភាពដែលត្រូវចូលរួមអនុវត្ត

មុនពេលចុះអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលាត្រូវគិតគូរ និង កំណត់អំពីសមាសភាពដែលត្រូវចូលរួម ពីព្រោះការកំណត់នេះវាជាប់ទាក់ទងទៅនឹងការចំណាយសោហ៊ុយក្នុងការអនុវត្ត។ នៅក្នុងការអនុវត្តជាក់ស្តែង ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ សមាសភាពដែលត្រូវចូលរួមអាចមាន អាជ្ញាធរ

រាជធានី/ខេត្ត និងអាជ្ញាធរក្រុង/ស្រុក/ខណ្ឌ និងអាជ្ញាធរមូលដ្ឋាន(ឃុំ-សង្កាត់)។ ប៉ុន្តែ ឆ្លងតាមរយៈការអនុវត្តជាក់ស្តែងកន្លងមក គេកម្រឃើញអាជ្ញាធរថ្នាក់រាជធានី/ខេត្ត ចូលរួមក្នុងការអនុវត្តណាស់ ទាល់តែទំហំនៃសាច់រឿងនោះមានសភាពធ្ងន់ធ្ងរ ហើយជាប់ពាក់ព័ន្ធទៅគូភាគីច្រើនដូចជា មានកូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការអនុវត្តច្រើនជាដើម។ ម្យ៉ាងវិញទៀត ករណីរឿងក្តីអនុវត្តនេះ មានទំហំធំដែលអាចមានការប្រឆាំងខ្លាំង ទើបមានការចូលរួមច្រើនពីអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់ថ្នាក់។

### ១.១. អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្នុងករណីនេះ មន្ត្រីដែលមកពីសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលអាចជា អភិបាល ឬ អភិបាលរងខេត្ត ក្រុង ស្រុក ខណ្ឌ មន្ត្រីមកពីមន្ទីរសុរិយោដីរាជធានីខេត្ត ដែលអាចជាប្រធាន ឬ អនុប្រធានមន្ទីរសុរិយោដី ឬ មន្ត្រីជំនាញបច្ចេកទេសផ្នែកភូមិបាលសម្រាប់ធ្វើការវាស់វែង និង ស្នងការ ឬ ស្នងការរងរាជធានីខេត្ត អធិការ ឬ អធិការរងក្រុង ស្រុក ឬ មន្ត្រីជំនាញផ្សេងៗ ខាងនគរបាលថ្នាក់ខេត្ត ឬ មេបញ្ជាការ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ក្រុង ស្រុក ឬ មន្ត្រីអាវុធហត្ថក្រោមចំណុះជាដើម។

### ១.២. អាជ្ញាធរមូលដ្ឋាន(ឃុំ សង្កាត់)

ក្នុងករណីនេះ អាជ្ញាធរមូលដ្ឋានគឺជាតួអង្គមួយសំខាន់ដែលនៅជាមួយនឹងប្រជាពលរដ្ឋផ្ទាល់ ដូចនេះ អាជ្ញាធរកម្រិតនេះមានតួនាទីសំខាន់ក្នុងការចង្អុលបង្ហាញអំពីទីតាំងជាក់ស្តែងនៃអចលនវត្ថុ និង តម្កល់ទុកឯកសារសំខាន់ៗ ដែលពាក់ព័ន្ធជាក់ស្តែងនឹងអចលនវត្ថុដែលត្រូវអនុវត្តការប្រគល់នេះ។ អាជ្ញាធរមូលដ្ឋានកម្រិតនេះអាចរួមមានដូចជា៖ មេឃុំ-ចៅសង្កាត់ ចៅសង្កាត់រង ជំទប់ឃុំ នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ មេភូមិ អនុប្រធានភូមិ មន្ត្រីរដ្ឋបាលថ្នាក់ឃុំ-សង្កាត់ជាដើម។ ការកំណត់អំពីសមាសភាពនៃការចូលរួមអនុវត្តនេះ គឺវាអាស្រ័យទៅលើទំហំ និងទ្រង់ទ្រាយនៃការអនុវត្ត បើការអនុវត្តនេះវាមានទំហំធំនោះត្រូវការកម្លាំងដែលត្រូវចូលរួមនោះច្រើន ប៉ុន្តែប្រសិនបើការអនុវត្តនោះមានទំហំតូចនោះ ត្រូវការប្រើកម្លាំងចូលរួមតិចដែរ ដូចនេះ ការកំណត់សមាសភាពនៃការចូលរួមនេះ គឺអាស្រ័យទៅលើទិដ្ឋភាពជាក់ស្តែងនៃអង្គហេតុនីមួយៗ។

## កថាភាគទី២. លិខិតរដ្ឋបាលដែលត្រូវប្រើប្រាស់មុនពេលចុះអនុវត្ត

នៅក្នុងនីតិវិធីអនុវត្តជាក់ស្តែង មុនពេលចុះអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលាត្រូវធ្វើលិខិតរដ្ឋបាល ដើម្បីទំនាក់ទំនងជាមួយនឹងអាជ្ញាធរសាធារណៈ និងអាជ្ញាធររដ្ឋបាល ព្រមទាំងមន្ត្រីនគរបាលយុត្តិធម៌គ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ។ លិខិតរដ្ឋបាលនេះ មានសារៈសំខាន់ណាស់សម្រាប់បង្ហាញអំពីខ្លឹមសារសំខាន់ៗនៃលិខិតអនុវត្ត ពេលវេលា ទីកន្លែងដែលត្រូវអនុវត្តកម្មវត្ថុដែលត្រូវអនុវត្ត និងសមាសភាពនៃគណៈកម្មការដែលត្រូវចូលរួមក្នុងការអនុវត្ត។ ការចេញលិខិតរដ្ឋបាលនេះ គឺធ្វើឡើងក្នុងគោលបំណងស្នើឱ្យមានការចូលរួមសហការពីអាជ្ញាធរសាធារណៈគ្រប់លំដាប់ថ្នាក់ ព្រមទាំងជាការស្នើសុំកេណ្ឌកម្លាំងសាធារណៈ

ជាមុន ដើម្បីសម្រួលដល់ការអនុវត្តនាពេលខាងមុខផងដែរ។ ជាការអនុវត្តជាក់ស្តែង នៅក្នុងនីតិវិធីត្រៀមមុនពេលចុះអនុវត្ត អាជ្ញាសាលា អាចចេញលិខិតរដ្ឋបាលមួយចំនួនតាមការចាំបាច់ដូចជា៖ លិខិតស្នើសុំកម្លាំងចូលសហកាអនុវត្តពីអាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ លិខិតស្នើ និងលិខិតជូនដំណឹងទៅគូភាគីដែលពាក់ព័ន្ធ ដូចជា កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត និង តតិយជនដែលពាក់ព័ន្ធ។ ហើយសុំការឯកភាពពីគណៈបញ្ជាការឯកភាពខេត្ត ករណីតុលាការខេត្ត ដូច្នេះ ការចេញលិខិតរដ្ឋបាលសម្រាប់ទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាននេះ មានសារៈសំខាន់ណាស់សម្រាប់សម្របសម្រួលការងារ មុនពេលចុះអនុវត្ត និង ត្រៀមសម្រាប់ពេលអនុវត្តនាពេលអនុវត្តឱ្យមានដំណើការរលូនទៅមុខបានល្អ។

**កថាភាគទី៣. ការកោះហៅកូនបំណុលមកចរចាក្រៅផ្លូវការ**

ជាបច្ចេកទេសនៃការអនុវត្តជាក់ស្តែង មុនពេលចុះអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ព្រះរាជអាជ្ញារងដែលជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា តែងតែធ្វើលិខិតកោះហៅកូនបំណុលនៃការអនុវត្តមកចរចាគ្នាម្តងជាពីរដង ដើម្បីធ្វើការសម្របសម្រួលឱ្យកូនបំណុលនៃការអនុវត្តយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត ដើម្បីកុំឱ្យមានការអនុវត្តដោយបង្ខំកើតឡើង ព្រោះវាអាចជាមធ្យោបាយមួយដែលអាចធ្វើឱ្យចំណេញពេលវេលា និងថវិកាចំពោះម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត។ ដំណាក់កាលនេះ អាចជាដំណាក់កាលចុងក្រោយ នៃការជួបចរចាជាមួយកូនបំណុលនៃការអនុវត្ត ហើយដំណាក់កាលនេះ អាចផ្តល់លទ្ធផលល្អសម្រាប់ភាគីទាំងសងខាង ព្រោះការចរចានេះ ប្រសិនបើកូនបំណុលនៃការអនុវត្តយល់ព្រមអនុវត្តដោយស្ម័គ្រចិត្តតាមការសម្របសម្រួលរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ការលំបាកទាំងឡាយដែលអាចនឹងកើតមានក្នុងពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុអាចនឹងត្រូវបានកាត់បន្ថយ។

ក្នុងករណីនេះ ប្រសិនបើកូនបំណុលនៃការអនុវត្តយល់ព្រមសងបំណុលដោយស្ម័គ្រចិត្តទៅម្ចាស់បំណុលនៃការអនុវត្តក្នុងដំណាក់កាលនៃការចរចាចុងក្រោយនេះ នោះមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការអនុវត្តដោយស្ម័គ្រចិត្ត ហើយបង្គាប់ឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើពាក្យសុំដកពាក្យសុំអនុវត្តដោយបង្ខំ ហើយបន្ទាប់មកទៀតត្រូវធ្វើកំណត់ហេតុមួយ ដើម្បីបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ដូច្នេះ នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុដែលនឹងត្រូវធ្វើនៅពេលខាងមុខនោះ នឹងត្រូវបានបញ្ចប់ដោយការព្រមព្រៀងសងបំណុលដោយស្ម័គ្រចិត្តរបស់កូនបំណុលនៃការអនុវត្ត ចំពោះម្ចាស់បំណុលនៃការអនុវត្តដោយមានការសម្របសម្រួលពីស្ថាប័នអនុវត្ត។

**កថាភាគទី៤. ការកោះហៅម្ចាស់បំណុលមកពិភាក្សាអំពីការចំណាយក្នុងការអនុវត្ត**

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុអាចធ្វើទៅបាន ទាល់តែម្ចាស់បំណុលនៃការអនុវត្តបានបង់កម្រៃ និងសោហ៊ុយផ្សេងៗដែលចាំបាច់សម្រាប់ការអនុវត្តជាមុន ព្រោះសោហ៊ុយនៃការអនុវត្ត គឺជាការចំណាយ

ដ៏សំខាន់សម្រាប់ធានានូវដំណើរការនៃការអនុវត្តនីតិវិធី។ ក្នុងការអនុវត្តជាក់ស្តែង សោហ៊ុយនៃការអនុវត្តត្រូវចំណាយទៅលើមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ម្ហូបអាហារ ដែលស្ថាប័នអនុវត្តត្រូវការក្នុងពេលអនុវត្ត ព្រមទាំងការចំណាយទាំងឡាយសម្រាប់កងកម្លាំងសាធារណៈ និងអាជ្ញាធរពាក់ព័ន្ធដែលបានចូលរួម។ ជាមួយគ្នានេះដែរ នៅក្នុងប្រកាសលេខ៣០ របស់ក្រសួងយុត្តិធម៌ក៏មានបញ្ញត្តិមួយដែលមានចែងអំពី សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ[47] ដែលក្នុងបញ្ញត្តិនេះ អ្នកដាក់ពាក្យសុំអនុវត្តដោយបង្ខំត្រូវទទួលបន្ទុកក្នុងការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ ដើម្បីចាត់ចែងកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំនេះ។ ប៉ុន្តែប្រសិនបើសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលតុលាការឱ្យអាជ្ញាសាលាចាត់ចែងដោយផ្ទាល់ តុលាការត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ។

ដូច្នេះ សោហ៊ុយដែលត្រូវបង់មុនពេលចុះអនុវត្តមានសារៈសំខាន់ណាស់ សម្រាប់យកទៅប្រើប្រាស់ក្នុងពេលអនុវត្តនាពេលខាងមុខ ដែលសោហ៊ុយនេះ អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកបង់ឱ្យស្ថាប័នអនុវត្ត មុនពេលដែលនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុបានមកដល់។ នៅក្នុងការអនុវត្តជាក់ស្តែង អ្នកដាក់ពាក្យសុំត្រូវមកពិភាក្សាអំពីការចំណាយនេះជាមួយនឹងអាជ្ញាសាលាដោយផ្ទាល់ ឬ អាចឱ្យមេធាវីតំណាងដោយអាណត្តិមកជំនួសក៏បាន ពីព្រោះថាប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយនេះទេ ស្ថាប័នអនុវត្តមិនអាចចុះអនុវត្តដោយបង្ខំបានទេ។

**កថាភាគទី៥. ការចុះទៅពិនិត្យស្ថានភាពនៃទីតាំងដែលត្រូវអនុវត្តជាមុន**

ការចុះទៅពិនិត្យស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និង ទីតាំងដែលត្រូវអនុវត្ត គឺជាបច្ចេកទេសនៃការអនុវត្តជាក់ស្តែងរបស់អាជ្ញាសាលា ហើយនៅក្នុងនីតិវិធីនេះពុំមានបញ្ញត្តិណាមួយនៅក្នុងច្បាប់ចែងអំពីសកម្មភាពការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុឡើយ។ ការធ្វើសកម្មភាពបែបនេះ គឺវាកើតចេញមកពីបទពិសោធន៍ជាក់ស្តែង ដែលអ្នកទទួលបន្ទុកកិច្ចការអនុវត្តបានជួបប្រទះនាពេលកន្លងមក។ ការធ្វើសកម្មភាពបែបនេះមុនពេលចុះអនុវត្ត វាគឺជាសកម្មភាពត្រៀមមួយដ៏សំខាន់ ព្រោះវាអាចជួយឱ្យអាជ្ញាសាលាមានភាពច្បាស់លាស់ចំពោះកម្មវត្ថុនៃការអនុវត្ត និងទីតាំងដែលត្រូវអនុវត្ត។ ជាក់ស្តែង អាជ្ញាសាលាអាចមានពេលវេលាគ្រប់គ្រាន់សម្រាប់ផ្ទៀងផ្ទាត់ឯកសារ ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់អចលនវត្ថុជាមួយនឹងទីតាំងជាក់ស្តែង ដែលអចលនវត្ថុតាំងនៅ និងស្ថានភាពនៃការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ឬ មានតតិយជនណាមួយកំពុងកាន់កាប់ ពីព្រោះប្រសិនបើយើងមិនបានផ្ទៀងផ្ទាត់ឱ្យបានគ្រប់ជ្រុងជ្រោយទេ វាអាចនឹងកើតមាននូវការភ័ន្តច្រលំជាយថាហេតុណាមួយ ដែលបង្កបានជាឧបសគ្គ ឬ ភាពស្មុគស្មាញណាមួយចំពោះការអនុវត្ត ដែលនឹងត្រូវធ្វើ

[47] ប្រកាសលេខ៣០ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា, ១៩ កក្កដា ២០០៧ (ភ្នំពេញ៖ក្រសួងយុត្តិធម៌), ប្រការ ១៤។

នាពេលខាងមុខ។

លើសពីនេះទៅទៀត ការចុះទៅពិនិត្យស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និងទីតាំងអនុវត្តនេះអាចផ្តល់ជាឱកាសល្អសម្រាប់ស្ថាប័នអនុវត្ត ក្នុងការទំនាក់ទំនងជាមួយនឹងអាជ្ញាធរជាមុនដោយផ្ទាល់ មានន័យថា យ៉ាងហោចណាស់អាជ្ញាសាលាមានឱកាសពីរដង ក្នុងការទំនាក់ទំងជាមួយនឹងអាជ្ញាធរសាធារណៈ (លើកទីមួយ គឺការទំនាក់ទំនងតាមរយៈលិខិតរដ្ឋបាល និង លើកទីពីរ គឺការទំនាក់ទំនងដោយផ្ទាល់)។ ដូចដែលយើងបានដឹងស្រាប់ហើយថា ការប្រើប្រាស់លិខិតរដ្ឋបាលសម្រាប់ការទំនាក់ទំនង វាគឺជាការទំនាក់ទំនងផ្លូវការមួយដ៏ល្អ ប៉ុន្តែក៏មានគុណវិបត្តិផងដែរ កាលណាលិខិតនោះបានបញ្ជូនទៅយឺតពេល ឬ ចំណាត់ការលិខិតនោះ មានការយឺតយ៉ាវនៅក្នុងស្ថាប័នអ្នកទទួល ឬ មានការបាត់បង់លិខិតនោះដោយសារករណីណាមួយនោះនឹងធ្វើឱ្យមានការលំបាកដល់អាជ្ញាសាលា ដូច្នេះ ការទំនាក់ទំនងដោយផ្ទាល់នេះ ផ្តល់លទ្ធភាពល្អសម្រាប់សម្របសម្រួលកិច្ចការអនុវត្តឱ្យមានដំណើរការល្អ។ ទន្ទឹមនឹងនេះផងដែរ ការធ្វើសកម្មភាពបែបនេះ វាបានបង្កលក្ខណៈងាយស្រួលដល់ស្ថាប័នអនុវត្តស្ទាបស្ទង់សមាសភាពគណៈកម្មការដែលអាចនឹងចូលរួមក្នុងការអនុវត្តបាន ព្រមទាំងវាយតម្លៃនូវលទ្ធភាពនៃកំលាំងប្រឆាំងរបស់កូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលនឹងអាចកើតមានឡើងក្នុងពេលអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុដែលខ្លួននឹងធ្វើនាពេលខាងមុខនោះបាន។

**កថាភាគទី៦. កំណត់កាលបរិច្ឆេទ និង ជូនដំណឹងអំពីការអនុវត្ត**

អាជ្ញាសាលា ត្រូវកំណត់កាលបរិច្ឆេទនៃការចុះអនុវត្តឱ្យបានច្បាស់លាស់ ព្រមទាំងត្រូវជូនដំណឹងអំពីការចុះអនុវត្តនេះទៅគ្រប់ភាគីទាំងអស់ដែលពាក់ព័ន្ធ។ ការកំណត់កាលបរិច្ឆេទនេះ មានសារៈសំខាន់ណាស់សម្រាប់ធានានូវដំណើរការនៃការអនុវត្តឱ្យមានភាពរលូនទៅមុខដោយគ្មានឧបសគ្គ។ ករណីនេះ អាជ្ញាសាលាគួរចៀសវាងការចុះអនុវត្តនូវថ្ងៃឈប់សម្រាក ឬ ថ្ងៃណាមួយដែលអាជ្ញាធរសាធារណៈមិនអាចមានលទ្ធភាពចូលរួមអនុវត្តបាន។ ប្រសិនបើការអនុវត្តដោយបង្ខំនោះធ្វើតាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ[48] នោះអាជ្ញាសាលាអាចបំពេញមុខនាទីរបស់ខ្លួនក្នុងថ្ងៃឈប់សម្រាក ឬ ថ្ងៃអាទិត្យនោះបាន។ លើសពីនេះទៅទៀត អាជ្ញាសាលាត្រូវធ្វើការជូនដំណឹងអំពីការអនុវត្តនេះទៅគ្រប់ភាគីដែលពាក់ព័ន្ធ និងអ្នកដែលទទួលផលប្រយោជន៍ទាំងឡាយពីការអនុវត្ត។ ជាពិសេសនោះ គឺការបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុន[49]ជាដើម ពីព្រោះការអនុវត្តដោយបង្ខំអាចចាប់ផ្តើមអនុវត្តបានតែក្នុងករណីដែលឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្តីសម្រេចដែលនឹង

[48] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៤០។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៦០។

ក្លាយជាលិខិតអនុវត្តនៅ ពេលចូលជាស្ថាពរត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន។ ហេតុដូច្នេះហើយ ការធ្វើសកម្មភាពដូចនេះ វាហាក់ដូចជាការជូនដំណឹងទៅកូនបំណុលនៃការអនុវត្តជាមុនផងដែរ។

# ជំពូកទី៣
# នីតិវិធីអនុវត្ត និង ក្រោយពេលអនុវត្ត
# ការប្រគល់អចលនវត្ថុ

# ជំពូកទី៣
# នីតិវិធីអនុវត្ត និង ក្រោយពេលអនុវត្តការប្រគល់អចលនវត្ថុ

នៅក្នុងជំពូកនេះ នឹងធ្វើការសិក្សាទៅលើលំហូរនៃនីតិវិធីអនុវត្ត (ផ្នែកទី១) និង ក្រោយអនុវត្តការប្រគល់អចលនវត្ថុ (ផ្នែកទី២) ដែលចំណុចទាំងអស់នេះ នឹងធ្វើការសិក្សាដូចខាងក្រោម។

## ផ្នែកទី១. នីតិវិធីនៃការចុះអនុវត្តការប្រគល់អចលនវត្ថុ

### កថាភាគទី១. កំណត់ទីតាំងដើម្បីជួបជុំគណៈកម្មការ

នៅក្នុងការអនុវត្តជាក់ស្តែង មុននឹងចូលទៅកាន់ទីតាំងនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលាតែងតែកំណត់ពេលវេលា និងទីកន្លែងដើម្បីត្រៀមជួបប្រជុំគ្នាមុនពេលចុះអនុវត្ត។ គេអាចកំណត់យកទីតាំងណាមួយ ដើម្បីប្រជុំគណៈកម្មការនៃការអនុវត្ត ជាក់ស្តែងគេអាចជ្រើសរើសយកសាលាខណ្ឌ ឬ សាលាសង្កាត់ណាមួយ ដែលមានទីតាំងសមរម្យជិតទីកន្លែងអនុវត្ត ដើម្បីពិភាក្សាគ្នាមុនពេលចាប់ផ្តើមអនុវត្ត ហើយក្នុងពេលនោះដែរ ដើម្បីឱ្យការងារមានភាពឆាប់រហ័ស គេអាចធ្វើបញ្ជីស្រង់វត្តមានសមាសភាពមន្ត្រីដែលបានចូលរួម។ ក្នុងករណីនេះ ប្រសិនបើមានមន្ត្រីបច្ចេកទេសគ្រប់ជំនាញបានចូលរួមនោះ គេនឹងអាចចុះអនុវត្តបាន ប៉ុន្តែប្រសិនបើគ្មានការចូលរួមសហការពីមន្ត្រីជំនាញ និង អាជ្ញាធរមូលដ្ឋានទេនោះគេមិនអាចអនុវត្តបានទេ។ ដូច្នេះ ការស្រង់វត្តមានអ្នកដែលចូលរួមនេះមានសារៈសំខាន់ណាស់សម្រាប់អាជ្ញាសាលា ពីព្រោះវាគឺជាដំណាក់កាលដំបូងដែលកំណត់ថា តើការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុអាចធ្វើទៅរួចឬទេ។

ជាមួយគ្នានេះដែរ ការជួបជុំគណៈកម្មការនេះ គឺជាពេលវេលាដ៏ល្អប្រសើរសម្រាប់អាជ្ញាសាលា ក្នុងការពន្យល់និងបញ្ជាក់ឡើងវិញអំពីខ្លឹមសារនៃការអនុវត្ត និងខ្លឹមសារនៃលិខិតអនុវត្ត ពីព្រោះពេលខ្លះមន្ត្រីដែលចូលរួមពួកគេអាចមិនសូវយល់ ឬ មិនយល់អំពីខ្លឹមសារនៃសេចក្តីសម្រេចដែលតុលាការបានចេញ។ ដូច្នេះ អាជ្ញាសាលាត្រូវធ្វើការបកស្រាយនិងបញ្ជាក់បន្ថែមម្តងទៀត ដើម្បីចៀសវាងការអនុវត្តមានលក្ខណៈខុសឆ្គង ឬមិនច្បាស់លាស់ ព្រោះកាលណាមានការអនុវត្តខុសឆ្គង ឬ មិនត្រឹមត្រូវតាមខ្លឹមសារនៃលិខិតអនុវត្តនោះ អ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងដំណើរការនៃការអនុវត្តនីតិវិធីនេះ គឺជាអាជ្ញាសាលា ជាពិសេសនៅពេលមានការប្តឹងតវ៉ាណាមួយកើតឡើង។ ទន្ទឹមនឹងនេះ ការជួបប្រជុំគ្នាមុនពេលចុះអនុវត្តនេះ គឺជាពេលវេលាមួយដ៏សមរម្យផងដែរសម្រាប់អាជ្ញាសាលាធ្វើការបែងចែក និងកំណត់ទិសដៅការងារដល់មន្ត្រីដែលចូលរួមក្នុងការអនុវត្តនីតិវិធី ពីព្រោះកាលណាយើងកំណត់មុខសញ្ញាការងារបានច្បាស់លាស់សម្រាប់អ្នកចូលរួមអនុវត្ត នោះវាអាចធ្វើឱ្យការអនុវត្តការងារមានភាពរលូន ឆាប់រហ័ស និងមានអ្នកទទួលខុសត្រូវច្បាស់លាស់ក្នុងកិច្ចការនីមួយៗ ហើយនៅពេលណាមានបញ្ហាណាមួយកើតមានឡើងជាយថាហេតុ យើងអាចស្វែងរកដំណោះស្រាយបញ្ហាបានឆាប់រហ័ស។

**កថាភាគទី២. ការសម្របសម្រួលឱ្យកូនបំណុលយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត**

ទោះបីជាឈានដល់ដំណាក់កាលចុងក្រោយ នៃការចាប់ផ្ដើមនីតិវិធីត្រៀមសម្រាប់ការអនុវត្តក៏ដោយ ក៏ការសម្របសម្រួលឱ្យកូនបំណុលយល់ព្រមអនុវត្តដោយស្ម័គ្រចិត្តនៅតែមិនទាន់បញ្ចប់នៅឡើយ ពីព្រោះនេះគឺជាវិធីសាស្ត្រទន់ភ្លន់មួយសម្រាប់អ្នកអនុវត្ត[50]។ ករណីនេះមានន័យថា អាជ្ញាសាលាត្រូវមានភាពអត់ធ្មត់ ហើយព្យាយាមបញ្ចុះបញ្ចូលកូនបំណុលនៃការអនុវត្តឱ្យយល់ព្រមអនុវត្តដោយស្ម័គ្រចិត្តម្តងទៀត ដើម្បីអាចចៀសវាងបាននូវការប្រទូសរ៉ាយគ្នា ក្នុងពេលអនុវត្តនៅទីកន្លែងជាក់ស្តែង។ ជាបច្ចេកទេសនៃការអនុវត្ត អាជ្ញាសាលាអាចអញ្ជើញកូនបំណុលមកទីតាំងជួបជុំរបស់គណៈកម្មការ ហើយបើកលទ្ធភាពឱ្យកូនបំណុលនិងម្ចាស់បំណុលធ្វើការចរចាគ្នាម្តងទៀត ដោយមានការសម្របសម្រួលពីសមាជិកនៃគណៈកម្មការ និង អាជ្ញាសាលា។ ក្នុងករណីនេះ ប្រសិនបើកូនបំណុលយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុអនុវត្តដោយស្ម័គ្រចិត្ត ហើយអានឱ្យអ្នកដែលចូលរួមបានស្តាប់ ហើយបង្គាប់ឱ្យម្ចាស់បំណុលនៃការអនុវត្តដកពាក្យសុំអនុវត្តដោយបង្ខំដោយបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំ។ ប្រសិនបើកូនបំណុលមិនព្រមអនុវត្តដោយស្ម័គ្រចិត្តទេនោះ អាជ្ញាសាលាត្រូវធ្វើការអនុវត្តដោយបង្ខំ ហើយចុះទៅកាន់ទីតាំងអនុវត្តការប្រគល់ និងចាត់ចែងអនុវត្តនីតិវិធីនៃការអនុវត្តការប្រគល់អចលនវត្ថុ។

**កថាភាគទី៣. ការចុះទៅដល់ទីតាំងដែលត្រូវអនុវត្ត**

ក្នុងការចុះទៅកាន់ទីតាំងដែលត្រូវអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវមានភាពរហ័សរហួន និងឈ្លាសវៃជាមួយនឹងឧបសគ្គ និងការប្រឆាំងនានាដែលអាចកើតមានជាយថាហេតុ។ ប៉ុន្តែ អ្វីដែលត្រូវធ្វើជាអាទិភាពមុនគេនោះគឺ ការកំណត់អំពីតួនាទី និងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកការងារនីមួយៗឱ្យបានច្បាស់លាស់ ជាពិសេស គឺពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់នៃទីកន្លែងដែលត្រូវអនុវត្ត ការពារសុវត្ថិភាពដល់អ្នកដែលចូលរួមអនុវត្ត និងសុក្រឹត្យភាពនៃការវាស់វែងអចលនវត្ថុរបស់មន្ត្រីជំនាញសុរិយោដី ពីព្រោះអាជ្ញាសាលាគឺជាអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់ជាងគេក្នុងការអនុវត្តនីតិវិធីរបស់ខ្លួន។ មុនពេលចាប់ផ្តើមអនុវត្ត អាជ្ញាសាលា ត្រូវអានខ្លឹមសារនៃលិខិតអនុវត្តឱ្យអ្នកដែលពាក់ព័ន្ធ និងអ្នកដែលចូលរួមអនុវត្តបានស្តាប់ម្តងទៀត ចាត់ទុកដូចជាការជូនដំណឹងមុនពេលអនុវត្តការប្រគល់អចលនវត្ថុ។

**កថាភាគទី៤. ករណីមានឧបសគ្គកើតឡើងក្នុងពេលអនុវត្ត**

**៤.១. ករណីមានការប្រឆាំងកើតឡើង**

ក្នុងករណីដែលមានការប្រឆាំងកើតមានឡើង អាជ្ញាសាលាត្រូវមានភាពឈ្លាសវៃ ហើយពិនិត្យមើល

[50] នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៣៨ (១)។

ទំហំនៃការប្រឆាំងនោះ ព្រមទាំងបញ្ជាកម្លាំងការពារសន្តិសុខ សុវត្ថិភាព ជូនអ្នកចូលរួមអនុវត្ត។ ក្នុងករណីចាំបាច់ បើពិនិត្យឃើញថា មានការខ្វះខាតកម្លាំងសម្រាប់ការអនុវត្តនោះ អាជ្ញាសាលាត្រូវស្នើសុំកម្លាំងសាធារណៈបន្ថែមទៀត ដើម្បីអនុវត្តក្នុងការបំពេញមុខងាររបស់ខ្លួនតាមអំណាចដែលច្បាប់ប្រគល់សិទ្ធិឱ្យ[51]។

ក្នុងករណីនេះ អាជ្ញាសាលាត្រូវពិនិត្យទៅលើស្ថានភាពពីរករណីគឺ បើកម្លាំងប្រឆាំងនោះអាចទប់ទល់បានត្រូវបន្តការអនុវត្តដោយឆាប់រហ័សបំផុត។ ប៉ុន្តែប្រសិនបើកម្លាំងប្រឆាំងនោះមានទំហំធំ ហើយបើបានប្រមាណទៅឃើញថា មិនអាចទប់ទល់បានទេ ត្រូវផ្អាកការអនុវត្តជាបណ្តោះអាសន្នសិន ហើយឈានទៅរកការកំណត់យុទ្ធសាស្ត្រនៃការអនុវត្តជាថ្មីម្តងទៀតនៅពេលក្រោយ។

### ៤.២. ករណីមានអន្តរាគមន៍កើតឡើង

ស្ថាប័នអាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យលើមុខងាររបស់ខ្លួន នៃអំណាចតុលាការ។ អំណាចតុលាការ គឺជាអំណាចឯករាជ្យ[52] ហើយអំណាចនេះ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រពលរដ្ឋ។ ដូច្នេះ អំណាចនេះមិនស្ថិតនៅក្រោមចំណុះរបស់អំណាចដទៃផ្សេងទៀតឡើយ (អំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ) ហេតុនេះហើយ គ្មានស្ថាប័នអំណាចណាមួយអាចធ្វើសេចក្តីបង្គាប់បញ្ជាឱ្យស្ថាប័នតុលាការត្រូវតែធ្វើតាមឡើយ ប៉ុន្តែខ្លឹមសារនេះ វាហាក់ដូចជាមានតែនៅក្នុងទ្រឹស្តីច្បាប់តែប៉ុណ្ណោះ ចំណែកឯការអនុវត្តជាក់ស្តែងវិញ វាហាក់ដូចជានៅឆ្ងាយពីទ្រឹស្តីច្បាប់នេះខ្លាំងណាស់។ នៅក្នុងការអនុវត្តជាក់ស្តែង កិច្ចអន្តរាគមន៍ពីស្ថាប័នអំណាចនីតិប្រតិបត្តិ និងស្ថាប័នអំណាចនីតិបញ្ញត្តិ គឺកំពុងកើតមានជាញឹកញយជាពិសេស គឺក្នុងករណីរឿងក្តីដែលមានប្រភពកើតចេញអ្នកនយោបាយ ឬ អ្នកដែលមានអំណាចក្នុងជួររាជរដ្ឋាភិបាល ក្នុងជួររដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្នុងស្ថាប័នតុលាការខ្លួនឯងផងដែរ។ តាមការពិតទៅការអន្តរាគមន៍នេះ គឺជាសកម្មភាពដែលប្រព្រឹត្តទៅនៅក្រៅច្បាប់ ហើយវាគឺជាសកម្មភាពនៃការរំលោភអំណាចពីសំណាក់បុគ្គលដែលមានអំណាចមានធនធាន និងមានខ្សែស្រឡាយជាមួយអ្នកនយោបាយ។ បើនិយាយអំពីទិដ្ឋភាពផ្លូវច្បាប់ អាជ្ញាសាលាមិនមានអ្វីដែលត្រូវខ្វល់ខ្វាយ និងខ្លាចរអាចំពោះការអន្តរាគមន៍នេះទេ ព្រោះច្បាប់បានប្រគល់សិទ្ធិអំណាចលើការអនុវត្តមុខងាររបស់ខ្លួនដោយឯករាជ្យ ហើយមិនត្រូវស្ថិតក្រោមការបង្ខិតបង្ខំរបស់បុគ្គលណាមួយឡើយ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងវាមិនដូច្នោះទេ កាលណាមានអន្តរាគមន៍ពីស្ថាប័នអំណាច ឬ បុគ្គលមានអំណាចណាមួយ គេតែងតែឃើញមានការផ្អាកការអនុវត្តដោយបង្ខំជានិច្ច ទិដ្ឋភាពនេះហើយដែលជាមូលហេតុចម្បងមួយធ្វើឱ្យអំណាចតុលាការចុះខ្សោយ ព្រោះតែទទួលរងសម្ពាធពីស្ថាប័នអំណាចដទៃៗទៀតនោះ។

[51] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៣៨។

[52] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា ១២៨ ថ្មី។

### ៤.៣. ការសម្រេចផ្អាកការអនុវត្ត

ការផ្អាកការអនុវត្តដោយបង្ខំ សំដៅទៅលើស្ថានភាពដែលស្ថាប័នអនុវត្ត មិនអាចចាប់ផ្ដើម ឬ បន្តការអនុវត្តដោយបង្ខំតាមច្បាប់ទៀតបាន។ ទំហំនៃអានុភាពនៃការផ្អាកប្រែប្រួលទៅតាមមូលហេតុនៃការផ្អាក។ ចំពោះការផ្អាកដែលជាការចាត់ចែងមួយរយៈ ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត[53] ត្រូវបានកម្រិតត្រឹមតែការផ្អាកនូវសកម្មភាពនៃការអនុវត្តដោយបង្ខំដែលជាកម្មវត្ថុនៃការតវ៉ានោះប៉ុណ្ណោះ។ ក្នុងករណីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ប្រសិនបើមានដីកាសម្រេចណាមួយដែលបង្គាប់ឱ្យអាជ្ញាសាលាធ្វើការផ្អាកការអនុវត្តរបស់ខ្លួននោះ អាជ្ញាសាលាត្រូវសម្រេចផ្អាកសកម្មភាពនៃការអនុវត្តរបស់ខ្លួនភ្លាម ហើយរង់ចាំឱ្យមានការសម្រេចជាថ្មីរបស់តុលាការ ទើបអាចធ្វើការអនុវត្តបន្តទៀតបាន[54]។

### ៤.៤. ការសម្រេចលុបចោលការអនុវត្តដោយបង្ខំ

ការលុបចោលការអនុវត្តដោយបង្ខំ មានន័យថា ជាការជម្រះចេញនូវការចាត់ចែងការអនុវត្តទាំងមូល ឬ មួយផ្នែកដែលបានធ្វើរួចហើយដោយស្ថាប័នអនុវត្ត នៅក្នុងដំណើរការនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ។ មូលហេតុនេះហើយ ការលុបចោលការអនុវត្តដោយបង្ខំ ពុំអាចគិតបាននៅមុនពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ ហើយនៅក្រោយការបញ្ចប់នីតិវិធីនីមួយៗនៃការអនុវត្តដោយបង្ខំ ការលុបចោលនូវការចាត់ចែងការអនុវត្ត ដែលធ្វើឡើងនៅក្នុងនីតិវិធីនោះមិនត្រូវបានអនុញ្ញាតទេ។ បើការចាត់ចែងការអនុវត្តនោះ ពុំមានសុពលភាពតាមផ្លូវច្បាប់តាំងពីដំបូងក៏ដោយ ប្រសិនបើវាមានអត្ថិភាពពីខាងក្រៅ វាអាចនឹងត្រូវបានលុបចោល ដើម្បីជម្រះចោលនូវឧបសគ្គដែលអាចនឹងកើតចេញពីការចាត់ចែងនោះ។ លើសពីនេះទៅទៀត ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដកពាក្យសុំឱ្យចាប់ផ្ដើមការអនុវត្តដោយបង្ខំ ឬ លះបង់សិទ្ធិដែលបានទទួលពីការចាត់ចែងការអនុវត្តនោះ[55] នៅមុនពេលបញ្ចប់ការអនុវត្តដោយបង្ខំនោះ ការអនុវត្តដោយបង្ខំ ក៏ត្រូវលុបចោលដែរ។ ដោយសាថា ការលះបង់នេះពុំមែនជាការលះបង់សិទ្ធិទាមទារតាមច្បាប់សារធាតុឡើយ ដូច្នេះ មិនរារាំងម្ចាស់បំណុលនៃការអនុវត្ត មិនឱ្យធ្វើការអនុវត្តដោយបង្ខំម្ដងទៀតនាពេលក្រោយ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដដែល តាមវិធីដដែល ឬតាមវិធីផ្សេងឡើយ។

## ផ្នែកទី២. វិធីអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

### កថាភាគទី១. ករណីអចលនវត្ថុកាន់កាប់ដោយកូនបំណុល

ចំពោះវិធីអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ក្នុងករណីដែលអចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តនោះត្រូវបានកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចត្រូវធ្វើការ

[53] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៨៥។

[54] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៨៣។

[55] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៤១០ (១)។

រំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្តលើវត្ថុនោះ ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបានការកាន់កាប់នោះ[56]។ ដូច្នេះ ដើម្បីសម្រេចរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្តនេះបាន អាជ្ញាសាលាត្រូវបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តត្រូវរុះរើចាកចេញពីអចលនវត្ថុនោះដោយស្ម័គ្រចិត្ត។ ប៉ុន្តែប្រសិនបើកូនបំណុលនៃការអនុវត្តមិនព្រមធ្វើតាមការបង្គាប់នេះទេ អាជ្ញាសាលាត្រូវអនុវត្តដោយបង្ខំឱ្យកូនបំណុលនៃការអនុវត្តតាមរយៈការបណ្តេញចេញពីអចលនវត្ថុដោយប្រើប្រាស់កម្លាំងសាធារណៈ ប្រសិនបើកូនបំណុលនៅតែបន្តការរឹងរូសមិនព្រមចាកចេញ។

ប្រសិនបើមានឧបសគ្គដែលរារាំងដល់ការអនុវត្តដូចជា កូនបំណុលចាក់សោរបិទទ្វារ ព្រលែងឆ្កែកាច ឬ បង្កើតឱ្យមានហេតុការណ៍ផ្សេងៗទៀតជាយថាហេតុ នោះអាជ្ញាសាលាត្រូវមានភាពឈ្លាសវៃ ក្នុងការដោះស្រាយបញ្ហានេះ ដោយត្រៀមទុកជាមុននូវអ្នកជំនាញ កាត់សោរ ចាប់ឆ្កែ និងគ្រូពេទ្យ រថយន្តពន្លត់អគ្គីភ័យជាដើម សម្រាប់ជួយដោះស្រាយបញ្ហាដែលអាចកើតមានជាយថាហេតុ។[57] ដូច្នេះ ក្នុងការអនុវត្តដោយបង្ខំម្តងៗ អាជ្ញាសាលាត្រូវមានភាពប្រុងប្រយ័ត្នខ្ពស់បំផុត ហើយត្រូវគិតនិងត្រៀមទុកជាមុន ព្រមទាំងព្យាករណ៍នូវស្ថានការណ៍ទាំងឡាយដែលអាចកើតមាន ព្រោះប្រសិនបើមានហេតុការណ៍មិនប្រក្រតីណាមួយ ឬ គ្រោះថ្នាក់ណាមួយកើតឡើង ហើយត្រូវចងចាំថា អ្នកដែលទទួលខុសត្រូវខ្ពស់ជាងគេក្នុងការអនុវត្តនីតិវិធីនេះ គឺអាជ្ញាសាលា។

**កថាភាគទី២. ករណីមានសំណង់របស់កូនបំណុលនៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត**

ការអនុវត្តការប្រគល់អចលនវត្ថុ គឺជាសមត្ថកិច្ចរបស់អាជ្ញាសាលា ប៉ុន្តែចំពោះការរុះរើអចលនវត្ថុវិញ គឺជាសមត្ថកិច្ចរបស់តុលាការអនុវត្ត។ ក្នុងករណីនេះ បើយោងតាមប្រកាសលេខ៣០ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ចំណុចទី៥ មន្ត្រីទទួលបន្ទុកអាជ្ញាសាលាអាចធ្វើបានទាំងពីរ ទាំងការរុះរើ និងការប្រគល់អចលនវត្ថុ។ ប៉ុន្តែប្រសិនបើមានការព្រួយបារម្ភថា ការរុះរើនោះអាចនឹងខុសសមត្ថកិច្ចអាជ្ញាសាលា នោះគេអាចអនុវត្តតែការប្រគល់អចលនវត្ថុសិនបានហើយ បន្ទាប់មកឱ្យម្ចាស់បំណុលដាក់ពាក្យសុំរុះរើមួយទៀតទៅតុលាការអនុវត្ត ដើម្បីចេញសាលក្រមសម្រេចឱ្យរុះរើផ្ទះ ឬ អាគារចេញពីដី ដោយចេញដីកាសម្រេចអនុវត្តជំនួស រួចឱ្យអាជ្ញាសាលាចុះអនុវត្តការរុះរើតែម្តង ហើយករណីនេះ គេអាចកំណត់កាលបរិច្ឆេទនៃការអនុវត្តរុះរើក្នុងពេលតែមួយនឹងការអនុវត្តការប្រគល់ ឬ អាចធ្វើក្នុងពេលផ្សេងពីគ្នាក៏បាន គឺវាអាស្រ័យទៅលើស្ថានភាពជាក់ស្តែង។ សរុបជារួមមក ដោយសារស្ថានភាពជាក់ស្តែងរបស់អចលនវត្ថុមិនអាចកែប្រែបានទេនោះ ប្រសិនបើមានសំណង់ណាមួយ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត

[56] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៥។
[57] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៤២។

ស្ថិតនៅលើដីដែលត្រូវបណ្តេញចេញ អាជ្ញាសាលាមិនអាចបំផ្លាញសំណង់នោះដោយគ្មានការអនុញ្ញាតឡើយ។ ដើម្បីទាមទារឱ្យដកសំណង់នេះចេញ ម្ចាស់បំណុលនៃការអនុវត្តពុំមានជម្រើសអ្វីផ្សេងក្រៅពីត្រូវទទួលលិខិតអនុវត្តមួយដោយឡែក ដើម្បីអនុវត្តដោយបង្ខំឱ្យដកសំណង់នោះចេញ និងត្រូវងាកទៅរកវិធីនៃការអនុវត្តជំនួស[58] នោះឡើយ។

**កថាភាគទី៣. ករណីអចលនវត្ថុត្រូវបានកាន់កាប់ដោយតតិយជន**

ប្រសិនបើមានតតិយជនកំពុងកាន់កាប់អចលវត្ថុដែលជាកម្មវត្ថុ អាជ្ញាសាលាមិនអាចរំលាយការកាន់កាប់ដោយតតិយជននោះ ហើយប្រគល់អចលនវត្ថុទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដោយផ្ទាល់បានទេ។ ប៉ុន្តែប្រសិនបើកូនបំណុលនៃការអនុវត្តមានសិទ្ធិទាមទារឱ្យប្រគល់ចំពោះតតិយជននោះ ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំឱ្យអនុវត្តតាមវិធីដូចការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទៅតុលាការអនុវត្ត ដើម្បីទទួលដីកាសម្រេចដែលបង្គាប់ឱ្យរឹបអូសសិទ្ធិទាមទារឱ្យប្រគល់នោះ និងដែលអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តសិទ្ធិទាមទារឱ្យប្រគល់នោះ ដែលបញ្ជាក់ថា ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារឱ្យប្រគល់វត្ថុនោះ ចំពោះតតិយជននោះ ជំនួសកូនបំណុលនៃការអនុវត្តបាន[59]។ នៅក្នុងករណីនេះ តុលាការអនុវត្តគឺ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលលំនៅឋានរបស់កូនបំណុលនៃការអនុវត្តស្ថិតនៅ[60]។ ម្យ៉ាងវិញទៀត ប្រសិនបើតតិយជនគ្រាន់តែជាអ្នកកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុ ដើម្បីផលប្រយោជន៍របស់កូនបំណុលដូចជា អ្នកទទួលបញ្ញើដោយឥតគិតថ្លៃ អ្នកថែរក្សាគ្រប់គ្រងជាដើមនោះ ដោយផ្អែកលើលិខិតអនុវត្តដូចជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកជាដើម ក្នុងករណីនេះ ម្ចាស់បំណុលនៃការអនុវត្តអាចទទួលរូបមន្តអនុវត្ត ហើយធ្វើការអនុវត្តដោយបង្ខំបាន[61]។ ប៉ុន្តែ គួរបញ្ជាក់ថា នៅក្នុងករណីនេះ អ្នកកាន់កាប់អចលនវត្ថុគឺកូនបំណុលនៃការអនុវត្តមិនមែនតតិយជនទេ។ ក៏ប៉ុន្តែ ដើម្បីធ្វើការអនុវត្តចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថាកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយឯករាជ្យដាច់ដោយឡែកពីកូនបំណុលនៃការអនុវត្តដូចជា បុគ្គលដែលមិនមែនជាសមាជិកគ្រួសាររបស់កូនបំណុលនៃការអនុវត្តជាដើម ដូចជាអ្នកជួលជាដើម នោះចាំបាច់ត្រូវមានលិខិតអនុវត្តចំពោះបុគ្គលនោះ។

**កថាភាគទី៤. ករណីមានចលនវត្ថុនៅជាប់ជាមួយអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត**

ចំពោះករណីចលនវត្ថុទាំងឡាយ ដែលជាវត្ថុចំណុះនៅជាប់ជាមួយនឹងអចលនវត្ថុដែលជាកម្មនៃការ

[58] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៧។

[59] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៦, មាត្រា៤០២ (៣,៤), មាត្រា៤០៣, មាត្រា៤០៥ និងមាត្រា៤១០ (១,២,៤)។

[60] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៤ (២) និងមាត្រា៤០២ (៣)។

[61] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៣៥១ (២) និងមាត្រា៣៥៦ (២,៣)។

អនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនោះ គេត្រូវប្រគល់វាទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ពីព្រោះវាមិនអាចបំបែកចេញពីវត្ថុចម្បងបានឡើយ ឧទាហរណ៍ដូចជា គ្រឿងសង្ហារិម វត្ថុតាំងភ្ជាប់នឹងជញ្ជាំង ពិដាន សម្ភារៈអគ្គីសនី ជាដើម។ ប៉ុន្តែចំពោះចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ឬ របស់តតិយជន ក្រៅពីវត្ថុចំណុះដូចដែលបានរៀបរាប់ខាងលើនេះវិញ អាជ្ញាសាលាអាចរុះរើ ឬដោះចលនវត្ថុទាំងនោះចេញពីអចលនវត្ថុ ហើយប្រគល់ចលនវត្ថុទាំងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនោះ ឬ ញាតិនៅជាមួយ ឬ អ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះ ដែលមានការយល់ដឹងសមរម្យ[62]។

ប៉ុន្តែ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុទាំងនោះទៅឱ្យជនដូចដែលបានរៀបរាប់ខាងលើនេះបានទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះតាមវិធីសមរម្យ ដោយឱ្យកូនបំណុលនៃការអនុវត្តជាអ្នកចេញសោហ៊ុយក្នុងការថែរក្សាគ្រប់គ្រងនោះ[63] ហើយត្រូវជូនដំណឹងអំពីការណ៍នេះទៅឱ្យកូនបំណុលនៃការអនុវត្ត[64]។ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនៃការអនុវត្ត ឬញាតិនៅជាមួយ ឬ អ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលាអាចលក់ចលនត្ថុនោះ តាមវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន ហើយករណីនេះ អាជ្ញាសាលាត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់ នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និងការថែរក្សាគ្រប់គ្រង ហើយត្រូវផ្ញើទុកប្រាក់ដែលនៅសេសសល់នោះនៅសាលាដំបូងដែលខ្លួនស្ថិតនៅ[65]។

## ផ្នែកទី៣. បញ្ចប់នីតិវិធីនៃការអនុវត្តការប្រគល់អចលនវត្ថុ

### កថាភាគទី១. ការធ្វើកំណត់ហេតុនៃការអនុវត្ត

ស្ទើរតែគ្រប់នីតិវិធីទាំងអស់របស់អាជ្ញាសាលា ក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវតែមានការធ្វើកំណត់ហេតុនៃការអនុវត្តសម្រាប់ទុកជាភស្តុតាងនៃការអនុវត្តដោយមានការចូលរួមទទួលស្គាល់ និងចុះហត្ថលេខាទទួលស្គាល់ពីគណៈកម្មការ និងភាគីពាក់ព័ន្ធទាំងអស់ដែលចូលរួម។ កំណត់ហេតុ គឺជាឧបករណ៍គតិយុត្តមួយដ៏សំខាន់សម្រាប់ការការពារខ្លួនរបស់អាជ្ញាសាលា ចំពោះការចោទប្រកាន់នានា អំពីការអនុវត្តមុខងាររបស់ខ្លួន ព្រោះកំណត់ហេតុគឺជាការកត់ត្រានូវរាល់សកម្មភាពសំខាន់ៗ ដែលអាជ្ញាសាលាបានធ្វើ និងបញ្ជាឱ្យគេធ្វើក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ប្រសិនបើមានការចោទប្រកាន់ណាមួយកើតឡើងពាក់ព័ន្ធទៅនឹងការអនុវត្តមុខងាររបស់ខ្លួន ភស្តុតាងដ៏សំខាន់មួយនេះ នឹងជួយបំភ្លឺនូវភាពត្រឹមត្រូវនៃការអនុវត្តជាក់ស្តែងរបស់អាជ្ញាសាលា ក្នុងករណីមានបណ្តឹងឧបាស្រ័យណាមួយទៅតុលាការ។ ការបកស្រាយទប់ទល់

[62] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៤ (៤)

[63] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៤ កថាខណ្ឌទី៤ វាក្យខណ្ឌទី២ និងកថាខណ្ឌទី៥

[64] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៥២៤ (៨)

[65] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៥២៤ (៦,៧)

ចំពោះការចោទប្រកាន់នានា គឺត្រូវបានបញ្ជាក់នៅក្នុងកំណត់ហេតុ។ ប្រសិនបើអាជ្ញាសាលាធ្វើការអនុវត្តមុខងាររបស់ខ្លួន ដោយមិនបានធ្វើកំណត់ហេតុនោះទេ នោះអាជ្ញាសាលាមិនអាចមានអ្វីឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនោះបានឡើយ។ ជាក់ស្តែងនៅក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលាអាចធ្វើកំណត់ហេតុមួយចំនួនដូចជា កំណត់ហេតុនៃការប្រគល់អចលនវត្ថុ កំណត់ហេតុនៃការរុះរើចលនវត្ថុ កំណត់ហេតុនៃការរុះរើសំណង់ ឬ អាគារផ្សេងៗ កំណត់ហេតុនៃការកាត់សោរ...។ល។ ជាមួយគ្នានេះដែរ កំណត់ហេតុទាំងអស់ខាងលើនេះ គេអាចធ្វើរួមបញ្ចូលគ្នាក្នុងកំណត់ហេតុតែមួយ ឬ ធ្វើកំណត់ហេតុផ្សេងៗគ្នា។ ដូច្នេះវាអាស្រ័យទៅលើទម្លាប់នៃការអនុវត្តជាក់ស្តែងរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាម្នាក់ ក្រោយពីការធ្វើកំណត់ហេតុបានបញ្ចប់ អាជ្ញាសាលាត្រូវឱ្យអ្នកដែលចូលរួមចុះហត្ថលេខា ក្នុងករណីដែលកូនបំណុលមិនព្រមចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃ អាជ្ញាសាលាអាចចារនៅលើកំណត់ហេតុនោះថា កូនបំណុលចូលរួមអនុវត្តតែមិនព្រមផ្តិតស្នាមមេដៃ។ បន្ទាប់មកអាជ្ញាសាលាត្រូវអានកំណត់ហេតុនោះឱ្យអ្នកដែលចូលរួមបានស្តាប់ និងថតចម្លងកំណត់ហេតុនោះ ចែកជូនអាជ្ញាធរដែលចូលរួមអនុវត្ត ព្រមទាំងថតចម្លងជូនម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តសម្រាប់ទុកជាឯកសារអនុវត្ត។

### កថាភាគទី២. បញ្ចប់នីតិវិធីនៃការអនុវត្តការប្រគល់អចលវត្ថុ

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់ឱ្យបានច្បាស់លាស់អំពីពេលវេលានៃការបញ្ចប់របស់នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុឡើយ។ ប៉ុន្តែតាមរយៈការអនុវត្តជាទូទៅ ការបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំនេះ នឹងត្រូវបានបញ្ចប់នៅពេលដែលលំហូរនីតិវិធី ដែលមានចែងនៅក្នុងច្បាប់ត្រូវបានបំពេញចប់សព្វគ្រប់ ហើយលំហូរនីតិវិធីនៃការអនុវត្តជាក់ស្តែងនៅនឹងទីតាំងអនុវត្តត្រូវបានបញ្ចប់ដូចគ្នាផងដែរ។ ករណីនេះមានន័យថា សិទ្ធិកាន់កាប់របស់កូនបំណុលនៃការអនុវត្តដែលមានលើអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តត្រូវបានរំលាយទាំងអស់ ហើយសិទ្ធិកាន់កាប់នេះត្រូវបានប្រគល់ទាំងស្រុងទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។ ហេតុដូច្នេះហើយ បានជានៅក្នុងនីតិវិធីនេះ ទាមទារឱ្យមានការចូលរួមពីម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងដោយអាណត្តិ ដើម្បីទទួលសិទ្ធិកាន់កាប់នេះបន្ទាប់ពីស្ថាប័នអនុវត្តបានរំលាយការកាន់កាប់រួចហើយ។

លើសពីនេះ គេអាចកំណត់ការបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះបានដោយវិធីម្យ៉ាងទៀត គឺការបញ្ចប់ការធ្វើកំណត់ហេតុ។ ជាធម្មតា នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំនីមួយៗរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺតែងតែមានសរសេរនៅក្នុងកំណត់ហេតុនៃការអនុវត្ត។ ហេតុដូច្នេះហើយ កំណត់ហេតុនេះមានសារៈសំខាន់ណាស់ សម្រាប់កំណត់អំពីកាលបរិច្ឆេទនៃការបញ្ចប់ការអនុវត្ត។ ចំពោះការបញ្ចប់កំណត់ហេតុនេះទៀតសោត គឺត្រូវបានអានជាសាធារណៈជូនដល់អ្នកចូលរួមបានស្តាប់ ព្រមទាំងមានការចុះហត្ថលេខា និងផ្តិតស្នាមមេដៃពីម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត មន្ត្រីទទួល

បន្ទុកកិច្ចការអាជ្ញាសាលា អ្នកធ្វើកំណត់ហេតុ និងអាជ្ញាធរសាធារណៈដែលចូលរួមក្នុងការអនុវត្ត ជាដើម។

ការអានកំណត់ហេតុនៃការអនុវត្ត និងការថតចម្លងកំណត់ហេតុនៃការអនុវត្តនេះ ជូនដល់អ្នកដែលចូលរួមអនុវត្ត ដូចដែលបានរៀបរាប់ខាងលើនេះ ត្រូវបានគេចាត់ទុកថា ដូចជាការផ្សព្វផ្សាយជាសាធារណៈមួយដល់គ្រប់ភាគី ដែលពាក់ព័ន្ធនឹងការអនុវត្ត ដើម្បីឱ្យពួកគេដឹងថា ស្ថាប័នអនុវត្តដោយបង្ខំបានធ្វើការរំលាយសិទ្ធិកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ហើយបានប្រគល់សិទ្ធិកាន់កាប់នេះទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដោយស្របច្បាប់ តាមខ្លឹមសារដែលមានចែងនៅក្នុងលិខិតអនុវត្តហើយ ដូច្នេះ អ្នកដែលចូលរួមអនុវត្ត និងអាជ្ញាធរសាធារណៈទាំងឡាយ ត្រូវតែចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីសម្រេចនេះ។

អាជ្ញាសាលាធ្វើការណែនាំឱ្យអាជ្ញាធរមូលដ្ឋាន មេឃុំ ចៅសង្កាត់ធ្វើការពន្យល់បន្ថែមដល់កូនបំណុលនៃការអនុវត្ត ដើម្បីបញ្ឈប់រាល់សកម្មភាពដែលធ្វើឱ្យមានការរំខាន ឬប៉ះពាល់ដល់អចលនវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចការប្រគល់បានសម្រេច ព្រោះសិទ្ធិរបស់ខ្លួនលើអចលនវត្ថុត្រូវរលត់អត្ថិភាព ហើយរាល់ទង្វើដែលប៉ះពាល់ដល់អចលនវត្ថុនោះ នឹងទទួលបានការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[66]។

សរុបជារួមមក ការបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវបានបញ្ចប់ទាំងស្រុងនៅពេលដែលកំណត់ហេតុនៃការអនុវត្តត្រូវបានបញ្ចប់ និងអានឱ្យអ្នកដែលចូលរួមបានស្តាប់ ហើយម្ចាស់បំណុលទទួលបានសិទ្ធិកាន់កាប់អចលនវត្ថុដោយពេញលេញ ហើយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាប្រកាសរំសាយកម្លាំងដែលចូលរួមអនុវត្ត។

[66] ខាំ សុមករា, *ការអនុវត្តដោយបង្ខំឱ្យបគល់អចលនវត្ថុ*"(ភ្នំពេញ, ១៨ កុម្ភៈ ២០២១), ១៩

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមរយៈការបកស្រាយអំពីខ្លឹមសារ នៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុខាងលើ យើងអាចធ្វើការសន្និដ្ឋានជារួមមកវិញបានថា ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជានីតិវិធីចុងក្រោយមួយ ដែលស្ថាប័នអាជ្ញាសាលា ត្រូវអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ឱ្យរំលាយសិទ្ធិកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលសិទ្ធិទាមទារនេះមានបញ្ជាក់នៅក្នុងលិខិតអនុវត្ត។

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុអាចធ្វើទៅបាន វាទាមទារឱ្យអាជ្ញាសាលាត្រូវយល់ឱ្យបានច្បាស់អំពីខ្លឹមសារនៃការអនុវត្ត ស្ថាប័នមានសមត្ថកិច្ច វត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ល័ក្ខខ័ណ្ឌដែលអាចអនុវត្តបាន មូលហេតុនៃការអនុវត្ត ព្រមទាំងសិទ្ធិនិងករណីយកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ជាមួយគ្នានេះដែរ វាអាចធ្វើឱ្យយើងបានយល់ច្បាស់អំពីលំហូរនីតិវិធីនៃការអនុវត្ត ដែលរួមមានៈ ការរៀបចំដាក់ពាក្យសុំ ការពិនិត្យពាក្យសុំដោយអាជ្ញាសាលា ការងារត្រៀមមុនពេលចុះអនុវត្ត និងការចុះអនុវត្តផ្ទាល់នៅនឹងទីតាំងនៃការអនុវត្ត។ នៅក្នុងនីតិវិធីនេះ មានច្រើនវិធីក្នុងការអនុវត្ត ហើយវាអាស្រ័យទៅតាមករណីនីមួយៗដូចជា ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ក្នុងករណីដែលអចលនវត្ថុនោះ ត្រូវបានកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ឬ កាន់កាប់ដោយតតិយជន ករណីដែលមានសំណង់របស់កូនបំណុលនៃការអនុវត្តសាងសង់ក្នុងនោះ ព្រមទាំងការចាត់ចែងនិងគ្រប់គ្រងចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តដែលនៅជាប់នឹងអចលនវត្ថុនោះ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តមិនព្រមរុះរើតាមសេចក្ដីសម្រេចរបស់តុលាការ។ នីតិវិធីនេះ គឺជានីតិវិធីមួយដែលមានលក្ខណៈលំបាក និងស្មុគស្មាញក្នុងការអនុវត្ត ពីព្រោះក្នុងដំណាក់កាលនីមួយៗនៃនីតិវិធីនេះ អាជ្ញាសាលាត្រូវមានភាពឈ្លាសវៃ និងច្បាស់លាស់ទៅនឹងខ្លឹមសារនៃការអនុវត្តដែលជាសេចក្ដីសម្រេចរបស់តុលាការ។ម្យ៉ាងវិញទៀត ការអនុវត្តនីតិវិធីនេះ វាអាចកើតមាននូវបណ្ដឹងតវ៉ា ឬ បណ្ដឹងជំទាស់ផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការអនុវត្តកិច្ចការរបស់អាជ្ញាសាលា ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមតាមច្បាប់និងលិខិតអនុវត្ត។

លើសពីនេះទៅទៀត ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជាការងារមួយដែលក្ដៅ ហើយអាចមានការប្រឆាំងតវ៉ាកើតឡើងជាយថាហេតុ ក្នុងករណីនេះ អាជ្ញាសាលាត្រូវមានភាពបត់បែន និងប្រុងប្រយ័ត្នខ្ពស់ចំពោះការអនុវត្តមុខងាររបស់ខ្លួន ជាពិសេសគឺភាពឆ្លាតវៃក្នុងការគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពផ្ទាល់ខ្លួន និងអ្នកដែលចូលរួមអនុវត្តជាមួយ។

# អនុសាសន៍

# អនុសាសន៍

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជានីតិវិធីមួយដែលមានភាពសាមញ្ញនៅក្នុងច្បាប់ និងក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងវិញ គឺមានភាពបត់បែន និងស្មុគស្មាញ ហើយពិបាកក្នុងការអនុវត្ត។ ជាមួយគ្នានេះដែរ តាមការអនុវត្តកន្លងមកសង្កេតឃើញមានបញ្ហាមួយចំនួនបានកើតមានឡើងនៅក្នុងនីតិវិធីនេះ ដែលរួមមានដូចជា៖

១. ការសរសេរពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនៅមានភាពខ្វះចន្លោះ។ ជាក់ស្តែងដូចជាពាក្យសុំមួយចំនួនមិនមានបញ្ជាក់អំពី ខ្លឹមសារសំខាន់ៗដែលមានចែងនៅក្នុងមាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី អំពីរបៀបសរសេរពាក្យសុំអនុវត្តដោយបង្ខំ ជាដើម។ បញ្ហានេះអាចកើតចេញពីកង្វះសមត្ថភាពរបស់អ្នកសរសេរពាក្យសុំ (មេធាវីតំណាងដោយអាណត្តិ ឬ ម្ចាស់បំណុលនៃការអនុវត្ត) ជាដើម។ ប៉ុន្តែ ទោះបីជាមានការកំហុសឆ្គង ឬកង្វះខាតមួយចំនួនកើតមានជារឿយៗក៏ដោយ ក៏ស្ថាប័នអនុវត្តនៅតែមានភាពទន់ភ្លន់ និងការអធ្យាស្រ័យជានិច្ច ដោយបច្ចុប្បន្ន កម្រនឹងបង្គាប់ឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវពាក្យសុំ ឬលើកចោលពាក្យសុំនោះឡើយ។ ករណីនេះ គឺជាកំហុសឆ្គងមួយរបស់ស្ថាប័នអនុវត្ត និង អ្នកដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។ ដូច្នេះ កំហុសឆ្គងខាងលើនេះ គួរតែត្រូវបានកែតម្រូវ ហើយស្ថាប័នអនុវត្តគួរណែនាំឱ្យអ្នកដាក់ពាក្យសុំអនុវត្តសរសេរពាក្យសុំឱ្យបានត្រឹមត្រូវ តាមមាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. កំហុសសមត្ថកិច្ច នៃស្ថាប័នអនុវត្តក៏ជាបញ្ហាមួយដែលជួបប្រទះជាញឹកញាប់ផងដែរ ជាក់ស្តែងនៅក្នុងសំណុំរឿងអនុវត្តមួយចំនួន យើងសង្កេតឃើញថា តុលាការអនុវត្តបានធ្វើការងារខុសសមត្ថកិច្ចរបស់ខ្លួន។ ដូចដែល យើងបានដឹងស្រាប់ហើយថា ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អាជ្ញាសាលា ប៉ុន្តែចៅក្រមអនុវត្តបែរជាចេញដីកាសម្រេចអនុវត្តជំនួស ហើយបញ្ជូនមកឱ្យអាជ្ញាសាលាអនុវត្តជំនួសខ្លួនទៅវិញ នេះគឺជាកំហុសបច្ចេកទេសរបស់តុលាការអនុវត្ត ដែលគួរតែត្រូវបានកែតម្រូវឱ្យស្របទៅតាមច្បាប់វិញ។ ដូច្នេះ ករណីនេះគួរត្រូវបានកែតម្រូវ ហើយតុលាការអនុវត្តមិនគួរចេញដីកាសម្រេចអនុវត្តជំនួសចំពោះករណីការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនោះបន្តទៀតឡើយ។

៣. ការមិនចូលរួមអនុវត្តពីអាជ្ញាធរសាធារណៈ ជាធម្មតា ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុគឺទាមទារឱ្យមានការចូលរួមពីអាជ្ញាធរសាធារណៈ និងកងកម្លាំងសាធារណៈ ពីព្រោះស្ថាប័នតុលាការគ្មានកងកម្លាំងសម្រាប់ប្រើប្រាស់ដោយខ្លួនឯងឡើយ។ ដូច្នេះ កាលណាគ្មានការចូលរួមពីអាជ្ញាធរសាធារណៈទេ នោះស្ថាប័នអនុវត្តរបស់តុលាការនឹងមិនអាចអនុវត្តបានទេ ក្នុងករណីនេះដែរ ប្រសិនបើការមិនចូលរួមអនុវត្តសេចក្តីសម្រេចរបស់តុលាការនេះ គឺជាចេតនារបស់អាជ្ញាធរសាធារណៈទាំងនោះវិញ នោះនឹងនាំឱ្យមានបទល្មើសព្រហ្មទណ្ឌកើតឡើង។ ជាក់ស្តែងបទល្មើសនេះ គឺមានចែងកំណត់នៅក្នុងមាត្រា៥២០ នៃក្រមព្រហ្មទណ្ឌ៖

"បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ"។ ជាមួយគ្នានេះដែរ អាជ្ញាធរសាធារណៈដែលត្រូវចូលរួមក្នុងការអនុវត្តសេចក្តីសម្រេចរបស់តុលាការ អាចមានដូចជា អាជ្ញាធរមូលដ្ឋាន (ឃុំ សង្កាត់) មន្ត្រីសុរិយោដី ឬភូមិបាលស្រុក កងកម្លាំងនគរបាល កងរាជអាវុធហត្ថស្រុក ឬខេត្ត។ កងកម្លាំងទាំងអស់នេះមានតួនាទីសំខាន់ណាស់ សម្រាប់ធានាឱ្យការអនុវត្ត អាចធ្វើទៅបាន និងទប់ទល់នូវការប្រឆាំងនានាដែលអាចកើតមាន។ ដូច្នេះ ដើម្បីចូលរួមក្នុងការអនុវត្តច្បាប់ និងធានាបាននូវភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ ព្រមទាំងបម្រើសេវាសាធារណៈឱ្យបានកាន់តែល្អប្រសើរ ជូនប្រជាពលរដ្ឋ អាជ្ញាធរសាធារណៈគ្រប់លំដាប់ថ្នាក់គួរតែចូលរួមក្នុងការអនុវត្តសេចក្តីសម្រេច នានារបស់ស្ថាប័នតុលាការឱ្យទទួលបានលទ្ធផលល្អប្រសើរ។

៤. ការមិនយល់ដឹងអំពីសិទ្ធិតតាំងចំពោះការអនុវត្ត ករណីនេះ គឺចង់សំដៅទៅលើតតិយជនដែលមានសិទ្ធិតតាំង។ ដោយសារតែតតិយជនដែលមានសិទ្ធិតតាំងនេះ គឺជាប្រជាពលរដ្ឋសាមញ្ញដែលមិនបានយល់ដឹងស៊ីជម្រៅអំពីសិទ្ធិរបស់ខ្លួន ទើបមន្ត្រីអនុវត្តច្បាប់មួយចំនួនឆ្លៀតឱកាសរំលោភបំពានលើសិទ្ធិដែលពួកគាត់មាន។ តាមរយៈការអនុវត្តជាក់ស្តែងកន្លងមក មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា កម្រនឹងប្រាប់អំពីសិទ្ធិតតាំងរបស់តតិយជននេះខ្លាំងណាស់ ហើយព្យាយាមបណ្តេញតតិយជន ដែលមានសិទ្ធិតតាំងនេះ ចេញពីអចលនវត្ថុដែលគាត់បានជួលពីកូនបំណុលនៃការអនុវត្ត។ ការធ្វើបែបនេះ គឺការរំលោភបំពានយ៉ាងខ្លាំងដល់សិទ្ធិរបស់ពួកគាត់ ព្រោះថាសិទ្ធិនេះមិនរលត់ដោយសារការអនុវត្តដោយបង្ខំឡើយ។ ដូច្នេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាគួរតែសិក្សាស្វែងយល់បន្ថែមអំពីសិទ្ធិនេះ ហើយព្យាយាមអនុវត្តតាមលិខិតអនុវត្ត និងគោរពនូវសិទ្ធិដែលពលរដ្ឋមាន ព្រមទាំងមិនត្រូវកេងបន្លំបំភ្លៃ និងបំពានលើសិទ្ធិនេះឡើយ។

៥. វិបត្តិរបស់សង្គម ក៏ជាបញ្ហាមួយដែលបង្កការលំបាកយ៉ាងខ្លាំងដល់ការអនុវត្តដោយបង្ខំផង។ ការអភិវឌ្ឍសង្គមឱ្យមានភាពរីកចំរើន គឺជាកត្តាគន្លឹះដែលធ្វើឱ្យពលរដ្ឋយល់ដឹងអំពីច្បាប់ និងចូលរួមអនុវត្តច្បាប់។ កាលណាសង្គមពោរពេញទៅដោយបញ្ញវ័ន្ត ហើយកម្រិតនៃការយល់ដឹងរបស់ពលរដ្ឋ នៅក្នុងសង្គមមានភាពទូលំទូលាយ នោះវិបត្តិសង្គមនានានឹងត្រូវបានកាត់បន្ថយ ហើយពលរដ្ឋនឹងលែងប្រព្រឹត្តនូវសកម្មភាពណាមួយដែលច្បាប់ហាមឃាត់។ ដើម្បីទទួលបាននូវភាពសុខដុម និងសង្គមមានស្ថិរភាពបែបនេះ រាជរដ្ឋាភិបាលគួរតែជម្រុញឱ្យពលរដ្ឋចូលរួមក្នុងការអនុវត្ត ការសិក្សា ការស្វែងយល់អំពីច្បាប់ និងធ្វើការផ្សព្វផ្សាយអំពីច្បាប់ឱ្យបានទូលំទូលាយ ដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកច្បាប់ឱ្យដល់ប្រជាពលរដ្ឋនៅគ្រប់មជ្ឈដ្ឋានទាំងអស់។

៦. ចំណេះដឹងរបស់ប្រជាពលរដ្ឋ ការអប់រំប្រជាពលរដ្ឋឱ្យមានចំណេះដឹងខ្ពស់នៅក្នុងសង្គមគឺមិនមែនជាការងាយស្រួលនោះឡើយ តែរាជរដ្ឋាភិបាលត្រូវតែព្យាយាមដោយស្រាយបញ្ហានេះ។ ចំណេះដឹងមានសារៈសំខាន់ណាស់សម្រាប់មនុស្សម្នាក់ៗ ពីព្រោះ ចំណេះដឹង គឺជាត្រីវិស័យមួយដ៏ល្អដែលអាចចង្អុលបង្ហាញផ្លូវដ៏ត្រឹមត្រូវមួយសម្រាប់មនុស្សម្នាក់ៗ ប្រទេសដែលមានការរីកចំរើនខ្លាំង គឺសំបូរទៅដោយធនធានមនុស្សសំបូរ

បែប ហើយសមត្ថភាពគ្រប់គ្រាន់សម្រាប់ប្រកួតប្រជែង និងបំពេញការងារជូនប្រជាជន និង ប្រទេសជាតិ។ ប៉ុន្តែ ដោយសារតែប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍដែលទើបតែរួចផុតពីសង្គ្រាមបង្ហូរឈាម ទើបធ្វើឱ្យការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាប ជាពិសេស ការយល់ដឹងអំពីច្បាប់ និងការគោរពប្រតិបត្តិច្បាប់នៅមានភាពខ្វះចន្លោះ ដែលជាហេតុបង្កឱ្យមានការលំបាកយ៉ាងខ្លាំងដល់ការអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នតុលាការ។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលគួរតែខិតខំបណ្តុះធនធានមនុស្សបន្ថែមទៀត ដើម្បីរួមចំណែកក្នុងការកាត់បន្ថយអនក្ខរភាព និងការប្រព្រឹត្តអំពើល្មើសច្បាប់នៅក្នុងសង្គម។

ឆ្លងតាមរយៈការបកស្រាយអំពីបញ្ហានានាដែលកើតមានចំពោះការអនុវត្តច្បាប់ និងសេចក្តីសម្រេចនានារបស់ស្ថាប័នតុលាការ ដូចដែលបានរៀបរាប់ជូនខាងលើ ជាថ្មីម្តងទៀត យើងខ្ញុំសូមសំណូមពរឱ្យបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា មេត្តាជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់បន្ថែមទៀត ដើម្បីរួមចំណែកក្នុងការបង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ ក៏សូមសំណូមពរឱ្យប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានចូលរួមក្នុងការអនុវត្តច្បាប់ និងគោរពច្បាប់ទាំងអស់គ្នា ដើម្បីទទួលបាននូវសង្គមមួយដែលមានសុខសន្តិភាព និងស្ថិរភាព។

# ឯកសារយោង

# បញ្ជីឯកសារយោង

## ❖ លិខិតបទដ្ឋានគតិយុត្ត

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣។

-ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧។

-ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

-ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

-ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

-ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រក/ ០៥១១/០០៧, ៣១ ឧសភា ២០១១។

-ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រក ម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។

-ច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី, លេខ ៥១, ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩២។

-ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ៣០ កយប្រក/០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០៧។

-ប្រកាសលេខ០៦២ កយ.ប្រក/១៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីបែបបទសម្រាប់អនុវត្តការងារ របស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌។

-ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីលេខ៥៩ ប្រកដនស/ ១១ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងយុត្តិធម៌។

-សេចក្តីបង្គាប់លេខ១១៧ សរ.រវ.៩៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៧ របស់ក្រសួងយុត្តិធម៌ស្តីពី ការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ។

-សេចក្តីណែនាំពីបែបបទនៃការអនុវត្តដោយបង្ខំ និងការចាត់ចែងលើ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា លេខ១៦៨ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៨។

❖ **សៀវភៅ និងឯកសារផ្សេងទៀត**

-ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. ២០០៨. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១៖ នីតិវិធីបណ្តឹង.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

-ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. ២០០៩. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

-គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី.២០១០. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ១៖គន្ថីទី១-៣.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

-គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី.២០០៧. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

-ខាំ សុមករា. ២០២១. ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ. ភ្នំពេញ។

-ហ៊ាង ចាន់ដារ៉ា. ២០២២. សៀវភៅទ្រឹស្តីការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ. ភ្នំពេញ។

-គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃទីស្តីការគណរដ្ឋមន្ត្រី. *សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* បោះពុម្ពលើកទី១ ឆ្នាំ ២០០៧។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ៣០.កយ/ប្រក/០៧

# ប្រកាស
## ស្តីពី
## មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

********

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញសេចក្តីបង្គាប់លេខ ១១៧ សរ.រវ.៩៧ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និង សេចក្តីសំរេចផ្សេងៗរបស់តុលាការ
- យោងតាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## ស រ ម្រេ ច

**ប្រការ ១** ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

១- ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង នៃសាលាដំបូង ត្រូវអនុវត្តកិច្ចការរបស់



ផ្លូវសម្តេចសុធារស.ខ័ណ្ឌដូនពេញ.ក្រុងភ្នំពេញ ទូរស័ព្ទ : 023 216 322 , 023 212 693

អាជ្ញាសាលា ក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីអាជ្ញាសាលា ។

២-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវអនុវត្តកិច្ចការខាងក្រោមនេះ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម :

ក-កិច្ចការដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀតថា ត្រូវចាត់ចែងដោយអាជ្ញាសាលា ។

ខ-កិច្ចការពាក់ព័ន្ធនឹងការរក្សា ការគ្រប់គ្រងវត្ថុ ឬ សកម្មភាពផ្សេងទៀតដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថា ត្រូវចាត់ចែងដោយអាជ្ញាសាលា ។

**ប្រការ ២ អ្នកអនុវត្តកិច្ចការជំនួស អ្នកជំនួយក្នុងការអនុវត្តកិច្ចការ ជាអាទិ៍**

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវអនុវត្តកិច្ចការដោយខ្លួនឯង ។ ប៉ុន្តែក្នុងករណីដែលប្រតិបត្តិការបញ្ជូន ដោយយោងតាមកថាខណ្ឌទី ៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមានមូលហេតុពិសេសដែលមិនអាចអនុវត្តកិច្ចការនោះដោយខ្លួនឯង មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចឱ្យអ្នកអនុវត្តកិច្ចការជំនួស អនុវត្តកិច្ចការនោះជំនួសខ្លួន ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

២-ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចប្រើអ្នកបច្ចេកទេស ឬ កម្មករបាន ។

៣-ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចប្រើអ្នកជំនួយក្នុងការអនុវត្តកិច្ចការ ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

៤-ប្រធានសាលាដំបូង អាចលុបចោលនូវការអនុញ្ញាតដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៅពេលណាក៏បានដែរ ។

**ប្រការ ៣ ជំនួយក្នុងការអនុវត្តកិច្ចការ**

១-ប្រសិនបើមានការលំបាកពិសេស ក្នុងការអនុវត្តកិច្ចការដោយឯកឯង ឬ មាន

ការចាំបាច់ពិសេសផ្សេងទៀត ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចស្នើសុំជំនួយពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាផ្សេងទៀត ដោយទទួលបានការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

២-ប្រសិនបើមិនអាចទទួលជាមុននូវការអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយសារមានភាពចាំបាច់បន្ទាន់ចំពោះរឿងក្តី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវទទួលការអនុញ្ញាតនោះភ្លាម ក្រោយការស្នើសុំជំនួយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានីមួយៗ អាចទទួលការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ក្នុងការអនុវត្តកិច្ចការ ។

**ប្រការ ៤** ការរក្សាទុកនូវប្រាក់ដែលបានទទួលតាមកិច្ចការ ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវប្រគល់ប្រាក់ ឬ វត្ថុផ្សេងទៀតដែលខ្លួនបានរឹបអូស ឬ បានទទួលការប្រគល់ តាមការអនុវត្តកិច្ចការរបស់ខ្លួន ទៅអ្នកដែលត្រូវទទួលប្រាក់ ឬ វត្ថុនោះភ្លាម ឬ សាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ត្រូវរក្សាទុកនូវប្រាក់ ឬ វត្ថុនោះ លើកលែងតែករណីដែលត្រូវតម្កល់ ឬ ករណីផ្សេងទៀតដែលច្បាប់បានកំណត់ ។

២-នៅពេលដែលទទួលប្រាក់ ឬ វត្ថុផ្សេងទៀតពីភាគី ឬ បុគ្គលផ្សេងទៀត តាមការអនុវត្តកិច្ចការរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចេញលិខិតបញ្ជាក់ការទទួល (បង្កាន់ដៃ) ហើយត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ ឬ ប្រភេទ និង ចំនួននៃវត្ថុដែលខ្លួនបានទទួល និង ថ្ងៃ ខែ ឆ្នាំទទួល នៅក្នុងសំណុំរឿង ។

**ប្រការ ៥** ការចាត់ចែងកិច្ចការ

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ តាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះកិច្ចការដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់ ក្នុងនាមជាកិច្ចការដែលជាផ្នែកមួយនៃនីតិវិធីនៃរឿងក្តីដែលតុលាការនោះកំពុងចាត់ការ ។

២-ការចាត់ចែងកិច្ចការរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវកំណត់ដោយ

[illegible]ប្រធានតុលាការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះបំពេញ[illegible] ។ ប៉ុន្តែ ចំពោះកិច្ចការដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថា ត្រូវចាត់ចែងដោយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាជាកំណត់ណាម្នាក់ ក្នុងចំណោមកិច្ចការដែលបានកំណត់នៅក្នុងចំណុច ខ កថាខណ្ឌទី ២ នៃប្រការ ១ (មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា) មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ត្រូវចាត់ចែងកិច្ចការនោះ ។

**ប្រការ ៦ ការដកហូត**

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួនក្នុងករណីដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនោះ :

ក-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឬ សហព័ទ្ធរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ជាភាគី ឬ មានទំនាក់ទំនងនៃសិទ្ធិរួម ឬ កាតព្វកិច្ចរួមជាមួយនឹងភាគី ។

ខ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬ ញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) ឬ ញាតិដែលរស់នៅជាមួយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ។

គ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាអ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

ឃ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាអ្នកតំណាងរបស់ភាគីចំពោះកិច្ចការដែលខ្លួនត្រូវចាត់ចែង ។

២-ភាគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានរួមទាំងជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ ។

**ប្រការ ៧ ឧបាស្រ័យ**

ចំពោះពាក្យសុំឧបាស្រ័យចំពោះការគណនាសោហ៊ុយ ឬ ការចាត់ចែងផ្សេងទៀតរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាស្តីពីកិច្ចការដែលត្រូវបានចាត់ចែង តាមពាក្យសុំ ឬ ចំពោះពាក្យសុំឧបាស្រ័យចំពោះការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងកិច្ចការទាំងនោះ ត្រូវអនុលោមតាមករណីនៃការតវ៉ាចំពោះការអនុវត្តដែលបានកំណត់

នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៨៤ (ការតវ៉ាចំពោះការអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែករណីដែលមានបញ្ញត្តិពិសេស នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៨** របៀបដាក់ពាក្យសុំ

១-ពាក្យសុំចំពោះមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវធ្វើដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរបញ្ជាក់ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង ព្រមទាំងខ្លឹមសារនៃចំណុចដែលសុំនោះ ។

២-ក្នុងករណីដែលពាក្យសុំត្រូវបានដាក់ដោយអ្នកតំណាង ត្រូវភ្ជាប់លិខិតបញ្ជាក់សិទ្ធិតំណាង ជាមួយនឹងពាក្យសុំ ។

**ប្រការ ៩** លំដាប់នៃការចាត់ចែងកិច្ចការ

មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ តាមលំដាប់ដែលខ្លួនបានទទួល លើកលែងតែករណីដែលមានស្ថានភាពពិសេស ។

**ប្រការ ១០** ម៉ោងធ្វើការ និង ការចាត់ចែងកិច្ចការក្រៅម៉ោងធ្វើការ

១-ម៉ោងធ្វើការរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺចាប់ពីម៉ោងប្រាំពីរព្រឹក ដល់ម៉ោងប្រាំល្ងាច ។

២-ប្រសិនបើមានភាពចាំបាច់បន្ទាន់ ឬ ភាពចាំបាច់ពិសេសផ្សេងទៀត មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ ទោះជាក្រៅម៉ោងធ្វើការក៏ដោយ ។

**ប្រការ ១១** ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ

នៅពេលបំពេញមុខនាទីរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ ។

**ប្រការ ១២** ចំណុចត្រូវសរសេរនៅក្នុងកំណត់ហេតុ

5

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួន ។

២-នៅក្នុងកំណត់ហេតុដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ ហើយត្រូវសរសេរឈ្មោះ និង ចុះហត្ថលេខា :

ក-សញ្ញាណរឿងក្តី ។

ខ-ពេលវេលា និង ទីកន្លែងដែលបំពេញមុខនាទី ។

គ-ខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង ។

ឃ-ថ្ងៃ ខែ ឆ្នាំ ដែលធ្វើកំណត់ហេតុ ។

**ប្រការ ១៣** ពន្ធដាក់ពាក្យសុំ

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ។

២-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ ទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ។

**ប្រការ ១៤** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

១-អ្នកដាក់ពាក្យសុំ ត្រូវទទួលបន្ទុកក្នុងការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំនេះ ។

២-ចំពោះសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់ តុលាការត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។

៣-សោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មានដូចតទៅ :

ក-សោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅ សម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ។

ខ-សោហ៊ុយសម្រាប់ការផ្ញើឯកសារ ទូរស័ព្ទ និង ទូរសារ ជាអាទិ៍ ។ 5

គ-សោហ៊ុយសម្រាប់ការជូនដំណឹងជាសាធារណៈ ។

ឃ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់អ្នកសង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ (អ្នកសង្កេតការណ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ង-កម្រៃសម្រាប់អ្នកបច្ចេកទេស ឬ កម្មករ ។

ច-សោហ៊ុយសម្រាប់ការដឹកជញ្ជូន ថែរក្សា និង គ្រប់គ្រងវត្ថុ ។

ឆ-សោហ៊ុយសម្រាប់ការប្រមូលផល ។

ជ-សោហ៊ុយសម្រាប់ការទទួលលិខិតបញ្ជាក់ពីស្ថាប័នសាធារណៈ ។

ឈ-សោហ៊ុយសម្រាប់ថត និង ផ្តិតរូបថត ដើម្បីថតស្ថានភាពបច្ចុប្បន្ននៃវត្ថុ ។

ញ-សោហ៊ុយសម្រាប់ការធ្វើលិខិតបញ្ជាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៩ នៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សោហ៊ុយស្នាក់នៅ និង កម្រៃសម្រាប់អ្នកវាយតម្លៃ ។

ឋ-សោហ៊ុយធ្វើលិខិតរាយការណ៍ដែលត្រូវដាក់ជូនទៅតុលាការអនុវត្ត ។

ឌ-សោហ៊ុយចាំបាច់សម្រាប់ការលក់តាមវិធីផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៤-ចំពោះការគណនាចំនួននៃសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅដែលបានកំណត់នៅក្នុងចំណុច ក នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវអនុលោមទៅតាមករណីនៃក្រឡាបញ្ជី ។

**ប្រការ ១៥** ការបង់សោហ៊ុយជាមុន

១-ចំពោះកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម អាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននូវសោហ៊ុយចាំបាច់ដើម្បីបាត់ចែងកិច្ចការនោះ តាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកដាក់ពាក្យសុំនោះ បានទទួលការសង្គ្រោះលើបណ្តឹង ។ 5

២-ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបង់ជាមុននូវចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាអាចលើកចោលពាក្យសុំនោះបាន ។

**ប្រការ ១៦** បញ្ញត្តិពិសេសក្នុងករណីនៃពាក្យសុំដោយអ្នកដែលបានទទួលការសង្គ្រោះលើបណ្តឹង

ក្នុងចំណោមសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការអនុវត្តដោយបង្ខំដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំរបស់អ្នកដែលបានទទួលការសង្គ្រោះលើបណ្តឹង ប្រសិនបើមានសោហ៊ុយខ្លះដែលមិនអាចប្រមូលពីកូនបំណុលនៃការអនុវត្ត រដ្ឋត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។

**ប្រការ ១៧** អានុភាពនៃប្រកាសនេះ

ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទដែលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ។ ៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧

មន្ត្រី

អង្គ_វង្សវឌ្ឍានា

**ចម្លងជូន** :

- តុលាការខេត្ត-ក្រុង

  "ដើម្បីអនុវត្ត"

- តុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមតុលាការខេត្ត-ក្រុង
- តុលាការយោធា និង អយ្យការអមតុលាការយោធា
- អគ្គាធិការដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- គណៈមេធាវី

  "ដើម្បីជ្រាប"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :..០៦៤.គយ.ប្រក.១៨

# ប្រកាស

## ស្តីពី

## បែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩០៣ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- បានឃើញប្រកាសលេខ ០៩៣ កយប្រក/១៨ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ របស់ក្រសួងយុត្តិធម៌ ស្តីពីការកែសម្រួល និងផ្ទេរភារកិច្ចមន្ត្រីអាជ្ញាសាលាក្នុងក្របខណ្ឌក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់ក្នុងការអនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌

## សម្រេច

ប្រការ១.

១.១.មន្ត្រីអាជ្ញាសាលា ត្រូវទទួលបន្ទុកអនុវត្តកិច្ចការអាជ្ញាសាលានៅក្នុងដែនសមត្ថកិច្ច នៃសាលាដំបូងដែលខ្លួនប្រចាំការ។

១.២.សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវប្រគល់កិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់អាជ្ញាសាលា ជូនទៅមន្ត្រីអាជ្ញាសាលា ដែលកំពុងប្រចាំការនៅទីនោះ ដើម្បីអនុវត្តការងារតាមច្បាប់ជាធរមាន លើកលែងតែ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមិនទាន់មានមន្ត្រីអាជ្ញាសាលាប្រចាំការ ត្រូវបន្តអនុវត្តតាមប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

ប្រការ២.

២.១. សាលាដំបូងរាជធានី-ខេត្ត មានភារកិច្ចជួយសម្របសម្រួលនូវរាល់កិច្ចការរដ្ឋបាលរបស់មន្ត្រីអាជ្ញាសាលា ដោយត្រូវចេញដីកាសម្រេចស្តីពីការបែងចែកសំណុំរឿង និងលេខលំដាប់សំណុំរឿង សម្រាប់ប្រគល់ជូនមន្ត្រីអាជ្ញាសាលាដែលកំពុងប្រចាំការនៅទីនោះ។

២.២.មន្ត្រីអាជ្ញាសាលាដែលប្រចាំការនៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាដំបូងរាជធានី-ខេត្តនោះជាបណ្តោះអាសន្ន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី ឬច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលាចូលជាធរមាន។

ប្រការ៣.

មន្ត្រីអាជ្ញាសាលាដែលប្រចាំការនៅសាលាដំបូងរាជធានី-ខេត្ត ត្រូវស្នើសុំគោលការណ៍ណែនាំជាមុនពីក្រសួងយុត្តិធម៌ រាល់ការអនុវត្តដោយបង្ខំទាំងឡាយណាដែលអាចនឹងមានការប្រឆាំង ជាហេតុបង្កអោយមានភាពចលាចល វឹកវរ ឬអសន្តិសុខដល់សង្គម និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរដែលមិនអាចគ្រប់គ្រងបាន។

ប្រការ៤.

សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ ស្តីពីកិច្ចការអាជ្ញាសាលាប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងយុត្តិធម៌តាមកាលកំណត់។

ប្រការ៥.

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋានកិច្ចការតុលាការ គ្រប់អគ្គនាយកដ្ឋានគ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហ ១០រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍនា**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
« ដើម្បីជូនជ្រាប »
-ដូចប្រការ៥
« ដើម្បីអនុវត្ត »
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

- សំណុំរឿងរដ្ឋប្បវេណីលេខ ២៥០៨ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។
- សាលក្រមលេខ ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ។

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១។

### ចៅក្រមជំនុំជម្រះ

លោក ភូយ សៅ ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជី

លោក យ៉ុន សារ៉ុន ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

- ដើមចោទ៖ ឈ្មោះ ស ភេទប្រុស អាយុ ៦៥ឆ្នាំ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ ន (ស្លាប់) មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- អ្នកតំណាងដោយអាណត្តិ៖

  មេធាវី ខេង លី មេធាវី យ៉េន ស៊ីណាល់ មេធាវី ឡុង ស្រីនិច មានការិយាល័យស្ថិតនៅ អាគារលេខ ១០១-១០៣ ផ្លូវ១៩៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

- ចុងចម្លើយ៖ ឈ្មោះ ម ភេទប្រុស អាយុ ៤៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្លូវ ភូមិ រាជធានីភ្នំពេញ។

- អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖

  មេធាវី ឯក សាវ៉ាវុធ មេធាវី ស៊ាង គីមហ៊ាង ជាមេធាវីនៃការិយាល័យមេធាវី ឯក សាវ៉ាវុធ មានអាសយដ្ឋានផ្ទះលេខ ៣៧៧ ផ្ទះលេខ ២៧ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

### អង្គហេតុ និងចំណុចវិវាទ

ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១. ស្នើសុំអនុវត្តកិច្ចព្រមព្រៀងចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០៦ ដោយសុំអោយទទួលស្គាល់ថា ឈ្មោះ ស និងភរិយាឈ្មោះ ន ជាម្ចាស់កម្មសិទ្ធិលើដី មានទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

២. បង្គាប់អោយចុងចម្លើយឈ្មោះ ម ប្រគល់ដីទំហំ ១២ម x ៧០ម មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មកអោយដើមចោទឈ្មោះ ស

៣. បង្គាប់អោយចុងចម្លើយឈ្មោះ ម ចាកចេញពីដី និងរុះរើរាល់សំណង់ទាំងអស់ចេញពីដី ទំហំ ១២ម x ៧០ម មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

៤. អោយចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី

៥. ទាមទារសំណងការខូចខាតពេលវេលា និងសេវាមេធាវី ចំនួន $១០០.០០០ (ដប់ម៉ឺនដុល្លារអាមេរិក)។

## ខ. ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១ ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ កាលពីឆ្នាំ១៩៧៩ ដើមចោទ និងចុងចម្លើយបានរស់នៅជុំគ្នាជាគ្រួសារដែលមានសមាជិកចំនួន ៨នាក់ មានឈ្មោះ ង ជាឪពុក ឈ្មោះ ន និងប្តីឈ្មោះ ស ឈ្មោះ ជ ឈ្មោះ ម ឈ្មោះ វ ឈ្មោះ រ និងឈ្មោះ ទ ស្ថិតនៅលើដីទំហំ ១២ម៉ែត្រ x ១៤០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល (បច្ចុប្បន្នស្ថិតនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ)។ នៅឆ្នាំ១៩៨២ ឈ្មោះ ង ជាឪពុកក្មេករបស់ដើមចោទ និងកូន១បង្កើតចំនួន ៥នាក់ទៀត បានទៅរស់នៅជំរុំជាយដែនថៃ។ នៅឆ្នាំ១៩៩២ ឪពុកក្មេកឈ្មោះ ង និងកូន១ បានត្រឡប់មកស្រុកកំណើតវិញ។ ដោយសារគ្មានដីលំនៅដ្ឋាន ដើមចោទក៏បានប្រគល់ដីឱ្យពាក់កណ្តាល ចំនួន ១២ម៉ែត្រ x ៧០ម៉ែត្រ នៅប៉ែកខាងលិច ហើយពាក់កណ្តាលទៀត ប៉ែកខាងកើតជារបស់ដើមចោទ ដូចមានក្នុងកិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៦។ ប៉ុន្តែ នៅឆ្នាំ២០០៧ ដើមចោទបានចាកចេញមករស់នៅភ្នំពេញ ដោយទុកដីរបស់ខ្លួនឱ្យឪពុកក្មេកឈ្មោះ ង និងកូន១របស់គាត់ជួយថែរក្សាមើល។ លុះដល់ឆ្នាំ២០១៧ ចុងចម្លើយឈ្មោះ ម បានមករុះរើផ្ទះរបស់ដើមចោទចោល ហើយសាងសង់ផ្ទះថ្មី នៅលើដីរបស់ដើមចោទនោះ ដោយអះអាងថា ជាមរតករបស់ឪពុកបង្កើតខ្លួនឈ្មោះ ង ។ ទើបដើមចោទបានប្តឹងមកតុលាការ ទាមទារឱ្យចេញសាលក្រមទទួលស្គាល់ និងអនុវត្តកិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៦ និងបង្គាប់ឱ្យចុងចម្លើយប្រគល់ដីនេះ ឱ្យទៅដើមចោទវិញ។

### ខ.២ ចំណុចវិវាទ៖

តើដើមចោទមានមូលហេតុ ឬគតិយុត្តស្របច្បាប់ដើម្បីទាមទារឱ្យចុងចម្លើយប្រគល់ដីដែរឬទេ?

### ខ.៣ ការអះអាងរបស់សហដើមចោទ

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា ក្នុងនាមខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ នៅតែរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ និងពាក្យស្នើសុំកែតម្រូវពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ព្រមទាំងខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដូចមានក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ទុកទាំងស្រុង ពុំមានការកែប្រែចំណុចណាឡើយ។ ខ្ញុំបាទសូមបញ្ជាក់ជូនតុលាការបន្ថែមដូចខាងក្រោម៖

ចំណុចទី១ ខ្ញុំបាទសូមរៀបរាប់អំពីអង្គហេតុ

កាលពីឆ្នាំ១៩៧៩ កូនក្តីយើងខ្ញុំ ឈ្មោះ ស និងភរិយាឈ្មោះ ខ រួមជាមួយនឹងក្រុមគ្រួសារឪពុកក្មេករបស់កូនក្តីយើងខ្ញុំ ព្រមទាំងកូន ០៥ (ប្រាំ) នាក់ ដែលមានឈ្មោះ ជ ឈ្មោះ ម ឈ្មោះ វ ឈ្មោះ រ និងឈ្មោះ ១ បានរស់នៅជុំគ្នាលើដីដែលមានទីតាំងស្ថិតនៅភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល មានទំហំ ១២ម x ១៤០ម។ លុះរហូតដល់ឆ្នាំ១៩៨២ ឪពុកក្មេករបស់កូនក្តីយើងខ្ញុំ និងកូនទាំង ០៥ (ប្រាំ) នាក់របស់គាត់បានចាកចេញពីដីនេះទៅរស់នៅជំរុំ។ ចាប់តាំងពីពេលដែលគាត់ និងក្រុមគ្រួសារចាកចេញពីដីនោះមក កូនក្តីយើងខ្ញុំ និងភរិយារស់នៅ និងគ្រប់គ្រងលើដីដែលមានទីតាំងខាងលើ រហូតដល់ឆ្នាំ១៩៩២ ឪពុកក្មេករបស់កូនក្តីយើងខ្ញុំ និងក្រុមគ្រួសារគាត់បានត្រឡប់មកវិញ។ ដោយហេតុថា ឪពុកក្មេកកូនក្តីយើងខ្ញុំបានសុំដីពាក់កណ្តាលដែលមានទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ ដើម្បីអោយគាត់ និងក្រុមគ្រួសាររស់នៅ ដោយគាត់ពុំមានដីសំរាប់រស់នៅទេ កូនក្តីយើងខ្ញុំបានឯកភាពតាមការស្នើសុំរបស់ឪពុកក្មេក។

ក្រោយមកនៅឆ្នាំ២០០៦ កូនក្តីយើងខ្ញុំ និងឪពុកក្មេក រួមជាមួយនឹងកូនៗរបស់គាត់ ក៏បានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃ០២ ខែមេសា ឆ្នាំ២០០៦ ដែលផ្តល់ដីទំហំ ១២ម x ៧០ម ដែលស្ថិតនៅផ្លូវលំ បែកខាងលិច ហើយសល់ ១២ម x ៧០ម បែកខាងកើតគឺជាកម្មសិទ្ធិរបស់កូនក្តីយើងខ្ញុំនិងភរិយា ដែលមានគំនូសបង្ហាញប្លង់ដោយកំណត់ច្បាស់លាស់ពីទំហំដែលខ្ញុំបាទបានកាត់ជូនឪពុកក្មេក និងចំណែកដែលកូនម្នាក់ៗរបស់គាត់គួរទទួលបាន។ លុះដល់ឆ្នាំ២០០៧ កូនក្តីយើងខ្ញុំបានចាកចេញមករស់នៅភ្នំពេញ ខ្ញុំក៏បានទុកដីនោះឱ្យឪពុកក្មេក និងកូនៗគាត់ជួយថែរក្សា។ មកដល់ឆ្នាំ២០១៧ កូនរបស់គាត់ម្នាក់ក្នុងចំណោមកូនទាំង ០៥ (ប្រាំ) នាក់ ឈ្មោះ ម ក៏បានមករុះរើផ្ទះរបស់កូនក្តីយើងខ្ញុំដែលបានមានទីតាំងលើដីនោះ ហើយសង់ផ្ទះថ្មីរំលោភយកដីរបស់កូនក្តីយើងខ្ញុំទៀតផង។ .

ចំណុចទី២ ខ្ញុំបាទសូមរៀបរាប់អំពីអង្គច្បាប់

ការណ៍ដែលកូនក្តីយើងខ្ញុំបានដាក់ពាក្យបណ្តឹងទាមទារអោយចុងចម្លើយប្រគល់ដី គឺមានមូលហេតុដូចបានអះអាងខាងក្រោម៖

ក. ចាប់តាំងឆ្នាំ១៩៨២ ឪពុកក្មេករបស់កូនក្តីយើងខ្ញុំ និងកូនទាំង ០៥ (ប្រាំ) នាក់ របស់គាត់បានចាកចេញពីដីនេះទៅរស់នៅជំរុំ។ ចាប់តាំងពីពេលដែលឪពុកក្មេក និងក្រុមគ្រួសារចាកចេញពីដីនោះមកកូនក្តីយើងខ្ញុំ និងភរិយាបានរស់នៅ និងគ្រប់គ្រងលើដីដែលមានទីតាំងខាងលើរហូតដល់ឆ្នាំ១៩៩២ ទើបឪពុកក្មេកកូនក្តីយើងខ្ញុំ និងក្រុមគ្រួសារគាត់បានត្រឡប់មកវិញ។ យោងតាមស្មារតីនៃមាត្រា៣០ ច្បាប់ភូមិបាល ឆ្នាំ២០០១ បានចែងថា បុគ្គលទាំងឡាយដែលបានអាស្រ័យផល នៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំយ៉ាងតិច និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ ដូច្នេះ ប្រសិនបើគិតតាំងពីឆ្នាំ១៩៨២ រហូតដល់ឆ្នាំ១៩៩២ គឺកូនក្តីយើងខ្ញុំបានរស់នៅ និងកាន់កាប់ជាក់ស្តែងលើដីនោះ រយៈពេល ១០ឆ្នាំមកហើយ ហេតុដូចនេះហើយ កូនក្តីយើងខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិលើដីដែលបានកាន់កាប់ទាំងមូលរួចស្រេចទៅហើយ។

ខ. តាមរយៈកិច្ចព្រមព្រៀងចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៦ រវាងកូនក្តីយើងខ្ញុំឈ្មោះ ស និងប្រពន្ធឈ្មោះ ម ព្រមទាំងឪពុករបស់គាត់ឈ្មោះ ង ដែលបានធ្វើការកំណត់អំពីព្រំប្រទល់ដី

និងបានបែងចែកទំហំដីក្នុងកិច្ចព្រមព្រៀងយ៉ាងច្បាស់ថា ដីនោះមានព្រំប្រទល់ខាងជើងដល់ដីឈ្មោះ ឃ ខាងត្បូងទល់នឹងដីឈ្មោះ ល ខាងលិចទល់នឹងដីផ្លូវលំ និងខាងកើតទល់នឹងដីផ្លូវលំ និងបានព្រមព្រៀងប្រគល់ដីលំនៅដ្ឋាននេះចំនួនពាក់កណ្ដាលទៅក្រោយប្រវែង ៧០ម៉ែត្រ អោយទៅឈ្មោះ ង ជាឪពុកក្មេកចែកអោយកូនចំនួនប្រាំនាក់។ ខ្លឹមសារក្នុងកិច្ចព្រមព្រៀងនេះ បានសបញ្ជាក់យ៉ាងច្បាស់ថា ដីពាក់កណ្ដាលខាងមុខទំហំ ១២ x ៧០ ម៉ែត្រ គឺជាកម្មសិទ្ធិរបស់កូនក្ដីយើងខ្ញុំឈ្មោះ ស ។ រីឯពាក់កណ្ដាល ៧០ ម៉ែត្រ ខាងក្រោយ គឺជាកម្មសិទ្ធិរបស់ឪពុកក្មេកឈ្មោះ ង និងចែកអោយកូនចំនួន ៥ (ប្រាំ) នាក់ ដែលក្នុងនោះ មានឈ្មោះ ម ផងដែរ។

គ. ចំពោះចុងចម្លើយឈ្មោះ ជឹម ឬទ្ធីសក្ដិ ក៏ធ្លាប់បានធ្វើកិច្ចសន្យាចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ដោយបញ្ជាក់ថា សុំស្នាក់នៅជាបណ្ដោះអាសន្នទៅលើដីលំនៅដ្ឋានភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល ពោលគឺឈ្មោះ ម គ្រាន់តែសុំរស់នៅជាបណ្ដោះអាសន្នលើដីរបស់ឈ្មោះ ស និងប្រពន្ធឈ្មោះ ន តែប៉ុណ្ណោះ។

ឃ. ម្យ៉ាងវិញទៀត នៅក្នុងនីតិវិធីសាកសួរសាក្សីក្នុងសំណុំរឿងរក្សាការពារ សាក្សីឈ្មោះ ទ ដែលត្រូវជាប្អូនរបស់ចុងចម្លើយបានឆ្លើយជូនតុលាការថា នៅឆ្នាំ១៩៧៩ ឪពុករបស់ខ្លួនឈ្មោះ ង បានកាន់កាប់ និងសង់ផ្ទះលើដីទំនាស់នោះ លុះដល់ឆ្នាំ១៩៨០ ឪពុករបស់ខ្លួនបានទៅរស់នៅជំរុំ ហើយបងស្រីរបស់ខ្លួនឈ្មោះ ន និងប្ដីឈ្មោះ ស បានរស់នៅលើដីនោះ។ នៅឆ្នាំ១៩៩១ ឪពុករបស់ខ្លួនបានត្រឡប់មកវិញ និងបានរស់នៅលើដីទំនាស់នោះ។ ពេលនោះ ឪពុករបស់ខ្លួនបានព្រមព្រៀងជាមួយបងស្រីឈ្មោះ ន ដោយប្រគល់ដីផ្នែកខាងក្រោយឱ្យទៅកូនៗ ចំនួន ៥នាក់។ ចំណែកដីពាក់កណ្ដាលទៀតនៅផ្នែកខាងមុខ គឺបងស្រី ឈ្មោះ ន ជាប្រពន្ធរបស់ដើមចោទជាអ្នកគ្រប់គ្រង។ ឈ្មោះ ម បានចុះផ្ទះចាស់ចេញពីលើដីនោះ និងបានសង់ផ្ទះថ្មីជំនួស ហើយផ្ទះចាស់នោះគាត់ចុះរើឱ្យទៅបងស្រីឈ្មោះ ន ។ សាក្សីឈ្មោះ រ ដែលជាប្អូនរបស់ចុងចម្លើយជូនតុលាការថា ឈ្មោះ ម បានលក់ដីដែលជាចំណែករបស់គាត់ឱ្យមកខ្លួនក្នុងតម្លៃ ១.០០០$ ។ សាក្សីឈ្មោះ រ បានបំភ្លឺដែរថា ដីទំនាស់នោះ គ្រួសាររបស់ខ្លួនបានបែងចែកដូចមានក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៦ រួចហើយ។ ចំណែកលិខិតប្រគល់មរតកដែលឈ្មោះ ម យកមកបង្ហាញ នោះ ពួកខ្លួនជាបងប្អូនសុំបដិសេធ ព្រោះពួកខ្លួនមិនបានដឹងទេ។ ម្យ៉ាងទៀត សាក្សីឈ្មោះ ង ជាអ្នកជិតខាងរស់នៅក្បែរដីទំនាស់នោះ ក៏បានឆ្លើយជូនតុលាការក្នុងសំណុំរឿងរក្សាការពារថា ខ្លួនឃើញឈ្មោះ ស រស់នៅលើដីទំនាស់នោះរហូត ហើយក្រោយមកឈ្មោះ ស ទៅរស់នៅភ្នំពេញ ក៏បានទុកដីនោះឱ្យឈ្មោះ រ លក់ឥវ៉ាន់ចាប់ហួយ។

តាមអង្គហេតុ និងអង្គច្បាប់ដូចបានបកស្រាយខាងលើបញ្ជាក់ឱ្យឃើញថា កូនក្ដីខ្ញុំបាទគឺជាម្ចាស់ដី ដែលកាន់កាប់លើដីនោះដោយសុចរិត និងស្របច្បាប់ ហើយតាងនាមកូនក្ដី យើងខ្ញុំជាមេធាវីតំណាងដោយអាណត្តិសូមសំណូមពរឱ្យតុលាការមេត្តារកភាពយុត្តិធម៌ជូនកូនក្ដីយើងខ្ញុំ ដោយពិនិត្យ និងសម្រេចដូចខាងក្រោម៖

១. ស្នើសុំអនុវត្តកិច្ចព្រមព្រៀងចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០៦ ដោយសុំអោយទទួលស្គាល់ថា ឈ្មោះ ស និងភរិយាឈ្មោះ ខ ជាម្ចាស់កម្មសិទ្ធិលើដី មានទំហំ ១២ម x ៧០ម មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

២. បង្គាប់អោយចុងចម្លើយឈ្មោះ ម ប្រគល់ដីទំហំ ១២ម x ៧០ម មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មកអោយដើមចោទឈ្មោះ ស ។

៣. បង្គាប់អោយចុងចម្លើយឈ្មោះ ម ចាកចេញពីដី និងរុះរើរាល់សំណង់ទាំងអស់ចេញពីដី ទំហំ ១២ម x ៧០ម មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

៤. អោយចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

៥. ទាមទារសំណងការខូចខាតពេលវេលា និងសេវាមេធាវី ចំនួន $១០០.០០០ (ដប់ម៉ឺនដុល្លារអាមេរិក)។

## ខ.៥ ការអះអាងរបស់ចុងចម្លើយ

មេធាវី ឯក សាវ៉ាវុធ អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីអះអាងថា ខ្ញុំបាទសុំបដិសេធចំពោះការទាមទាររបស់ដើមចោទ ដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ និងពាក្យស្នើសុំកែតម្រូវបណ្តឹង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ចោលទាំងស្រុង ដោយហេតុថា ការលើកឡើងរបស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ គឺពុំត្រឹមត្រូវទេ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់ឈ្មោះ ង និងប្រពន្ធ ព្រមទាំងកូនចំនួន ០៥នាក់ បានចូលមករស់នៅក្នុងស្រុកកំណើតរបស់ខ្លួនវិញ និងបានរុករានកាប់ស្ការដីដើម្បីប្រើប្រាស់អាស្រ័យផលដាំដំណាំ និងសង់ផ្ទះនៅលើដីទំនាស់នោះ ដែលពេលនោះ ឈ្មោះ ង ត្រូវបានរដ្ឋអំណាចតែងតាំងជាមេឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលសព្វថ្ងៃត្រូវបានដូរមកភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដែលបានកាន់កាប់លើដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ក្រោយមក នៅឆ្នាំ១៩៨១ ឈ្មោះ ស បានរៀបការជាមួយនឹងបងស្រីរបស់ឈ្មោះ ម ឈ្មោះ ខ និងបានស្នាក់នៅជាមួយក្រុមគ្រួសារនោះ ហើយនៅឆ្នាំនោះដែរ ឪពុករបស់ខ្លួន និងបងប្អូនមួយចំនួនបានទៅរស់នៅជាយដែន ដោយទុកដីនិងផ្ទះនោះឱ្យបងស្រីឈ្មោះ ខ ជាអ្នកមើលថែរក្សា។ លុះដល់ឆ្នាំ១៩៨៣ ឪពុករបស់កូនក្តីខ្ញុំក៏បានត្រឡប់មកវិញ ហើយបងស្រីរបស់កូនក្តីខ្ញុំបាទក៏បានប្រគល់ដីនិងផ្ទះមកឱ្យកូនក្តីរបស់ខ្ញុំបាទវិញដែរ។ នៅឆ្នាំ១៩៨៩ ឈ្មោះ ង ជាឪពុករបស់កូនក្តីខ្ញុំ បានធ្វើកិច្ចសន្យាបែងចែកកេរឱ្យកូនទាំងអស់។ នៅក្នុងនោះ ឈ្មោះ ខ និងប្តីឈ្មោះ ស ត្រូវបានដី ១០ម៉ែត្រ x ១៥ម៉ែត្រ នៅជាប់កន្ទុយដីរបស់កូនក្តីខ្ញុំបាទឈ្មោះ ម ហើយចំណែកដីដែលកូនក្តីខ្ញុំបាទរស់នៅសព្វថ្ងៃ និងបានសាងសង់លើដីដែលឪពុកឈ្មោះ ង បានចែកឱ្យ ហើយចំពោះការលើកឡើងរបស់ដើមបណ្តឹង បានបញ្ជាក់ថា កូនក្តីរបស់ខ្ញុំបាទរស់នៅលើដីរបស់គាត់ទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ នោះ គឺជាការទាមទារដែលពុំត្រឹមត្រូវ និងពុំសមរម្យ។ ជាក់ស្តែងកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ ស បានដាក់ពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសុំមិនឱ្យកូនក្តីរបស់ខ្ញុំបាទសាងសង់ផ្ទះដែលមានថ្មខាងក្រោម និងឈើផ្នែកខាងលើ លើដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងហាមឃាត់មិនឱ្យលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ និងធ្វើអំណោយផ្សេងទៀត នៅលើដីនេះ ក៏ត្រូវបានសាលាឧទ្ធរណ៍ចេញដីកាសម្រេចលេខ ៣៣ ក្រ.ឋ.យ.ង.ត.ស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ដោយបានលុបចោលដីកាសម្រេចលើពាក្យសុំតវ៉ាចំពោះដីកា

សម្រេចចាត់ចែងបណ្ដោះអាសន្ន លេខ ៩៦ "ណា" ងរ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ដោយហេតុថា ឈ្មោះ ស ជាម្ចាស់បំណុលពុំមានសិទ្ធិក្នុងការប្ដឹងទាមទារឱ្យតុលាការចេញសេចក្ដីសម្រេចនោះទេ ព្រោះឈ្មោះនេះ មិនមែនជាមនុស្សដែលមានផលប្រយោជន៍ក្នុងការប្ដឹងទាមទារមរតករបស់ឪពុកក្មេកនោះទេ ព្រោះខ្លួនជាកូនប្រសា ហើយជាពិសេសទៅទៀត ឈ្មោះ ខ ក៏ត្រូវបានស្លាប់ហើយដែរ។

ដូច្នេះ សរុបសេចក្ដីមក ក្នុងនាមខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ស្នើសុំឱ្យតុលាការច្រានចោលការទាមទាររបស់ឈ្មោះ ស ដូចមានក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ និងពាក្យស្នើសុំកែតម្រូវបណ្ដឹង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ចោលទាំងស្រុង។

## សំអាងហេតុ

១. ឃើញថា នៅក្នុងរឿងនេះ គូភាគីមានវិវាទទៅលើកិច្ចសន្យានៃការបែងចែកដី ហើយចុងចម្លើយបានចូលមកអះអាងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនបានលើកឡើងអំពីសមត្ថកិច្ចរបស់តុលាការនោះឡើយ។ ដូច្នេះ តុលាការអាចលើកយករឿងនេះ មកវិនិច្ឆ័យសេចក្ដីបាន ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី។

២. ឃើញថា ដើមចោទបានធ្វើការបែងចែកដីដែលមានទំហំ ១២ម៉ែត្រ x ១៤០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល (បច្ចុប្បន្នស្ថិតនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ) ជាពីរចំណែកឱ្យទៅឪពុកក្មេករបស់ដើមចោទឈ្មោះ ង ដើម្បីចែកឱ្យកូនៗ របស់គាត់ទៀត ដោយដើមចោទទទួលបានដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ ហើយឈ្មោះ ង ទទួលបាន ១២ម៉ែត្រ x ៧០ម៉ែត្រ។ ឈ្មោះ ង បានបែងចែកឱ្យទៅកូនៗ របស់គាត់ គ្រប់ៗគ្នា ក្នុងនោះមានទាំងចុងចម្លើយផងដែរ ដែលបានទទួល ២៥ម៉ែត្រ រួមជាមួយឈ្មោះ ខ ដូចមាននៅក្នុងកិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៦។ម្យ៉ាងទៀត តាមឯកសារភស្តុតាងដែលចុងចម្លើយដាក់ជូនមកតុលាការ តុលាការពិនិត្យឃើញថា តាមសាក្សីដែលជាបងប្អូនបង្កើតរបស់ចុងចម្លើយ ឈ្មោះ ទ ឈ្មោះ វ ឈ្មោះ រ និងឈ្មោះ ង ដែលជាកូនរបស់ឈ្មោះ ខ សុទ្ធតែបានបំភ្លឺជូនតុលាការថា ចុងចម្លើយបានទទួលចំណែកដីដែលឪពុកឈ្មោះ ង បានបែងចែកឱ្យនោះហើយ ប៉ុន្តែចុងចម្លើយបានលក់ទៅឱ្យឈ្មោះ វ ចំនួន ១.០០០ ដុល្លារអាមេរិក អស់ហើយ។

៣. ឃើញថា ចុងចម្លើយ អះអាងថា ដីដែលមានវិវាទនេះ ឪពុករបស់ខ្លួនឈ្មោះ ង ជាអ្នកផ្ដល់ឱ្យជាមរតក ដូចមាននៅក្នុងកិច្ចសន្យាអំពីការចែកចាយមរតក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩។ តុលាការពិនិត្យឃើញថា ចំពោះលិខិតនេះ បងប្អូនបង្កើតរបស់ចុងចម្លើយ ក៏បានអះអាងដែលថា ពួកខ្លួនមិនដឹងលិខិតនេះទេ។ ផ្ទុយទៅវិញ ពួកខ្លួនទទួលស្គាល់តែកិច្ចសន្យា ព្រមព្រៀង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៦ តែប៉ុណ្ណោះ។ ដូច្នេះ តុលាការពិនិត្យឃើញថា ការបដិសេធរបស់ចុងចម្លើយទៅលើការទាមទាររបស់ដើមចោទនោះ មិនមានមូលដ្ឋាន និងភស្តុតាងច្បាស់លាស់នោះឡើយ។ ដូចនេះ ការចូលទៅកាន់កាប់លើចំណែកដីដែលមានទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ ជាអំពើខុសច្បាប់។ ផ្ទុយទៅវិញ ចំណែកដីនេះ គឺជាការកាន់កាប់ស្របច្បាប់របស់ដើមចោទ។

# សេចក្ដីសម្រេចបញ្ចប់

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ម ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឱ្យទៅដើមចោទឈ្មោះ ស ។

២. បង្គាប់ឱ្យចុងចម្លើយប្រគល់ដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅឱ្យដើមចោទ។

៣. បង្គាប់ឱ្យចុងចម្លើយ បង់សំណងការខូចខាត ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ទៅឱ្យដើមចោទ។ ការទាមទារលើសពីនេះច្រានចោល។

៤. ច្រានចោលការទាមទារផ្សេងទៀតរបស់ដើមចោទ។

៥. ឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

សាលក្រមនេះ ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ដោយកំបាំងមុខចុងចម្លើយ។ ក្នុងករណីប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេលដែលច្បាប់បានកំណត់។

ថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និង ត្រា៖ **ភួយ សៅ**

---

**បានឃើញ**

ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

**ចៅក្រម**

ភួយ សៅ

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

យ៉ុន សារ៉ុន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យសុំបញ្ជាក់សាលក្រមស្ថាពរ

ខ្ញុំបាទឈ្មោះ.......................... ភេទ.......... អាយុ.............ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មាន អាសយដ្ឋានបច្ចុប្បន្ននៅភូមិ................ ឃុំ................. ស្រុក...................... រាជធានីភ្នំពេញ ។

### សូមគោរពចូលមក
### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ** សូមបញ្ជាក់ស្ថាពរ លើសាលក្រមរដ្ឋប្បវេណីលេខ...................... ចុះថ្ងៃទី....... ខែ...... ឆ្នាំ២០....... របស់សាលាដំបូងរាជធានីភ្នំពេញ ។

**យោង** - សំណុំរឿងរដ្ឋប្បវេណីលេខ............ ចុះថ្ងៃទី...... ខែ.......... ឆ្នាំ២០......... របស់សាលាដំបូងរាជធានីភ្នំពេញ។

- សាលក្រមរដ្ឋប្បវេណីលេខ.............. ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០........ របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចម្លង) ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី..... ខែ.... ឆ្នាំ២០.... សាលាដំបូងរាជធានីភ្នំពេញ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណីលេខ........... ចុះថ្ងៃទី..... ខែ......... ឆ្នាំ២០.... បន្ទាប់ពីជំនុំជម្រះរួចមក សាលាដំបូងរាជធានីភ្នំពេញបានចេញ សាលក្រមលេខ............. ចុះថ្ងៃទី......... ខែ......... ឆ្នាំ២០..... ដែលមានសេចក្តីសម្រេចបញ្ចប់ដូចខាងក្រោម ៖

១.......................................................................................................................................។

២.......................................................................................................................................។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ឯកឧត្តមប្រធាន** ជាទីគោរព ! បច្ចុប្បន្ននេះឃើញថាសាលក្រមលេខ............ ចុះថ្ងៃទី...... ខែ........ ឆ្នាំ២០...... របស់សាលាដំបូងរាជធានីភ្នំពេញ ខាងលើនេះ បានចូលជាស្ថាពរហើយ ដោយភាគីមិនប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ។

សេចក្តីដូចបានជម្រាបជូនមកខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាចេញលិខិតបញ្ជាក់សាលក្រមស្ថាពរមកឱ្យខ្ញុំបាទ តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ថ្ងៃ..................... ខែ................. ឆ្នាំ........................ស័ក ព.ស ២៥......

រាជធានីភ្នំពេញ, ថ្ងៃទី......... ខែ.......... ឆ្នាំ២០......

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ១២០៧ ម-ល.ស.ព

## លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រម

**យើង យ៉ុន សារ៉ុន ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញ មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២៥០៨ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ពាក្យសុំបញ្ជាក់ការចូលស្ថាពរនៃសាលក្រម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ ឈ្មោះ ស ភេទប្រុស អាយុ ៦៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលមានខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមរដ្ឋប្បវេណីលេខ ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

### សូមបញ្ជាក់ថា

១. សាលក្រមរដ្ឋប្បវេណីលេខ ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលស្ថាពរ ចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ រួចហើយ។

២. លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមរដ្ឋប្បវេណីនេះ ចេញឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃច័ន្ទ [illegible] ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២

ក្រឡាបញ្ជី

យ៉ុន សារ៉ុន

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យសុំរូបមន្តអនុវត្ត

ខ្ញុំបាទឈ្មោះ.......................... ភេទ........... អាយុ.............ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មាន អាសយដ្ឋានបច្ចុប្បន្ននៅភូមិ................. ឃុំ.................. ស្រុក....................... រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** សូមផ្តល់រូបមន្តអនុវត្ត លើសាលក្រមរដ្ឋប្បវេណីលេខ................ ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០....... របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានចូលជាស្ថាពរ ។

**យោង** - សំណុំរឿងរដ្ឋប្បវេណីលេខ....... ចុះថ្ងៃទី..... ខែ..... ឆ្នាំ២០....... របស់សាលាដំបូងរាជធានីភ្នំពេញ ។

- សាលក្រមរដ្ឋប្បវេណីលេខ.......................... ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០....... របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចម្លង) ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ សាលក្រមរដ្ឋប្បវេណីលេខ................ ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០....... របស់សាលាដំបូងរាជធានីភ្នំពេញ នេះ បានចូលជាស្ថាពរហើយ ប៉ុន្តែពុំទាន់បានភ្ជាប់នូវរូបមន្តអនុវត្តនៅឡើយ ។ ហេតុដូចនេះ សូម **ឯកឧត្តមប្រធាន** មេត្តាផ្តល់រូបមន្តអនុវត្តនៃសាលក្រមរដ្ឋប្បវេណីនេះ ។

សេចក្តីដូចបានជម្រាបជូនមកខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង សម្រេចចេញរូបមន្តអនុវត្តមកឲ្យខ្ញុំបាទដើម្បីយកទៅធ្វើការអនុវត្តទៅតាមនីតិវិធីច្បាប់ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំនាទ ។

ថ្ងៃ.................... ខែ................ ឆ្នាំ.......................ស័ក ព.ស ២៥......

រាជធានីភ្នំពេញ, ថ្ងៃទី......... ខែ.......... ឆ្នាំ២០......

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ ៦៨ ម.ល.រ.អ

## រូបមន្តអនុវត្តសាលក្រមរដ្ឋប្បវេណី

### យើង យ៉ុន សារ៉ុន ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា ៣៥៤ មាត្រា ៣៥៥ និងមាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២៤០៨ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សាលក្រមរដ្ឋប្បវេណី លេខ ៥៨៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ពាក្យសុំរូបមន្តអនុវត្ត ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ ស ភេទប្រុស អាយុ ៦៥ឆ្នាំ (ដើមចោទ)។

### សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្ត មានដូចខាងក្រោមនេះ

ម្ចាស់បំណុលនៃការអនុវត្ត ឈ្មោះ ស ភេទប្រុស អាយុ ៦៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៧អុី ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ អាចអនុវត្តដោយបង្ខំតាមអំណាចសាលក្រមរដ្ឋប្បវេណី លេខ ៥៨៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានចូលជាស្ថាពរ ចាប់ពី ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ រួចហើយ។

កូនបំណុលនៃការអនុវត្ត ឈ្មោះ ម ភេទប្រុស អាយុ ៤៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជបង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំឱ្យសម្រេចតាមសាលក្រមស្ថាពរនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។*

ថ្ងៃច័ន្ទ ៧រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០២២
ក្រឡាបញ្ជី

យ៉ុន សារ៉ុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អនុប្រធានសាលា**
**នៃសាលាដំបូងរាជធានីភ្នំពេញ**

# លិខិតជូនដំណឹង
## ស្តីពី
## ការបង្គាប់ឲ្យអនុវត្តដោយស្ម័គ្រចិត្ត

លេខ៣៥ ជ.អ/២២ យើង **សុខ ចន្ថា** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- បានឃើញ ប្រកាសលេខ ០៦២ កយប្រក១៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ ស្តីពីបែបបទសម្រាប់ការអនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌
- បានឃើញ សំណុំរឿងអនុវត្តដោយអាជ្ញាសាលាលេខ ០៦ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលដីកាលេខ ១២៧ "ម" ល.ស.ព ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ រូបមន្តអនុវត្តលេខ ៦៨ "ម" ល.រ.អ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ ពាក្យសុំអនុវត្តរបស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ *ឈឹម វាសនា ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២*។

### ឃើញថា

សាលក្រមរដ្ឋប្បវេណីលេខ ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញបានចូលជាស្ថាពរ និងមានប្រសិទ្ធិភាពអនុវត្តហើយ ។

### ហេតុដូច្នេះសម្រេច

១. បង្គាប់ឲ្យចុងចម្លើយឈ្មោះ ម    ភេទប្រុស អាយុ ៦៥ឆ្នាំ អនុវត្តដោយស្ម័គ្រចិត្តតាមអំណាចនៃសាលក្រមរដ្ឋប្បវេណីលេខ៥៩៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញបានចូលជាស្ថាពរ ដោយបង្គាប់ឲ្យចុងចម្លើយឈ្មោះ ម    ប្រគល់ដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឲ្យទៅដើមចោទឈ្មោះ ស    ។

២. កូនបំណុលនៃការអនុវត្តខាងលើ ត្រូវអនុវត្តដោយស្ម័គ្រចិត្តតាមសេចក្តីជូនដំណឹងនេះ ក្នុងរយៈពេល ០៣ (បី) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃជូនដំណឹងនេះ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តមិនអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះទេ យើងនឹងចុះធ្វើការអនុវត្តដោយបង្ខំតាមនីតិវិធីច្បាប់ ហើយមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតទ្រព្យសម្បត្តិទាំងឡាយឡើយ។

*ថ្ងៃចន្ទ ៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២២*

**អាជ្ញាសាលា**

**សុខ ចន្ថា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាសាលា**
**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុអនុវត្ត

ថ្ងៃទីប្រាំបួន ខែកញ្ញា ឆ្នាំពីរពាន់ម្ភៃពីរ វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក យើង **សុខ ចន្ថា** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ដោយមានលោក **ស៊ិន សុវណ្ណ** ជាអ្នកធ្វើកំណត់ហេតុអមផង បានចុះអនុវត្តសាលក្រមរដ្ឋប្បវេណីលេខ ៥៨៦ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

| | |
|---|---|
| ១. លោកស្រី **លី រ៉ុហ្សាទី** | អភិបាលរងខណ្ឌ |
| ២. លោក **ឯក សេរីវុធ** | អធិការរងនគរបាលខណ្ឌ |
| ៣. លោក **ម៉ែន ចន** | មេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌ |
| ៤. លោក **ហួត ណារិទ្ធ** | អនុប្រធានការិ.ដ.ន.ស.ភ ខណ្ឌ |
| ៥. លោកស្រី **គុញ សុជាតិ** | ប្រធានការិ. នីតិកម្ម |
| ៦. លោក **សេន ម៉ិនសៀន** | អនុប្រធានសណ្តាប់ធ្នាប់ខណ្ឌ |
| ៧. លោកស្រី **ម៉ិល សុខុម** | ចៅសង្កាត់រងទី១ សង្កាត់កោះដាច់ |
| ៨. លោក **ជួន ឧត្តម** | នាយប៉ុស្តិ៍ស្តីទី ប៉ុស្តិ៍នគរបាលសង្កាត់កោះដាច់ |
| ៩. លោក **ប៉ុខ សំអេច** | មេភូមិក្បាលកោះ |

នៅពេលចុះដល់ទីតាំងស្ថិតនៅលើបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ យើងនិងគណៈកម្មការបានជួបឈ្មោះ      ម      ដែលជាកូនបំណុលនៃការអនុវត្ត និងសាច់ញាតិ ហើយយើងបានអានសាលក្រមខាងលើឲ្យស្តាប់ ឃើញថា ឈ្មោះ      ម      បានប្រឆាំងតវ៉ាចំពោះការអនុវត្ត និងបានអះអាងថាខ្លួនបានឈ្នះក្តីការពារនៅឆ្នាំ ២០១៨ ដោយបានបង្ហាញឯកសារមួយចំនួនផងដែរ។ ប៉ុន្តែយើង និងគណៈកម្មការពិនិត្យឃើញថា ពុំមានឯកសារណាមួយដែលអាចឲ្យអាជ្ញាសាលាធ្វើការផ្អាកការអនុវត្តតាមនីតិវិធីច្បាប់នោះទេ។ ដោយហេតុថាកូនបំណុលឈ្មោះ      ម      នៅតែបន្តប្រឆាំងរារាំងការអនុវត្ត យើងនិងគណៈកម្មការក៏បានអញ្ជើញឈ្មោះ      ម      មកកាន់ប៉ុស្តិ៍នគរបាលសង្កាត់កោះដាច់ដើម្បីសម្របសម្រួលអោយអនុវត្តដោយស្ម័គ្រចិត្ត ហើយបន្ទាប់មកឈ្មោះ      ម      ក៏បានយល់ព្រមអនុវត្តតាមអំណាចសាលក្រមខាងលើ។

ហេតុដូច្នេះ យើង និងគណៈកម្មការសម្រេចអនុវត្តតាមសាលក្រមខាងលើ៖

បង្គាប់ឲ្យចុងចម្លើយប្រគល់ដីទំហំ ១២ម៉ែត្រ x ៧០ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវបេតុង ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅឲ្យដើមចោទឈ្មោះ      ស      ។

ចំពោះចលនវត្ថុរបស់កូនបំណុលដែលមាននៅលើទីតាំងនៃអចលនវត្ថុខាងលើ ភាគីម្ចាស់បំណុលបានឯកភាពទុករយៈពេល ពីរសប្តាហ៍ចាប់ពីថ្ងៃធ្វើកំណត់ហេតុនេះតទៅ ដើម្បីឲ្យឈ្មោះ      ម      រុះរើឲ្យអស់ចេញពីទីតាំង ប៉ុន្តែនៅពេលឈ្មោះ      ម      ចង់ចូលទៅយកចលនវត្ថុទាំងនោះ ត្រូវមានការចូលរួមពីអាជ្ញាធរសង្កាត់ និងភាគីម្ចាស់បំណុលនៃការអនុវត្ត។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់ពីរ និងសែសិបនាទីរសៀលនាថ្ងៃខែឆ្នាំដដែល ដោយបានអានឲ្យអ្នកចូលរួមអនុវត្តបានស្តាប់ ឃើញថាត្រឹមត្រូវរួចឯកភាពចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃទុកជាភស្តុតាង តាមផ្លូវច្បាប់។

| **អាជ្ញាសាលា** | **ភាគីចូលរួម** | **អ្នកធ្វើកំណត់ហេតុ** |
|---|---|---|